ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 01-Jul-2015, 11:34
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៥**

**ម៉ោង ០៩:០០នាទី**

**សវនាការលើកទី៣០២**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម យ៉ា សុខន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា រ៉ូប៊ីន្នី ក្រូហ្វត៍ *(Ms. Robynne CROFT)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆវ័ន្ត

លោក សេង លាង

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ចូសេហ្វ អេនឌ្រូ ប៊យលី
*(Mr. Joseph Andrew BOYLE)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

លោក លីវ សុវណ្ណា

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន

*(Mr. Arthur VERCKEN)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោកស្រី ម៉ុច សុវណ្ណារី

លោក ឡោ ជុនធី

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណា

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម យ៉ា សុខន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក ចូសេហ្វ អេនគ្រូ ប៊ិយលី | អង់គ្លេស |
| លោក រ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក អាកទួរ វែកគែន | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោកស្រី ម៉ុច សុវណ្ណារី | ខ្មែរ |
| លោក ហ៊ឹម ហាន (2-TCW-901) | ខ្មែរ |
| លោកស្រី ជុំ សាមឿន (2-TCCW-247) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក ហ៊ីម ហ៊ន ហៅ ហ៊ីម ហាន** (2-TCW-901)


សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី.....ទំព័រ ៣
សួរដោយលោក អាកទ្វូរ វែកគែន ផ្តើមពី .....ទំព័រ ២០
សួរដោយលោក គង់ សំអុន ផ្តើមពី .....ទំព័រ ៣០


**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី ជុំ សាមឿន** (2-TCCP-247)


សួរដោយប្រធានអង្គជំនុំ ផ្តើមពី .....ទំព័រ ៣៥
សួរដោយលោកស្រី ម៉ុច សុវណ្ណារី ផ្តើមពី .....ទំព័រ ៣៧
សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី ផ្តើមពី .....ទំព័រ ៥១
សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី.....ទំព័រ ៥៥
សួរដោយលោក អាកទ្វូរ វែកគែន ផ្តើមពី .....ទំព័រ ៦៥

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០០:៥៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ អង្គជំនុំជម្រះសូមជម្រាបជូនដល់ភាគី និងសាធារណជនជ្រាបថា នៅក្នុងកិច្ចដំណើរការនីតិវិធីថ្ងៃនេះ និងថ្ងៃស្អែក លោកចៅក្រម និល ណុន ដែលប្រធានអង្គជំនុំជម្រះសាលាដំបូងអវត្តមានដោយមានមូលហេតុមានធុរៈចាំបាច់ផ្ទាល់ខ្លួនគាត់មិនអាចចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះបានទេ។ បន្ទាប់ពីយើងបានពិគ្រោះពិភាក្សាជាមួយនឹងបណ្តាចៅក្រមពេញសិទ្ធិនៃអង្គជំនុំជម្រះសាលាដំបូង រូបយើង យ៉ា សុខន នឹងធ្វើជាប្រធានដឹកនាំកិច្ចដំណើរការសវនាការនៅថ្ងៃនេះ និងថ្ងៃស្អែក និងលោកចៅក្រម ធូ មណី ដែលជាចៅក្រមបម្រុងខាងភាគីជាតិ ជំនួសកន្លែងដែលទំនេរនេះ រហូតដល់លោកប្រធាន និល ណុន អាចចូលរួមកិច្ចដំណើរការសវនាការវិញបាន។ សេចក្តីសម្រេចនេះ ផ្អែកតាមបទប្បញ្ញត្តិវិធាន៧៩(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក។

សវនាការថ្ងៃនេះអង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មសាក្សី ហ៊ឹម ហាន បញ្ចប់ បន្ទាប់មកអង្គជំនុំជម្រះនឹងចាប់ផ្តើមស្តាប់សក្ខីកម្មរដ្ឋប្បវេណីមួយរូប ដែលមានរហស្សនាម 2-TCCP-247។ ក្រឡាបញ្ជីសវនាការ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

[០៩:០២:៤៨]

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ហើយសាក្សីដែលត្រូវមកផ្តល់សក្ខីកម្មបន្តបញ្ចប់នៅថ្ងៃនេះ គឺលោក ហ៊ឹម ហាន លោកមានវត្តមានរួចហើយនៅក្នុងបន្ទប់

សវនាការនេះ។ ហើយដើមបណ្ដឹងរដ្ឋប្បវេណីបន្ទាប់ដែលត្រូវមកផ្ដល់សក្ខីកម្ម បន្ទាប់ពីបញ្ចប់ការស្ដាប់សក្ខីកម្មលោក ហ៊ឹម ហន គឺដើមបណ្ដឹងដែលមានរហស្សនាម 2-TCCP-247។ ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ មានវត្តមាននៅបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ ជាដំបូងអង្គជំនុំជម្រះ សម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៥ ដែលបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃមុខឱ្យមានប្រសិទ្ធភាព ខ្លួនសូមលះបង់សិទ្ធិ និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការ នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៥។ មេធាវីការពារក្ដីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់ នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះ មិនអាចបកស្រាយថាជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្ដីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះ គ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

[០៩:០៥:៤២]

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៥ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់លោក នួន ជា មានអាការៈឈឺចង្កេះជាប្រចាំ អង្គុយមិនបានយូរ និងបានផ្ដល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឱ្យ នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងតាមបញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឱ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឱ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទនួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅក្រោមសាលសវនាការ

នេះក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ជាបន្តនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅដល់ក្រុមមេធាវីការពារក្តីដែលមានពេលវេលាពីរវគ្គ ដើម្បីតាំងសំណួរទៅសាក្សីរូបនេះ។ ជាដំបូង អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី លោក នួន ជា។

សូមអញ្ជើញលោកមេធាវី កូប៉េ!

[០៩:០៦:២៥]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម។ ជម្រាបសួរសហការី។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំមានសំណួរមួយចំនួនដែលត្រូវសួរលោកនៅក្នុងថ្ងៃនេះ។ ដំបូង ខ្ញុំសូមសួរអំពីតួនាទីរបស់លោកនៅក្នុងកងពល៣១០។ ខ្ញុំបានកត់សម្គាល់ឃើញថា លោកបានផ្តល់សក្ខីកម្មកាលពីម្សិលមិញនេះ ថាលោកធ្លាប់ធ្វើជាស្មៀនទទួលខុសត្រូវខាងផ្នែកប្រវត្តិរូប។ ហើយខ្ញុំក៏កត់សម្គាល់ឃើញនូវចម្លើយឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ថាលោកធ្លាប់ធ្វើជាមេបញ្ជាការម្នាក់នៅក្នុងកងពល៣១០។ ហើយលោកនេះក៏ជាកងទ័ពម្នាក់នៅក្នុងកងវរសេនាធំមួយដែរ។ តើការដែលខ្ញុំរៀបរាប់អំពីតួនាទីរបស់លោកនៅក្នុងកងពល៣១០នេះ វាត្រឹមត្រូវដែរឬក៏អត់ទេ?

**លោក ហ៊ីម ហាន៖**

**ឆ៖** បាទ ត្រឹមត្រូវហើយ។ តែតួនាទីរបស់ខ្ញុំ មិនបានដល់ទៅថ្នាក់ដឹកនាំនៅក្នុងវរសេនាធំ១២នោះទេ គ្រាន់តែជាបុគ្គលិកនៅក្នុងមន្ទីរវរសេនាធំប៉ុណ្ណោះ។

**ស៖** ហើយនៅពេលដែលលោកធ្វើជាបញ្ជាការ លោកមានតួនាទីដឹកនាំអ្វីទេ? តើលោកមានគ្រប់គ្រងទៅលើយុទ្ធជនដែរឬទេ?

[០៩:០៨:២០]

**ឆ៖** ការងារគ្រប់គ្រងយុទ្ធជននៅក្នុងវរសេនាធំ១២នេះ គឺខ្ញុំមិនមានសិទ្ធិអីទេ បានគ្រាន់តែដឹកនាំពាំនាំពាក្យ ឬក៏មេបញ្ជាហើយ យកមកផ្សព្វផ្សាយប៉ុណ្ណោះ។

**ស៖** តើវាត្រឹមត្រូវដែរឬទេ បើខ្ញុំនិយាយថា តួនាទីនេះគឺថាលោកមានការយល់ឃើញបានល្អ

ត្រូតពិនិត្យបានល្អអំពីសកម្មភាពនៅក្នុងកងពល៣១០ បញ្ហាទាំងឡាយណាដែលដាក់ចេញពីកងពល៣១០? តើលោកមានទស្សនៈយល់ឃើញបានល្អត្រឹមត្រូវ នៅក្នុងកងពល៣១០? បើខ្ញុំយល់ថាអ៊ីចឹង តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ប្រសាសន៍ហ្នឹង ត្រឹមត្រូវហើយ។ តែសិទ្ធិរបស់ខ្ញុំមិនបានដល់ជាអ្នកបញ្ជា ឬក៏គ្រប់គ្រងនៅលើវរសេនាធំ១២នោះ មិនមានទេ។

**សៈ** បាទ ខ្ញុំយល់ហើយ។ ទាក់ទងទៅនឹងតួនាទីរបស់លោក តើលោកអាចយល់ អាចក្ដោបក្ដាប់អំពីសកម្មភាពរបស់កងពលដទៃទៀត ដូចជាកងពល៤៥០ កងពល៩២០ជាដើម? តើលោកមានបានកត់សម្គាល់ថា កងពលទាំងពីរនេះធ្វើអ្វីខ្លះដែរទេ ចន្លោះពីឆ្នាំ៧៥ ដល់៧៦?

**ឆ៖** កងពលទាំងពីរហ្នឹងខ្ញុំអត់ដឹងទេ។ ដឹងតែគេទៅឈរឯណា ឬក៏ទៅបំពេញភារកិច្ចនៅឯណាទៀត ខ្ញុំអត់ដឹងទេ។

**សៈ** តើលោកដឹងថា មានទំនាក់ទំនងរវាងកងពល៣១០ និងកងពល៤៥០ ដែរទេ?

**ឆ៖** ខ្ញុំមិនបានដឹងទេ។

[០៩:១១:០០]

**សៈ** តើលោកធ្លាប់ស្គាល់កងពល៩២០ដែរទេ?

**ឆ៖** អត់ស្គាល់ទេ។

**សៈ** កាលពីម្សិលមិញលោកបានឆ្លើយជូនអង្គជំនុំជម្រះថា នៅក្នុងខែកញ្ញា ចិតសិប -- នៅក្នុងខែវិច្ឆិកា ៧៥ ពេលនោះអគ្គសេនាធិការក៏ត្រូវបានបង្កើត នៅពេលនុំងគឺថា កងទ័ពពីភូមិភាគនានាត្រូវបានប្រគល់ជូនទៅអគ្គសេនាធិការ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាន ត្រឹមត្រូវហើយ។

**សៈ** តើលោកអាចជម្រាបជូនអង្គជំនុំជម្រះថា កងពលនីមួយៗគេប្រគល់កងទ័ពប៉ុន្មានទៅឲ្យមជ្ឈិម? ហើយនិងទុកប៉ុន្មានសម្រាប់ភូមិភាគរបស់ខ្លួន?

**ឆ៖** ត្រង់ហ្នឹងខ្ញុំក្ដាប់អត់បានទេ។ មិនដឹងថាក្នុងភូមិភាគមួយៗ គេប្រគល់ជូនសេនាធិការប៉ុន្មាន អត់ដឹង។ ហើយនៅសល់ប៉ុន្មាន គឺអត់ដឹងដែរ។

**សៈ** តើលោកអាចផ្ដល់តួលេខស្មានៗមកថា តួលេខប៉ាន់ប្រមាណត្រួសៗមើល៍ តើកងទ័ពពីកងពលនីមួយៗហ្នឹង គឺត្រូវគេប្រគល់ជូនទៅមជ្ឈិមហ្នឹងប៉ុន្មាននាក់ដែរ?

**ឆ៖** តាមការខ្ញុំឃើញ គឺមិនបានជាមានមុខកងទ័ពទាំងអស់នោះទេ គឺមានតែក្រដាសស្នាម ប៉ុណ្ណោះដែលឃើញដាក់លើតុគណៈអធិបតី។ ដឹងជាភូមិភាគមួយៗមានប៉ុន្មាននាក់ កងពលមួយៗមាន ប៉ុន្មានអី ខ្ញុំភ្លាប់អត់បាន។

[០៩:១៣:៣៧]

**ស៖** ខ្ញុំយល់ហើយ។ លោកបានឆ្លើយប្រាប់អ្នកសម្ភាសពីមជ្ឈមណ្ឌលឯកសារកម្ពុជា លោកក៏ បានឆ្លើយម្តងហើយម្តងទៀតដែរនៅក្នុងពេលផ្តល់សក្ខីកម្ម ថារូបលោកផ្ទាល់ និងអង្គភាពរបស់លោក ត្រូវបានគេចាត់ទុកថាជាជនក្បត់។ ក៏ប៉ុន្តែលោកមិនបានដឹងអំពីសកម្មភាពរបស់អ្នកពួកក្បត់ ដែល លោកត្រូវបានចោទប្រកាន់នោះទេ។ តើលោកនៅតែប្រកាន់ចម្លើយរបស់លោកថាយ៉ាងដូច្នេះ ឬក៏យ៉ាង ណាដែរ?

**ឆ៖** បាទ ខ្ញុំនៅតែប្រកាន់ពាក្យខ្ញុំដដែលថា ខ្ញុំអត់ដឹងថា ខ្ញុំត្រូវមានចិត្តក្បត់ និងដោយប្រការ ណាមួយ គឺអត់ដឹង។

**ស៖** ពីម្សិលមិញ និងពីម្សិលម៉្ងៃ ខ្ញុំបានស្តាប់ឮចម្លើយ លោកគេបានប្រាប់អំពីចម្លើយរបស់ គាត់។ សាក្សីម្នាក់មកពីកងពល៣១០ដែរ ហើយគាត់បានផ្តល់សក្ខីកម្មលម្អិតមែនទែន ពាក់ព័ន្ធទៅនឹង ផែនការអំពីមេបញ្ជាការកងពលម្នាក់ឈ្មោះ អឿន។ គាត់និយាយអំពីការដឹកជញ្ជូនចល័តអាវុធយកទៅ លាក់ទុកដើម្បីរៀបផែនការធ្វើរដ្ឋប្រហារ វាយប្រយុទ្ធព្រលានយន្តហោះពោធិ៍ចិនតុង និងវាយប្រយុទ្ធ ស្ថានីយ៍វិទ្យុផ្សាយសំឡេងទីក្រុងភ្នំពេញ គឺជាផែនការមួយដែលធ្វើរៀបត្រៀមធ្វើរដ្ឋប្រហារ ដឹកនាំដោយ កុយ ធួន នៅដើមឆ្នាំ១៩៧៧។ នៅពេលដែលខ្ញុំរៀបរាប់សក្ខីកម្មរបស់សាក្សីរូបនេះ តើលោកនៅចាំអំពី សកម្មភាពនៃផែនការរបស់ អឿន ដែរទេ?

**ឆ៖** ការងារនោះខ្ញុំអត់ដឹង។ អត់ដែលបានទទួលផែនការអីទេ។

**ស៖** ខ្ញុំយល់ហើយ ប៉ុន្តែតើលោកធ្លាប់ឮអំពីផែនការបះបោរ ឬក៏រដ្ឋប្រហារ ឬក៏ជាផែនការអ្វី មួយដែលលោកអាចហៅឈ្មោះវាយ៉ាងណាទៅតាមការលោកយល់ តើលោកធ្លាប់ឮទេ?

[០៩:១៦:២២]

**ឆ៖** ទាល់តែទៅដល់ ទៅធ្វើវាលវង់កំពង់ឆ្នាំងហើយ បានដឹងថា មានសកម្មភាពហ្នឹងលេចឮ តែខ្ញុំអត់ឃើញនឹងភ្នែក ឬក៏បានចូលរួមប្រជុំ គឺខ្ញុំអត់ដែលបាន។

**ស៖** តើលោកបានឮអ្វីពិតប្រាកដ?

**ឆ៖** ឮថាភូមិភាគឧត្តរក្បត់ និងបូព៌ាក្បត់ តែប៉ុណ្ណោះឯង។ តែសកម្មភាពផ្សេងៗទៀត ខ្ញុំអត់ដឹង។

**ស៖** មានសក្ខីកម្មជាច្រើនទៀត ពាក់ព័ន្ធទៅនឹង -- យើងក៏បានស្ដាប់ឮសក្ខីកម្មពីយុទ្ធជនម្នាក់មកពីកងពល៣១០ កាលពីម្សិលមិញដែរ។ ហើយខ្ញុំសូមអានឲ្យលោកស្ដាប់ ក្រែងលោថាអាចជួយរំឭកដល់ការចងចាំរបស់លោក។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន យើងខ្ញុំស្នើសុំ -- យើងខ្ញុំបានដាក់ឯកសារមជ្ឈមណ្ឌល -- ERN ជាភាសាអង់គ្លេសគឺ ឯកសារ ERN គឺអង់គ្លេស 00337712, ខ្មែរ 00055077, បារាំង 0036274 (*ស៊ីក*) គឺឯកសារ E3/504។ កម្មាភិបាលមកពីកងពលផ្ដល់សក្ខីកម្មដូចតទៅ៖ “បាទ គឺថាវាបានផែនការហ្នឹងកើតឡើងនៅឆ្នាំ១៩៧៦ ខ្ញុំមិនចាំខែទេ ខ្ញុំភ្លេចខែ។ នៅចុងឆ្នាំ១៩៧៦ គឺថាយើងគឺថាមានផែនការបះបោរមួយ ក៏ប៉ុន្តែត្រូវបានបែកធ្លាយទៅ។ គឺចាប់ផ្ដើមធ្វើខាងឧត្តរចាប់ផ្ដើមពីវត្តភ្នំទៅជើង ហើយខាងភូមិភាគបូព៌ាខាងកើត ប៉ុន្តែត្រូវបែកការណ៍។ ហើយក្រោម អឿន មេបញ្ជាការកងពលហ្នឹងក៏ត្រូវបានចាប់ខ្លួន។” នៅពេលដែលខ្ញុំសួរតទល់ជាមួយលោកអំពីបញ្ហានេះ គឺយុទ្ធជនម្នាក់មកពីឯកសារ D310 គឺឯកសារ 19.93 គឺ E3/19.3 និងអង់គ្លេស ERN 00--

**អ្នកបកប្រែ៖**

លោកប្រធានសូមការអនុញ្ញាតឲ្យមេធាវី -- លឿនពេក លោកប្រធានតាមអត់ទាន់។

**ប្រធានអង្គជំនុំ៖**

សូមលោកមេធាវីបន្ថយល្បឿនបន្តិចបាទ!

[០៩:១៩:៤១]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** បាទ ខ្ញុំសូមអធ្យាស្រ័យ។ គឺ ERN ភាសាខ្មែរគឺ 00087816, បារាំង 00324206 គឺឯកសារ E3/7535 និងឯកសារ 19.93។ សក្ខីកម្មរបស់ អឿន ដែលបានឆ្លើយដូចតទៅ៖ “នៅពេលនោះ គឺថាគាត់ជាប់ទាក់ទងជាមួយឃួន ចង់បះបោរនៅទីក្រុងភ្នំពេញ។ សួរ៖ តើគាត់មានផែនការធ្វើរដ្ឋប្រហារដែរឬទេ? ឆ្លើយ៖ គាត់រៀបចំផែនការធ្វើរដ្ឋប្រហារ ក៏ប៉ុន្តែនៅពេល ដោយសារគេនេះទៅគេបែកការណ៍ទៅ គេក៏បញ្ជូនទៅឲ្យធ្វើស្រែមួយរយៈ។ សួរ៖ តើលោកអាចរៀបរាប់អំពីផែនការរបស់

តាអឿន ធ្វើរដ្ឋប្រហារនេះបានទេ? ទី១ គឺគាត់ហៅយើងទៅប្រជុំស្ងាត់ៗ ហើយនិងរៀបចំផែនការដើម្បីវាយប្រហារមកលើទីក្រុងភ្នំពេញ។ គាត់ប្តេជ្ញាថានឹងរំដោះ ហើយនិងគ្រប់គ្រងទីក្រុងភ្នំពេញឲ្យបាន។ សួរ៖ ហេតុអ្វីបានជាគាត់រៀបចំផែនការធ្វើរដ្ឋប្រហារទម្លាក់ ប៉ុល ពត? ឆ្លើយ៖ គាត់ថាសង្គមនេះមិនល្អទេ។ សួរ៖ តើ តាអឿន មានបើកប្រជុំជាមួយនឹងកម្លាំងគាត់មុនៗដែរទេ? ឆ្លើយ៖ បាទ មាន។ គឺថាមានតែយុទ្ធជន១00នាក់ទេ គឺរួមទាំងខ្ញុំផង ត្រូវបានហៅទៅប្រជុំជាមួយគាត់។ សួរ៖ តើលោកបានចូលរួមជាមួយអ្នកទាំងនោះទេ? ឆ្លើយ៖ ខ្ញុំដឹកអាវុធពេញៗមកជួបគាត់នៅទីក្រុងភ្នំពេញ ដើម្បីរៀបចំវាយប្រយុទ្ធទីក្រុងភ្នំពេញ ក៏ប៉ុន្តែជាអកុសលគឺផែនការរដ្ឋប្រហារនេះក៏ត្រូវបែកធ្លាយទៅ។"

ហើយមកខាងក្រោមបន្តិច គឺឯកសារ ឌី.ស៊ី.ខេម ដដែល ERN អង់គ្លេស 00324172, ខ្មែរ 00087818 ដល់ 89 ហើយបារាំង 00324211។ កម្មាភិបាលដដែលនេះបានឆ្លើយដូចតទៅ៖ "សួរ៖ អ្នកណាជាមេរបស់ តាអឿន? ឆ្លើយ៖ ខ្ញុំមិនដឹងទេ។ សួរ៖ យោងទៅតាមផែនការដែលរៀបនោះ តើកម្លាំងទាំងនេះអាចយកជ័យជម្នះលើ ប៉ុល ពត បានទេ? ឆ្លើយ៖ វាមិនមែនជារឿងងាយស្រួលទេ ខ្ញុំគិត។ បើសិនយើងមិនអាចទម្លាក់ ប៉ុល ពត យកឈ្នះ ប៉ុល ពត បានទេយើងនឹងសុំអំពាវនាវទៅវៀតណាម ហើយសុំឲ្យហៅកងទ័ពពីបូព៌ាដឹកនាំដោយ ចក្រី ឲ្យមកជួយ។ តើនេះគឺជាអ្វីដែល តាអឿន ប្រាប់ឬ? ឆ្លើយ៖ បាទ។ ដូច្នេះមានន័យថាកម្លាំងរបស់ តាអឿន គឺពឹងពាក់ទៅលើកម្លាំងមកពីបូព៌ាដែរ អ៊ីចឹងមែនទេ? ឆ្លើយ៖ បាទ។ ប៉ុន្តែ តាអឿន គឺជាអ្នកដឹកនាំកម្លាំងនៅទីក្រុងភ្នំពេញ អ៊ីចឹងមែនទេ? ឆ្លើយ៖ បាទ។ សួរ៖ តើកម្លាំងនេះអាចប្រឈមមុខជាមួយកម្លាំង ប៉ុល ពត បានទេ? ឆ្លើយ៖ ខ្ញុំគិតអ៊ីចឹងពីព្រោះកម្លាំងរបស់ ប៉ុល ពត ត្រូវបានដកអាវុធ ហើយកាំភ្លើងទាំងអស់ គេដាក់ចូលទៅក្នុងឃ្លាំង។" លោកសាក្សី ខ្ញុំបានអានចម្លើយរបស់កម្មាភិបាលពីរនាក់មកពីកងពលរបស់លោកនេះ ខ្ញុំបានសង្ខេបសក្ខីកម្មរបស់កម្មាភិបាលម្នាក់អំមិញ ដែលបានឆ្លើយជូនតុលាការកាលពីថ្ងៃមុននេះ។ តើការដែលរៀបរាប់ប៉ុននេះអាចជួយរំឭកដល់ការចងចាំរបស់លោក អំពីផែនការបះបោរវាយប្រយុទ្ធនៅព្រលានយន្តហោះពោធិ៍ចិនតុង និងវិទ្យុផ្សាយសំឡេងទីក្រុងភ្នំពេញដែរឬទេ?

[០៩:២៤:00]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយ!

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ សូមអរគុណលោកប្រធាន។ បាទ ជាបឋមខ្ញុំគិតថា ប្រហែលជាមានប្រយោជន៍ជាង សម្រាប់សាក្សីនោះ ប្រាប់ឈ្មោះគាត់ តើអ្នកណាអ្នកឆ្លើយយ៉ាងដូច្នេះ ហើយនិងតួនាទីអ្នកដែលឆ្លើយ ព្រោះថាមិនជាការសមស្របទេ គ្រាន់តែនិយាយថា គាត់នោះជាកម្មាភិបាលនៃកងពល៣១០នោះ។ គាត់មិនអាចនឹកឃើញបានទេ។ សាក្សីហ្នឹងគាត់បានប្រាប់ហើយនៅទីនេះ គាត់ថាគាត់មិនដឹងអ្វីទាំងអស់។ អ៊ីចឹងសំណួរដែលមេធាវីសួរថា ក្រោយពីខ្លួនឯងសព្វហើយហ្នឹង សួរថានឹកឃើញដែរឬទេនោះ ខ្ញុំគិតថាមិនសមស្របទេ មិនបាច់ប្រាប់អ្វីគាត់ទាំងអស់។ គាត់មិនដែលនិយាយជម្រាបជូនតុលាការ អំពីរឿងហេតុជាក់លាក់ទាក់ទងនឹងការរៀបចំផែនការក្បត់នេះទេ។ អ៊ីចឹងខ្ញុំគិតថាគួរតែប្រាប់មុខងារ ហើយឈ្មោះកម្មាភិបាលហ្នឹងឲ្យបានច្បាស់លាស់ឲ្យគាត់។

**លោក វិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំគិតថាខ្ញុំមានសិទ្ធិសួរសំណួរនេះ។ ខ្ញុំសំណួរបើកទេដំបូង ប៉ុន្តែគាត់សាក្សីបានឆ្លើយថា គាត់មិនបានដឹងអ្វីនោះទេ ដែលមេធាវីការពារក្ដីជឿថាមិនគួរឲ្យជឿជាក់បានទេ។ ហើយក្រោយមកខ្ញុំសួរតទល់ជាមួយគាត់ ដោយលើកយកសក្ខីកម្មរបស់សាក្សីបីនាក់ យុទ្ធជនបីនាក់។ ខ្ញុំអាចផ្ដល់ឈ្មោះរបស់យុទ្ធទាំងបីនេះគឺ ទី១ មកពីវរសេនាធំលេខ១២។ ខ្ញុំគិតថានេះគឺជាការតាំងសំណួរ និងជាវិធីសាស្ត្រមួយដែលត្រឹមត្រូវក្នុងការតាំងសំណួរហើយ។ ដូច្នេះការសួរបែបនេះ ខ្ញុំយល់ឃើញថាគួរត្រូវបានអនុញ្ញាតឲ្យខ្ញុំសួរ។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:២៧:២៧]

**ប្រធានអង្គជំនុំ៖**

សូមជម្រាបទៅលោកមេធាវី សំណួរនេះអាចលោកសួរបាន តែលោកត្រូវសួរ សូមលោកប្រាប់ឈ្មោះសាក្សីនោះ ហើយនិងឋានន្តរសក្ដិសាក្សីនោះប្រាប់ទៅសាក្សីនេះ។

**លោក វិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំរីករាយនឹងធ្វើតាមការបង្គាប់របស់អង្គជំនុំជម្រះ។ ប៉ុន្តែវាមាន គឺថាយើងអាចកោះហៅសាក្សីពីរនេះមកសួរអំពីការបះបោរផ្ទៃក្នុង ការពិចារណាទៅលើចំណុចនេះ ការផ្ដល់ឯកសារជាភាសាខ្មែរទៅឲ្យសាក្សីនេះមើល ខ្ញុំគិតឃើញថាគឺជាការសមរម្យ ជាការសមស្របជាងលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អនុញ្ញាតឲ្យបង្ហាញឯកសារសាក្សីនេះជាភាសាខ្មែរទៅសាក្សី។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ លោកប្រធាន ខ្ញុំនឹងសរសេរនៅលើក្រដាស ហើយឲ្យទៅសាក្សីមើលបន្តិចទៀតនេះ។

*(សម្រាករយៈពេលខ្លី)*

យើងខ្ញុំកំពុងតែរៀបចំការតាំងសំណួរនេះ ហើយដូច្នេះកំពុងតែរៀបចំឈ្មោះទៅឲ្យ។ សូមរយៈពេលតែបន្តិចទេ។

*(សម្រាករយៈពេលខ្លី)*

[០៩:២៩:៥៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទសូមអរគុណលោកប្រធាន។ ពេលដែលកំពុងរង់ចាំឲ្យលោកមេធាវី កូប៉េ រកឃើញឯកសារនោះ គឺថាកិច្ចសម្ភាសន៍ទី១ នោះគឺជាមនុស្សដែលមានអាយុ២០នៅឆ្នាំ១៩៧៥ ហើយមនុស្សម្នាក់ទៀតគឺមានអាយុ១៥ឆ្នាំនៅក្នុងឆ្នាំ១៩៧៥ដែរ។ គាត់ លោកមេធាវី កូប៉េ និយាយអំពីកម្មាភិបាលហ្នឹង អ៊ីចឹងត្រូវគាត់ឲ្យឋានន្តរសក្តិមក ហើយអាយុគាត់អាយុប៉ុន្មានដែរ ព្រោះថាកាលណាមានឋានន្តរសក្តិទាល់តែមានអាយុច្រើនដែរ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនយល់ថា ការធ្វើបែបនេះមានសារៈប្រយោជន៍អីទេ។ សាក្សីទាំងនេះជាកម្មាភិបាល។ ខ្ញុំថាយើងគួរគ្រាន់តែសរសេរឈ្មោះទៅឲ្យគាត់មើល ឬក៏អានឈ្មោះគាត់ ឈ្មោះសាក្សីតែម្តងក៏បានដែរ ពាក់ព័ន្ធនឹងអាយុ វាមិនចាំបាច់អីទេ។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៣១:៣៨]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី សូមលោកបង្ហាញតែអាយុ និងឋានន្តរសក្តិ ហើយឲ្យសាក្សីនោះអាន ដោយមិន

បាច់និយាយ។

**លោក វ៉ិចទ័រ កូប៉េះ**

លោកប្រធាន កម្មាភិបាលម្នាក់គឺៗកើតនៅឆ្នាំមួយពាន់ប្រាំបួនរយ -- ខ្ញុំៗមិនដឹងថាគាត់មានឋានន្តរសក្តិអ្វីទេ គ្រាន់តែថាជាយុវជនម្នាក់។ ត្រង់អង់គ្លេសជាគឺ ERN 00324180។

**ចៅក្រម ក្លូឌា ហ្វេនស័ះ**

ហើយយើងសួរអាយុគាត់ដែរ អាយុគាត់ប៉ុន្មាន?

**លោក វ៉ិចទ័រ កូប៉េះ**

គឺគាត់អាយុ៤៥ឆ្នាំនៅពេលដែលគាត់ផ្តល់ចម្លើយនៅឆ្នាំ២០០៥។ អ៊ីចឹងគាត់កើតនៅឆ្នាំ១៩៦០ បាទ កើតនៅឆ្នាំ១៩៦០។ កម្មាភិបាលម្នាក់ទៀត កើតនៅ--

**ប្រធានអង្គជំនុំះ**

សូមអញ្ជើញលោកចៅក្រម ឡាវែន៍!

[០៩:៣៣:៣៤]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ះ**

បើសិនយើងនិយាយអំពីបុគ្គលម្នាក់ដែលទាក់ទងទៅនឹងឯកសារ 19.13 អ៊ីចឹងលោកចង់និយាយពីមនុស្សម្នាក់ដែលស្ថិតនៅក្នុងឯកសារ 19.93 ឬក៏យ៉ាងម៉េច? ដែលមាននៅក្នុងឧបសម្ព័ន្ធហ្នឹងមានប្រវត្តិរូប។ អ៊ីចឹងលោកចង់និយាយពីបុគ្គលម្នាក់ដែលមាននៅក្នុងឯកសារ 19.93 ហ្នឹង ឬក៏យ៉ាងណា?

**លោក វ៉ិចទ័រ កូប៉េះ**

បាទ ត្រឹមត្រូវហើយគឺនៅក្នុងឯកសារ 19.93។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ះ**

អ៊ីចឹងខ្ញុំឃើញថា ប្រវត្តិរូបដែលនៅក្នុងឧបសម្ព័ន្ធហ្នឹង គឺនិយាយថាបុគ្គលរូបនេះកើតនៅឆ្នាំ១៩៥៥ ហើយគាត់ជាសមាជិកនៃក្រុមអនុសេនាតូច១។

**លោក វ៉ិចទ័រ កូប៉េះ**

បាទ អនុសេនាតូច១ ប៉ុន្តែកងអនុសេនាតូចនេះគឺជាអនុសេនាតូចចំណុះឲ្យកងវរសេនាធំ១២ លេខ១២។ យើងមិនដែលនិយាយគ្នាពីអាយុរបស់យុទ្ធជនទេពីមុននោះ។

[០៩:៣៤:៤៩]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកមេធាវី កាលណាគេសុំឋានន្តរសក្តិគាត់ហ្នឹង គឺថាវាមានភាពពាក់ព័ន្ធ ព្រោះយើងចង់ដឹងថាតើបុគ្គលរូបហ្នឹង ពេលគាត់ផ្តល់ចម្លើយហ្នឹង កាលនៅសម័យខ្មែរក្រហមនោះគាត់មានកម្រិតយល់ដឹងប៉ុនណាដែរ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្សាឯល៖**

សូមអរគុណ។ ខ្ញុំមិនចង់កាត់ផ្តាច់ទេ នៅក្នុង*អ៊ីនធើហ្វេស*ឯកសារដែលយើងមាន គឺឯកសារ IS 19.193 មិនមែនឯកសារ 19.93 ទេ។ ខ្ញុំមិនដឹងថា យើងនិយាយពីឯកសារដដែលហ្នឹងទេ ក៏ប៉ុន្តែនៅក្នុងឯកសារហ្នឹង គឺៗថាគាត់កើតនៅឆ្នាំ១៩៤៥មែន។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំៗសូមសួរសំណួរផ្សេងទៅចុះ ពីព្រោះខ្ញុំមិនចង់តតាំងវែងឆ្ងាយរឿងនេះទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី តើលោកនៅចាំផែនការវាយប្រហារព្រលានយន្តហោះពោធិ៍ចិនតុង វិទ្យុផ្សាយសំឡេងទីក្រុងភ្នំពេញ ដែលដឹកនាំធ្វើរដ្ឋប្រហារដោយ អឿន និង កុយ ធួន ដែរឬទេ?

[០៩:៣៦:១៦]

**លោក ហ៊ឹម ហន៖**

**ឆ៖** ខ្ញុំអត់ដឹងទេ។

**ស៖** បាទ ខ្ញុំសូមចូលទៅចំណុចមួយផ្សេងទៀត ដែលលោកបាននិយាយរួចមកហើយ។ លោកបានឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ថានៅពេលមួយនោះ ដោយសារតែការចោទប្រកាន់អំពីសកម្មភាពក្បត់ លោកក៏បានប្តូរឈ្មោះរបស់លោក។ តើសូមលោកជម្រាបជូនអង្គជំនុំជម្រះថា តើលោកអាចប្តូរឈ្មោះលោកបានដោយរបៀបណាដែរ ក្រោយពីរកឃើញអំពីផែនការធ្វើរដ្ឋប្រហារ ឬក៏សកម្ម-ភាពក្បត់នេះ ហើយក្រោយមក លោកក៏បន្តធ្វើការងារដោយប្រើឈ្មោះផ្សេង? តើលោកអាចប្តូរឈ្មោះបានដោយរបៀបណា?

**ឆ៖** ពេលខ្ញុំទៅដល់កំពង់ឆ្នាំង វាលរវង់កំពង់ឆ្នាំង គេចាប់ផ្តើមធ្វើប្រវត្តិរូបសាថ្មី។ ត្រង់ហ្នឹង

ហើយដែលខ្ញុំផ្លៀតឱកាសដាក់ថាឈ្មោះ រាម ។

**ស៖** ខ្ញុំដឹងហើយថាលោកបានប្ដូរឈ្មោះរបស់លោក ប៉ុន្តែខ្ញុំសួរថា តើលោកអាចប្ដូរបានដោយរបៀបណា? នៅពេលហ្នឹង គឺថាតើលោកអាចប្ដូរឈ្មោះបានដោយងាយៗបែបនេះ ដោយខាងកងពលនុ៎ង គឺមិនអាចដឹងថា លោកប្ដូរឈ្មោះ ឬក៏យ៉ាងម៉េច?

**ឆ៖** ខ្ញុំទៅដល់វាលវង់ហើយ គឺដាច់អំពីកងពលអស់ហើយ។ អ៊ីចឹងនៅសល់តែគ្នាខ្ញុំដែលត្រូវគេចម្រាញ់ចេញតែប៉ុណ្ណឹង ហើយបំបែកគ្នាថែមទៀត មិនមាននៅជុំគ្នាទេ។

[០៩:៣៨:២៦]

**ស៖** លោកមិនទាន់ឆ្លើយសំណួរខ្ញុំនៅឡើយទេ។ តើលោកមានតួនាទីនៅក្នុងកងពល៣១០ គឺលោកទើបតែឆ្លើយ -- យើងទើបពិភាក្សាគ្នាអម្បាញ់មិញ ហើយក្រោយមកលោកឮអំពីសកម្មភាពក្បត់ ហើយលោកក៏បានប្ដូរឈ្មោះរបស់លោក។ លោកចូលរួមប្រយុទ្ធជាមួយកងពល៣១០អស់ជាច្រើនឆ្នាំ។ តើលោកអាចប្ដូរឈ្មោះរបស់លោកដោយងាយៗបានដោយរបៀបណា ដើម្បីលាក់ប្រវត្តិរូបរបស់លោកដោយរបៀបណានោះ?

**ឆ៖** ក្រោយពេលពួកនិរតីចូលមកហ្នឹង គឺគេមិនទាន់ស្គាល់ខ្ញុំទេ។ ហើយគេសួររក ខ្ញុំមើលឃើញទៅ ក៏ខ្ញុំថែមឈ្មោះ រាម ហ្នឹងដូរ រាម ហ្នឹងតែម្ដង។ ហើយអ្នកដែលមកយកនោះ គឺខ្ញុំឃើញថាអ្នកនេះអត់ស្គាល់ចេះអក្សរទេ អ៊ីចឹងខ្ញុំដូរឲ្យហើយ។

**ស៖** ដូច្នេះមេបញ្ជាការថ្មីកងពល៣១០ គឺមិនចេះអាន មិនចេះសរសេរទេ។ អ៊ីចឹងមែនទេ?

**ប្រធានអង្គជំនុំ៖**

មេធាវី -- សាក្សីចាំភ្លើងបង្ហាញចាំមានប្រសាសន៍។

**លោក ហ៊ីម ហាន៖**

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

សូមសាក្សីឆ្លើយនៅពេលដែលក្បាលមីក្រូហ្វូនប្រតិបត្តិការចេញភ្លើងក្រហម។

[០៩:៤០:៥០]

**លោក ហ៊ីម ហាន៖**

**ឆ៖** នៅពេលដែលពួកនិរតីមកគ្រប់គ្រងនៅវរសេនាធំ១២នេះ គឺខ្ញុំក្ដាប់បានថា អ្នកទាំងនោះ

មិនសូវចេះអក្សរទេ ពីព្រោះខ្ញុំអានខុសក៏គេអត់ដឹង អានត្រូវក៏គេអត់ដឹង។ អាត្រង់ហ្នឹងហើយ ដែលខ្ញុំត្រូវកែឈ្មោះខ្ញុំថាមកឈ្មោះ រាម វិញបាន។ ហើយបន្ទាប់មកទៀត ខ្ញុំក៏ត្រូវគេដកចេញពីកន្លែងនោះផុតអស់មក មិនដឹងជាសកម្មភាពម៉េចៗទៀត ខ្ញុំអត់ដឹង។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** ដូច្នេះចម្លើយរបស់គឺថា មេបញ្ជាការកងវរសេនាធំ និងមេបញ្ជាការកងពលថ្មីនេះ គឺថាមិនចេះអាន មិនចេះសរសេរទេ។ ហេតុដូច្នេះឯងបានជាលោកគិតថា នៅពេលនេះគឺថាលោកត្រូវតែប្តូរឈ្មោះរបស់លោក។ អ៊ីចឹងមែនទេ?

**ឆ៖** បាទៗ ត្រូវហើយ។

**ស៖** លោកសាក្សី ឥឡូវនេះខ្ញុំចូលទៅនិយាយអំពីការងាររបស់លោកនៅព្រលានយន្តហោះកំពង់ឆ្នាំង។ លោកបាននិយាយអំពីការបំបែកថ្ម គឺថាមានរបួសច្រើន ដោយសារតែការងារបំបែកថ្មនៅកំពង់ឆ្នាំង។ តើលោកចាំទេ តើកម្លាំងមកពីខាងណា ដែលត្រូវធ្វើការងារក្នុងការបំផ្ទុះបំបែកថ្មនេះ? តើកងអង្គភាពនរណាដែលជាអ្នកប្រើប្រាសគ្រឿងបំផ្ទុះដើម្បីបំបែកថ្មនេះ?

**ឆ៖** កម្លាំងមកពីបូព៌ា។

[០៩:៤២:៥០]

**ស៖** ថាតើលោកដឹងថាកម្លាំងហ្នឹងមកពីបូព៌ាបានមករបៀបណា?

**ឆ៖** កម្លាំងហ្នឹងវាគេចែក មិនមានឲ្យនៅជិតគ្នាទេ។ មួយនៅខាងត្បូងព្រលាន មួយទៀតនៅខាងជើង តែចុងវាលសានព្រលានយន្តហោះឯណោះ។ ពេលដែលដឹងថា បូព៌ានោះគឺ អ្នកទាំងឡាយនោះនិយាយខុសគ្នា និយាយខុសពីភូមិភាគឧត្តរ។ ស្តាប់ភាសាបាន អូ! អ្នកនេះនៅភូមិភាគបូព៌ា។ ហើយអ្នកគ្រប់គ្រងហ្នឹង គឺនិយាយខុសពីបូព៌ាទៀត កំណត់ថាអ្នកនេះមកពីភូមិភាគនិរតី។ ហើយខ្ញុំនៅភូមិភាគកណ្តាល ឬហៅថាភូមិភាគឧត្តរនោះ គឺនៅខាងជើងវាលរង់យន្តហោះ តែឆៀងខាងកើត។ ហើយចល័តធ្វើការនៅកន្លែងនោះ ទើបដឹងថាខាងនេះអង្គភាពភូមិភាគបូព៌ា ខាងនេះខាងនិរតី។

**ស៖** តើលោកដឹងថា មូលហេតុអ្វីបានជាកម្លាំងៗបូព៌ានោះត្រូវទុកចិត្ត ហើយឲ្យប្រើគ្រឿងបំផ្ទុះ ដើម្បីបំបែកថ្ម? គឺថាដឹងថាមូលហេតុអីទេ បានគេឲ្យកម្លាំងបូព៌ាប្រើប្រាស់គ្រឿងបំផ្ទុះដើម្បីបំបែកថ្ម?

**ឆ៖** គេប្រើឲ្យប្រើជាតិផ្ទុះបំបែកថ្ម មិនមែនប្រើឲ្យទៅលេងទេ គឺប្រើឲ្យទៅស្លាប់។ កាលណា

ផ្ទុះ រត់មិនទាន់ទេ អំបែងថ្មហ្នឹងខ្ទាតត្រូវងាប់ហើយ។ គឺស្លាប់សឹងតែរាល់ថ្ងៃតាមដំណឹងតៗគ្នាមក។

**ស៖** នេះមិនមានចម្លើយទៅនឹងរបស់សំណួរខ្ញុំទេ។ ខ្ញុំសួរ ថាតើហេតុអ្វីបានជាកងទ័ពមកពីបូព៌ាដែលធ្វើការនៅក្នុងព្រលានយន្តហោះកំពង់ឆ្នាំង ត្រូវបានគេទុកចិត្តឲ្យប្រើប្រាស់គ្រឿងបំផ្ទុះអ៊ីចឹង? ម៉េចបានជាអនុញ្ញាតឲ្យបំផ្ទុះថ្ម ឲ្យបំបែកថ្មដោយប្រើប្រាស់គ្រឿងផ្ទុះបែបនេះ?

**ឆ៖** នេះជាវិធីសម្លាប់មួយដែលមិនអាចប្រកែកបាន ហើយត្រូវតែធ្វើ។

**ស៖** ខ្ញុំមិនយល់ ហេតុអ្វីបានជាលោកថា វាជាវិធីសម្លាប់មនុស្សមួយ?

**ឆ៖** វិធីហ្នឹងដាក់ឆ្នួន គេហៅថាឆ្នួនហ្នឹងដាក់ខ្វួងថ្ម។ ខ្វួងថ្មហើយបញ្ចូលឆ្នួនទៅក្នុងហ្នឹង ហើយខ្សែបញ្ឆេះខ្លី។ អ្នកអុជមិនអាចរត់ផុតបានទេ ថ្មហ្នឹងផ្ទុះឡើងគឺអំបែងខ្ទាតត្រូវងាប់ហើយ ឬក៏របួសធ្ងន់។ ហើយវិធីនេះ ខ្ញុំមិនបានឃើញនឹងផ្ទាល់នឹងភ្នែកទេ។ ខ្ញុំឮតៗគ្នាមក។

[០៩:៤៦:៥៦]

**ស៖** លោកសាក្សី លោកធ្លាប់ធ្វើជាកងទ័ព លោកធ្លាប់ចូលរួមប្រយុទ្ធក្នុងសមរភូមិ។ ខ្ញុំដឹងថា លោកដឹងអំពីការ គោលបំណងនៃការប្រើប្រាស់គ្រឿងបំផ្ទុះ ឬក៏ប្រើប្រាស់ឆ្នួននេះ តើលោកយល់ថាម៉េចដែរ?

**ឆ៖** ខ្ញុំជម្រាបលោកម្តងហើយម្តងទៀតថា ឆ្នួននេះមិនងាយនឹងទៅដាក់ដោយងាយៗនោះទេ តែពេលនេះ កម្លាំងទាំងនេះ ស្លាប់ប៉ុន្មានក៏គេអត់ស្តាយដែរ។ អ៊ីចឹងការផ្ទុះក្តីអីក្តីហ្នឹង គឺកម្មវិធីធ្វើហ្នឹងវាទាន់ហាន់។ ខ្សែបញ្ឆេះខ្លី ថ្មផ្ទុះ ឆ្នួនផ្ទុះភ្លាមហ្នឹងអំបែងត្រូវធ្លាក់មកត្រូវមនុស្សហ្នឹងស្លាប់ ឬក៏របួសជាហូរហែមក។ ខ្ញុំ អានេះខ្ញុំមិនបានធ្វើផ្ទាល់ដែរទេ ប៉ុន្តែខ្ញុំគិតថាកម្មវិធីនេះ សកម្មភាពនេះ ដើម្បីសម្លាប់មនុស្សទេ។

**ស៖** ខ្ញុំខ្លាចក្រែងលោខ្ញុំមិនយល់ចម្លើយរបស់លោកទេ។ តើគ្រឿងបំផ្ទុះហ្នឹងវាស្ថិតនៅក្នុងដៃរបស់កងទ័ព គេអាចប្រើប្រាស់ក្នុងសកម្មភាពមិនល្អប្រឆាំងទៅលើកងទ័ពដទៃទៀត។ សំណួរខ្ញុំសួរថា ហេតុអ្វីបានជាកងទ័ពមកពីភូមិភាគបូព៌ាត្រូវបានទុកចិត្តឲ្យប្រើប្រាស់ឆ្នួន ប្រើប្រាស់គ្រឿងបំផ្ទុះហ្នឹង? តើគេមិនយល់ថា វាគ្រោះថ្នាក់ទេឬ? អាចជាការធ្វើសកម្មភាពគ្រោះថ្នាក់ទេឬ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ម្តងទៀត ការគ្រប់គ្រងកម្លាំងនៅបូព៌ាក៏ពួកនិរតីដែរ។ អ៊ីចឹងពួកនិរតីបញ្ជាឲ្យធ្វើម៉េច គឺត្រូវតែធ្វើ។ មិនដែលមានពីណាហ៊ានប្រកែកទេ។ សូម្បីតែកងរបស់ខ្ញុំក៏ត្រូវភូមិភាគនិរតីហ្នឹងមកត្រួតត្រាដែរ គ្រប់គ្រងដែរ។ គេឲ្យធ្វើអីខ្ញុំធ្វើហ្នឹង។ យ៉ាងណាមិញកម្លាំងបូព៌ាក៏ដូច្នោះដែរ។

[០៩:៤៩:៣៩]

**ស៖** ដូច្នេះកម្មាភិបាលភូមិភាគនិរតី គឺត្រូវគ្រប់គ្រង និងត្រួតពិនិត្យកម្មាភិបាលទាំងអស់នេះគឺថាផ្តល់គ្រឿងបំផ្ទុះ ឬផ្សេងទាំងអស់នេះទៅឲ្យខាងភូមិភាគបូព៌ាប្រើប្រាស់។ តើលោកកំពុងតែនិយាយថាដូច្នេះ ឬក៏យ៉ាងណា?

**ឆ៖** បាទៗ អ៊ីចឹងហើយ។ ខាងភូមិភាគនិរតីឲ្យផ្លូនទៅកម្លាំងភូមិភាគបូព៌ា យកទៅដាក់ថ្មឲ្យផ្ទុះដើម្បីយកថ្មនោះប្រើប្រាស់។ ប៉ុន្តែតុលាការជ្រាបស្រាប់ហើយ ជាតិផ្ទុះ និងថ្មនេះ តែផ្ទុះអាចមានបំណែកខ្ទាតមកត្រូវមនុស្ស ឲ្យខានមិនខានទេ។

**ស៖** បាទលោកសាក្សី ខ្ញុំបន្តទៅមុខទៀត។ លោកក៏បានឆ្លើយថា មុនលោកទៅធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំង លោកធ្វើការនៅអន្លង់ក្ងាន។ តើត្រឹមត្រូវដែរទេ លោក?

**ឆ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** លោកបានឆ្លើយថា លោកធ្វើការនៅអន្លង់ក្ងាន គឺថាម៉ោងប្រាំពីរព្រឹកទៅម៉ោងដប់មួយហើយឈប់សម្រាកបាយថ្ងៃត្រង់។ ចាប់ផ្តើមធ្វើការម្តងទៀត នៅម៉ោងពីររហូតដល់ម៉ោងប្រាំ។ តើត្រឹមត្រូវទេ?

**ឆ៖** បាទ គឺត្រឹមត្រូវហើយ។

**ស៖** តើខ្ញុំយល់សក្ខីកម្មរបស់លោកត្រឹមត្រូវទេថា ពេលម៉ោងការងារនៅព្រលានយន្តហោះកំពង់ឆ្នាំង គឺដូចតែគ្នាទេ គឺចន្លោះពីម៉ោងប្រាំពីរទៅម៉ោងដប់មួយ រួចសម្រាកបាយថ្ងៃត្រង់ បន្ទាប់មកចាប់ធ្វើការពីម៉ោងពីរ ឈប់សម្រាកនៅម៉ោងប្រាំល្ងាច តើដូចគ្នាអ៊ីចឹងទេ?

**ឆ៖** ពេលថ្ងៃដូចគ្នា។ តែពេលយប់ ព្រលានយន្តហោះថែមម៉ោងទៀត។

[០៩:៥១:៥៩]

**ស៖** លោកក៏បានឆ្លើយផងដែរថា លោក និងកងរបស់លោកត្រូវបានគេប្រព្រឹត្តខុសពីកងទ័ពដទៃទៀត ហើយគេចាត់ទុកក្រុមលោកហ្នឹងថាជាក្រុមគ្មានប្រយោជន៍អីទេ ដែលគេប្រព្រឹត្តខុសពីក្រុមផ្សេង។ តើលោកអាចផ្តល់ឧទាហរណ៍ជូនអង្គជំនុំជម្រះអំពីការប្រព្រឹត្តខុសគ្នាមកលើលោក កងរបស់លោក និងកងទ័ពដទៃទៀត?

**ឆ៖** ខ្ញុំសូមបញ្ជាក់ជូន កងខ្ញុំនេះគេហៅថា កង១៧។ កង១៧នេះគឺគេចម្រាញ់អស់ហើយ អត់មានឲ្យឆ្លងកាត់ទៅអ្នកណា ឬក៏ទៅសួរសុខទុក្ខនៅកងនេះកងនោះទៀត អត់មានទេ។ នៅកន្លែងណា គឺ

នៅកន្លែងហ្នឹង ហើយធ្វើការធ្ងន់ធ្ងរជាងគេ។ ថ្ងៃធ្វើ៨ម៉ោងហើយ យប់តម្រូវឲ្យធ្វើ៤ម៉ោងទៀត ពេលដែលគេចង់ប្រើ មិនថាភ្លៀង ឬអត់ទេ ឲ្យតែថាគឺថាត្រូវការហើយ ត្រូវតែទៅ ត្រូវតែទៅធ្វើ។

**ស៖** ខ្ញុំយល់ហើយលោកសាក្សី ប៉ុន្តែសូមលោកផ្ដល់ឧទាហរណ៍មួយអំពីការប្រព្រឹត្តខុសគ្នាបែបនេះ គឺការប្រព្រឹត្តមកលើកងរបស់លោក និងកងទ័ពដទៃទៀត ដែលលោកឆ្លើយថា ក្រុមដទៃទៀតគឺថាត្រូវបានគេប្រព្រឹត្តជាធម្មតា មានន័យថាគេអនុវត្តជាធម្មតា។ អ៊ីចឹងសូមលោកនិយាយពីចំណុចខុសគ្នា។

**ឆ៖** គេកំណត់កង១៧នេះថា ជាកងជម្រើស ជាកងដែលជាប់បណ្ដាញក្បត់។ អ៊ីចឹងគេប្រើវិធានការក្ដៅជាងគេ លត់ដំបាន បាន បើមិនបាន ងាប់ តែប៉ុណ្ណឹង។

[០៩:៥៤:១៩]

**ស៖** ខ្ញុំយល់ ប៉ុន្តែអ្វីដែលខ្ញុំសួរលោក គឺសូមឲ្យលោកផ្ដល់ឧទាហរណ៍ជាក់ស្ដែងមួយ ពាក់ព័ន្ធទៅនឹងពេលម៉ោងការងារ។ ឧទាហរណ៍របបអាហារ អនាម័យ សម្ភារៈសម្រាប់ដេកពួននេះ ដែលអាចបង្ហាញឲ្យឃើញថា ទាំងអស់នេះ វាមានលក្ខណៈខុសគ្នារវាងកងលោក និងកងដទៃទៀត ដែលលោកថា កងលោកគេប្រព្រឹត្តផ្សេង ឯកងដទៃទៀត គេប្រព្រឹត្តជាធម្មតា។

**ឆ៖** ការងារកងរបស់ខ្ញុំនេះ គឺគ្មានពេលសម្រាកទេ បញ្ជាក់ជូន។ កងគេមានពេលសម្រាកពីម៉ោងប្រាំពីរទៅម៉ោងប្រាំបួនហ្នឹងសម្រាកម្ដងទៅ។ ដល់ម៉ោងប្រាំបួនទៅដប់មួយទៅសម្រាកទៅទៀតទៅ។ ឯកងខ្ញុំគ្មានម៉ោងប្រាំបួនទេ បើចាប់ធ្វើហ្នឹងធ្វើទាល់តែពីម៉ោងប្រាំពីរទៅដល់ម៉ោងដប់មួយហ្នឹងសម្រាកហូបបាយតែម្ដង។ ហើយសម្រាកពីម៉ោងដប់មួយហ្នឹងដល់ម៉ោងពីរបានពេលចន្លោះហ្នឹងសម្រាក។ ដល់ម៉ោងពីររហូតដល់ម៉ោងប្រាំគឺគ្មានពេលសម្រាកទេ រហូតទៅដល់ពេលឈប់តែម្ដង។ ហ្នឹងការងារ។ រីឯជម្រកវិញគឺ គ្មានមុងគ្មានកន្ទេលទេ។ ឯលំនៅនោះក៏ដាច់ដាច មិនគួរទេៗ ប៉ុន្តែយើងមិនដឹងទៅជួសជុលស្អី បើយើងជាអ្នកពលកម្មអ៊ីចឹង។ ម៉ោងប្រាំបួនចេញធ្វើការបាត់ ម៉ោងប្រាំមកដល់កន្លែង។ មានពេលណាទៅរកឧបករណ៍មកជួសជុលជម្រកហ្នឹង គ្មានទេ។ ខោអាវតែពីរកំប្លេទេ ល្ងាចមកងូតទឹកបោកមួយ យកមួយស្លៀក។ មានតែប៉ុណ្ណឹង គឺគ្មានសិទ្ធិអីធ្វើអីទៀតទេ។

[០៩:៥៦:២៦]

**ស៖** តើមេបញ្ជាការរបស់លោក នៅពេលលោកធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំងនោះ មានប្រាប់លោក និងសមមិត្តរបស់លោកនៅក្នុងកងជាមួយគ្នាហ្នឹង ថាត្រូវធ្វើការ១ម៉ោងបន្ថែម ឬក៏

២ម៉ោងបន្ថែម ខុសពីកងដទៃ? តើមានការបញ្ជា មានការពន្យល់ មានការណែនាំណាមួយដែរទេ? សូមលោកបញ្ជាក់ដោយលម្អិតបន្តិចបានទេ?

**ឆ៖** ពេលដែលគេត្រូវការឲ្យយើងធ្វើម៉ោងថានៅពេលយប់ គេប្រាប់យើងតែម្តងទេ។ ឧបមាថា ថ្ងៃ២០ គេមិនថាថ្ងៃ២០ ប្រាប់យើងថាថ្ងៃ២០ ទៅដល់ថ្ងៃល្ងាចថា ល្ងាចនេះរហូតដល់ទៅរួចទើបយើងឈប់។ អ៊ីចឹងមិនថាថ្ងៃ២១, ២២ទេ ឲ្យថាគេហៅថាឲ្យធ្វើទាំងយប់ហើយ គឺថែម៤ម៉ោងហ្នឹង ពីម៉ោងប្រាំមួយទៅដល់ម៉ោងដប់អីហ្នឹង។ អាហ្នឹងសម្រាកត្រឡប់មកវិញហើយ។ ជារៀងរាល់ថ្ងៃអ៊ីចឹងថា ដល់ថ្ងៃបន្តបន្ទាប់ទៀតទៅ មិនបាច់មកវិញទេ នៅសម្រាកអង្គុយហ្នឹងទៅរហូតដល់ម៉ោងប្រាំមួយហ្នឹងទៅ ចាប់ផ្តើមធ្វើតទៅទៀតទៅ។ ឯកម្លាំងអ្នកត្រួតពិនិត្យកន្លែងខ្ញុំហ្នឹង គឺគេដូរខ្ញុំពិនិត្យមើលទៅឃើញគេដូរគ្នាជារៀងរាល់ពេលអ៊ីចឹង។ ឯកម្លាំងផងខ្ញុំប៉ុន្មាននាក់ហ្នឹង គឺមិនមានដូរទេ។ គ្មានកម្លាំងណាទៅដូរទេ។

**ស៖** ដោយសារខ្ញុំមានពេលវេលាខ្លី ខ្ញុំសូមបន្តទៅមុខទៀត។ លោកបានឆ្លើយថានៅព្រលានយន្តហោះកំពង់ឆ្នាំង គេលែងចាត់ទុកលោកថាជាកងទ័ពទៀតហើយ គេលែងចាត់ទុកលោកជាកងទ័ពឬក៏ជាយុទ្ធជនទៀតហើយ គេចាត់ទុកលោកគឺថាជាពលករ កម្មករ។ តើលោកដឹងថាកងទ័ពមកពីកងពល៣១០ធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំងត្រូវបានបញ្ជាឲ្យទៅប្រយុទ្ធនៅខែតុលា ឆ្នាំ១៩៧៧ជាមួយនឹងវៀតណាមដែរឬទេ?

**ឆ៖** កងដែលទៅធ្វើវាលរង់នៅកំពង់ឆ្នាំងហ្នឹង គឺមិនមានអ្នកណាម្នាក់ទៅប្រយុទ្ធជាមួយវៀតណាមទេ អត់មានទេ។ ហើយខ្ញុំដឹងតែកងនៅក្នុងក្រុមជាមួយខ្ញុំទេ ខុសពីហ្នឹងខ្ញុំអត់ដឹងដែរ។

[០៩:៥៩:២៩]

**ស៖** ខ្ញុំសូមផ្តល់ឧទាហរណ៍មួយជូនលោក។ អតីតមេបញ្ជាការនៃមន្ទីរក-៤ ខាងផ្នែកយោធាពិការ បានផ្តល់សក្ខីកម្មថា កម្លាំងជាងពាក់កណ្តាលនៃកងរបស់គាត់បានស្ម័គ្រចិត្តទៅវាយប្រយុទ្ធជាមួយវៀតណាមនៅតាមព្រំដែន។ តើលោកនឹកឃើញទេ បើខ្ញុំប្រាប់លោកអំពីសក្ខីកម្មរបស់សាក្សីរូបនេះឆ្លើយថាអ៊ីចឹង?

**ឆ៖** ខ្ញុំអត់ដឹងផង អត់ដែលឃើញផង។ ខ្ញុំទៅវាលរង់យន្តហោះហ្នឹង គឺលែងៗដឹងអីទាំងអស់។ អ្នកណាមានបញ្ហាទៅវាយនៅឯណាៗទៀត ខ្ញុំអត់ដឹង។ ខ្ញុំដឹងតែងើបឡើងរៀបចំខ្លួន ចេញទៅធ្វើការម៉ោងប្រាំពីរដល់កន្លែង តែប៉ុណ្ណឹង។

**ស៖** ដូច្នេះលោកឆ្លើយថា លោកមិនដឹងថា មានអ្នកណាម្នាក់ពីកងពល៣១០ ដែលបានទៅធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំង ត្រូវបានបញ្ជូនទៅឲ្យប្រយុទ្ធជាមួយវៀតណាមនៅតាមព្រំដែនទេ លោកមិនដឹងទេ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទៗអ៊ីចឹងហើយ។

**ស៖** សំណួរចុងក្រោយ។ លោកបានឆ្លើយខ្លីកាលពីម្សិលមិញ អំពីវត្តមានវិស្វករចិន។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេថា នៅដើមដំបូងនោះ លោកបាន -- នៅពេលលោកទៅដល់ទីនោះ លោកបានឃើញប៉ុន្មាន? ហើយមកដល់ចុងបញ្ចប់នៃពេលដែលលោកធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំង អ៊ីចឹងពីដើមដល់ចប់មក តើលោកសង្កេតឃើញថា មានវិស្វករចិនប៉ុន្មាននាក់ដែរ?

[១០:០១:៣៧]

**ឆ៖** ខ្ញុំមិនអាចសន្និដ្ឋានថា ប៉ុននេះប៉ុននោះបានទេ ប៉ុន្តែច្រើន។ ទៅត្រង់ណា ក៏មានជំនាញការចិនដែរ។ កុំសូមឡើយតែវាយថ្ម ឬក៏គ្រាន់តែពង្រាបដីឲ្យស្មើ ឬក៏ចាក់ដីហ្នឹង ក៏មានចិននៅឈរមើល នៅបង្គាប់ដែរ។

**ស៖** ដូច្នេះវិស្វករចិនធ្វើការនៅ -- ក៏ចូលរួមពិនិត្យមើលខាងផ្នែកកងដែលប្រើប្រាស់ឆ្នូន និងគ្រឿងបំផ្ទុះហ្នឹងដែរ។ អ៊ីចឹងមែនទេ?

**ឆ៖** ត្រង់ហ្នឹងខ្ញុំអត់ដឹងទេ។ ដឹងតែកន្លែងដែលខ្ញុំធ្វើការហ្នឹង គឺមានចិននៅត្រួតពិនិត្យគ្រប់ពេលទាំងអស់ លើកលែងតែយប់ អត់មានទេ។

**ស៖** តើលោកអាចផ្តល់ចម្លើយប្រហាក់ប្រហែលបានទេ ចំនួនប្រហាក់ប្រហែល? ពីខាងដើមលោកឃើញប្រហាក់ប្រហែលជាប៉ុន្មាន? ហើយនៅចុងបញ្ចប់ លោកឃើញចំនួនប្រហាក់ប្រហែលជាប៉ុន្មាន? មិនបាច់ផ្តល់តួលេខអីពិតប្រាកដទេ។

**ឆ៖** បើកម្លាំងពលកម្មធ្វើវាលរង់យន្តហោះហ្នឹង គឺឆ្នាំ៧៧, ៧៨ហ្នឹងច្រើនៗមែនទែន ត្រង់ណាក៏មនុស្សដែរ។ ហើយត្រង់ណា ក៏មានជំនាញ និងមានចិននៅចង្អុលការត្រួតពិនិត្យដែរ។ តែប៉ាន់ស្មានថាចំនួនប៉ុននេះរយ ប៉ុននេះពាន់ មិនអាចត្រូវទេ ស្មានមិនត្រូវទេ។

**ស៖** បាទ មិនជាអ្វីទេ លោកសាក្សី។ ប៉ុន្តែតើត្រឹមត្រូវដែរឬទេថា ឧបទ្ទវហេតុគ្រោះថ្នាក់ដែលកើតឡើងដោយសារគ្រឿងបំផ្ទុះ ពលករធ្វើការអស់កម្លាំង តើមានអ្វីកើតឡើងជាមួយនឹងវិស្វករចិន ឬក៏អ្នកជំនាញការចិន មានគ្រោះថ្នាក់អ្វីកើតឡើងចំពោះអ្នកទាំងនេះទេ?

**ឆ៖** ពេលថ្មផ្ទុះហ្នឹង ចិនគេមិនដែលនៅជិតទេ មិនដែលឃើញទេ។ មានតែខ្មែរៗ ដែលកម្លាំងនៅធ្វើវាលវង់ហ្នឹង គេនៅជិតហ្នឹង គេប្រើគេប្រាស់ ចង្អុលការឲ្យធ្វើយ៉ាងម៉េចៗហ្នឹង អ្នកចង្អុលការមិនមាននៅនឹងកន្លែងផ្ទុះទេ ហើយគ្រាន់តែប្រាប់យករបស់នេះទៅដាក់ឲ្យផ្ទុះ ហើយមានខ្សែបញ្ចេះហ្នឹងវាប្រវែងនេះៗទៅ។ អាអ្នកប្រើនៅឆ្ងាយ ហើយអ្នកយកទៅដាក់ហ្នឹង គឺឆ្នូនផ្ទុះ ខ្ទាតអំបែងថ្មមក យ៉ាងតិចក៏ត្រឹមរបួសធ្ងន់ យ៉ាងតិច។ បើច្រើន ងាប់។ ហ្នឹងគេ ភាគច្រើនគេនិយាយតៗគ្នាមកអ៊ីចឹង។

[១០:០៥:២២]

**ស៖** ខ្ញុំយល់ហើយ។ ខ្ញុំ -- គឺក្រោយពីស្តាប់មកខ្ញុំក៏បានសន្និដ្ឋានថា លោកមិនដែលបានឃើញព្រឹត្តិការណ៍បែបនេះដោយផ្ទាល់ភ្នែកទេ។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទៗ អ៊ីចឹងមែន។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទសូមអរគុណលោកប្រធាន។ ខ្ញុំចប់ហើយ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក ហ្សង់ម៉ាក!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ លោកមេធាវី កូប៉េ សម្រាប់ជាប្រតិចារឹកសវនាការ យើងសូមឲ្យលោកបញ្ជាក់ថា តើកាលពីព្រឹកមិញនេះលោកយោងទៅលើឯកសារ 19.93 ឬក៏ 19.193? ប្រហែលជាអាចមានបញ្ហាបកប្រែ ក៏ប៉ុន្តែប្រសិនជាមានបញ្ហាគឺយើងអាចកែតម្រូវ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកចៅក្រម ឡាវែន៍ ខ្ញុំលែងមានបំណងប្រើប្រាសឯកសារនេះទៀតហើយ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកមេធាវី។ នាពេលនេះដល់ពេលសម្រាកហើយ។ អង្គជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញ។

សូមអញ្ជើញសម្រាក!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:០៧នាទី ដល់ម៉ោង ១០:២៧ នាទី)*

[១០:២៧:២៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

ជាបន្តទៀត អង្គជំនុំជម្រះផ្តល់វេទិកាដល់ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន។

សូមអញ្ជើញលោកមេធាវី!

**លោក អាកទូរ វែកកែន៖**

បាទ សូមអរគុណលោកប្រធាន។ បាទ ជម្រាបសួរភាគីទាំងអស់។

**សួរដោយលោក អាកទូរ វែកកែន៖**

**ស៖** បាទ ជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ អាកទូរ វែកកែន ខ្ញុំជាសហមេធាវីអន្តរជាតិរបស់លោក ខៀវ សំផន។ សំណួរដំបូងរបស់ខ្ញុំ សួរទាក់ទងទៅនឹងមូលហេតុដែលលោកចូលទៅធ្វើបដិវត្តន៍។ លោកបាននិយាយក្នុងកិច្ចសម្ភាសន៍របស់លោកជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយលោកក៏បាននិយាយផងដែរ ពេលក្រោយមកជាមួយសហចៅក្រមស៊ើបអង្កេត។ អ៊ីចឹងខ្ញុំចង់ឲ្យលោកពន្យល់ថា ហេតុអ្វីបានជាលោកសម្រេចចិត្តចូលបដិវត្តន៍?

**លោក ហ៊ឹម ហាន៖**

**ឆ៖** មូលហេតុដែលខ្ញុំចូលបម្រើការងារបដិវត្តន៍ក្នុងជួរកងទ័ពនេះ ដោយ លន់ នល់ ធ្វើរដ្ឋប្រហារសម្តេច សីហនុ យើងនិយាយឲ្យខ្លីថា "សម្តេចឪ"។ ហើយក្រោយមកសម្តេចស្រែកអំពាវនាវឲ្យកូនចៅចូលព្រៃម៉ាគីរួមកម្លាំងគ្នា ដើម្បីរំលំរបប លន់ នល់។ ដូច្នេះបានជាខ្ញុំចូលធ្វើបដិវត្តន៍ទៅ នឹងគេទៅ។

**ស៖** ដោយលោកផ្ទាល់ ទាក់ទងនឹងប្រវត្តិរូបរបស់លោកផ្ទាល់នោះ តើបើចំពោះលោកផ្ទាល់ តើមានមូលហេតុអីជាលក្ខណៈបុគ្គលដែលជំរុញឲ្យលោកចូលបដិវត្តន៍ដែរឬទេ?

**ឆ៖** មានខ្លះ។ ដូចជាយន្តហោះកងទ័ព លន់ នល់ ហ្នឹងទម្លាក់គ្រាប់បែក ខ្ទេចខ្ទី ឆេះផ្ទះខ្ញុំខ្ទេចខ្ទីអស់ ហើយនិងកងទ័ពរបស់ លន់ នល់ ហ្នឹងរាតត្បាតមកលើប្រជារាស្ត្រដទៃទៀត មិនថាភូមិខ្ញុំ ឃុំខ្ញុំឬនេះ គឺទូទាំងប្រទេស គឺកងទ័ពគេគ្មានសីលធម៌។ កាលហ្នឹងខ្ញុំខឹង ហើយមករួមចំណែកនឹងបដិវត្តន៍ទៅ ដើម្បីរំលំរបប លន់ នល់ ហ្នឹងចេញ។

[១០:៣០:៥១]

**ស៖** បាទ ខ្ញុំយល់អ្វីដែលលោកបានលើកឡើង។ តើលោកអាចរៀបរាប់បានដែរឬទេ ឬឱ្យជាឧទាហរណ៍ទាក់ទងទៅនឹងភាពអត់មានសុជីវធម៌ អត់សីលធម៌របស់កងទ័ព លន់ នល់ នេះ? តើលោកអាចពន្យល់ឱ្យបានច្បាស់បានទេ ជាក់លាក់ថាយ៉ាងម៉េចដែរ មានន័យយ៉ាងម៉េចដែរ?

**ឆ៖** តាមខ្ញុំចាំ និងខ្ញុំបានឃើញ ឧទាហរណ៍ថា គេចុះទៅភូមិណាមួយ របស់របរប្រជាជនត្រូវចង់បានអី គឺយកហ្នឹង។ ខ្ញុំនិយាយតែអំពីការហូបចុកមួយមុខបានហើយ ដូចជាមាន់ ទាជាដើម គឺថាទៅគឺស្រេចនឹងចិត្តគេ។ បើគេស្គាល់គ្នាអីទៅខ្លះទៅ គឺគេសុំ បើមិនឃើញទេ ដេញបាញ់ ដេញចាប់តាមទំនើងចិត្តទៅ។ មិនថាភូមិខ្ញុំ ឬក៏ភូមិគេដទៃៗហ្នឹងក៏មានសភាពមិនខុសគ្នាទេ ព្រោះទ្រឹស្ដីគេថា បើមិនចាប់ បើមិនរកអត់ស៊ី។ គ្មានយកធ្វើអីទេ ខ្ញុំដឹងប៉ុណ្ណឹង រកគ្រាន់តែស៊ី ប៉ុន្តែវាខ្វះសីលធម៌។

**ស៖** បាទ សូមអរគុណដែលបានឆ្លើយលម្អិត។ បាទ ឥឡូវខ្ញុំសូមចោទសំណួរម្ដងទៀត សំណួរហ្នឹងគេសួរលោកហើយៗ ខ្ញុំសួរដើម្បីសុំការបំភ្លឺចម្លើយរបស់លោក។ ខ្ញុំចង់សួរលោកថា តើនៅពេលណាដែលលោកត្រូវបានគេបញ្ជូនទៅព្រលានយន្តហោះកំពង់ឆ្នាំងនោះ? លោកចាំទេថា គេបញ្ជូនលោកទៅពេលណាដែរ? បើសិនជាលោកមានលទ្ធភាពអាចជម្រាបជូនតុលាការ ដោយប្រៀបទៅនឹងព្រឹត្តិ-ការណ៍ណាមួយនៅសម័យនោះ តើគេបញ្ជូនលោកហ្នឹងធៀបហ្នឹង បើធៀបនឹងព្រឹត្តិការណ៍ណាមួយនៅពេលណាដែរ មុន ឬក៏ក្រោយអីជាដើម?

**ឆ៖** បើតាមខ្ញុំចាំ ប្រហែលជាចុងឆ្នាំ៧៦ ដើមឆ្នាំ៧៧ ព្រោះខ្ញុំគ្រាន់តែចាំថាខែ១១ ខ្ញុំចេញទៅ។ តែឆ្នាំ៧៦ ក៏មិនដឹង ដើមឆ្នាំ៧៧ក៏មិនដឹង។ ខ្ញុំភ្លេចអស់ហើយ។

[១០:៣៤:០២]

**ស៖** តើលោកចាំដែរឬទេ ថានៅពេលដែលលោកត្រូវបានបញ្ជូនទៅការដ្ឋានព្រលានយន្តហោះ គឺ អឿន ត្រូវបានចាប់ខ្លួនហើយ ឬក៏គាត់មិនទាន់ត្រូវបានគេចាប់ខ្លួនទេ?

**ឆ៖** អឿន ត្រូវគេចាប់ខ្លួនបាត់ហើយ។

**ស៖** បាទ សូមអរគុណ។ បាទ កាលពីម្សិលមិញ សហព្រះរាជអាជ្ញាបានបង្ហាញឯកសារមួយជូនលោក គឺជាទង់ -- ទស្សនាវដ្ដីទង់បដិវត្ត ដែលចុះថ្ងៃទី០៨ សីហា ឆ្នាំ១៩៧៥ គឺឯកសារ E3/5។ បាទ ខ្ញុំសូមអានសម្រង់មួយជូនលោក ព្រោះម្សិលមិញហ្នឹងមិនទាន់មានបានអានជូនលោកស្ដាប់ទេ គឺជាទស្សនាវដ្ដីរបស់របបខ្មែរក្រហមគឺ ERN ជាភាសាខ្មែរលេខ 00063340, ជាភាសាបារាំង

00538965, អង់គ្លេសគឺ 00401500។ បាទ សម្រង់ដែលខ្ញុំចង់អានជូនលោកស្តាប់នោះគឺទាក់ទងទៅនឹងភារកិច្ចពីរដ៏សំខាន់ដែលគេប្រគល់ឲ្យកងទ័ព គឺស្ថិតនៅក្នុងជំពូក៤។ បាទ ខ្ញុំសូមដកស្រង់៖ “ភារកិច្ចថ្មីរបស់កងទ័ពបដិវត្តន៍យើង។ ភារកិច្ចរបស់កងទ័ពបដិវត្តន៍យើង គឺជាភារកិច្ចដែលបក្សប្រគល់មានពីរ គឺការពារប្រទេស និងកសាងប្រទេស។ នេះគឺជាភារកិច្ចពីរដែលបក្សលើកឡើង ធំៗពីរដែលបក្សលើកឡើង។ ភារកិច្ចទាំងពីរនេះជាប់គ្នា ព្រោះទាល់តែការពារប្រទេសបានទើបកសាងប្រទេសបាន។ ហើយទាល់តែកសាងប្រទេសឲ្យបានជឿនលឿន ទើបការពារប្រទេសបានល្អ។” បាទ សូមចប់ការដកស្រង់។ ខ្ញុំចង់សួរលោកថា នៅពេលដែលគេបញ្ជូនលោកទៅការដ្ឋានសម្ងាត់នៃព្រលានយន្តហោះកំពង់ឆ្នាំងនេះ គេបានពន្យល់ ថាតើគេបានពន្យល់ប្រាប់លោកអំពីភារកិច្ចថា ការពារប្រទេស ឬក៏កសាងប្រទេសនេះជូនលោកស្តាប់ដែរឬទេ មុននឹងបញ្ជូនលោកទៅព្រលានយន្តហោះកំពង់ឆ្នាំងនេះ?

[១០:៣៧:០៣]

**ឆ៖** គេមិនបានមកណែនាំ រៀបរាប់អំពីការងារការពារនិងកសាងអីឲ្យជាដុំកំភួនទេ ព្រោះពេលនុ៎ងថា គេចង់ធ្វើអីថ្មីរណាគឺគេហៅប្រជុំថ្មីរហ្នឹងហើយ។ និយាយបញ្ជាក់ជូនថា គ្រប់គ្រងដោយកម្លាំងនិរតីមកគ្រប់គ្រងខ្ញុំ តែកងខ្ញុំទាំងអស់គ្នាហ្នឹង។ តែគេទទួលផែនការពីលើមកថា ថ្មីរណាគេហៅថ្មីរហ្នឹងតែម្តង។ មិនថាយើងអត់ មិនទាន់ហូបបាយ ឬក៏កំពុងតែសម្រាកហេរ អត់ទេ។ តែគេត្រូវការគឺគេហៅហើយ។ បញ្ជាក់ជូនដោយខ្លីប៉ុណ្ណឹង។

**ស៖** ហើយលោកនិយាយថា គេហៅប្រជុំអីពេលណាពេលហ្នឹង តើកិច្ចប្រជុំហ្នឹង -- ក្នុងកិច្ចប្រជុំហ្នឹងគេនិយាយអំពីអ្វីដែរ?

**ឆ៖** គេនិយាយអំពី ឲ្យរៀបចំខ្លួនទៅធ្វើវាលរវង់នៅកំពង់ឆ្នាំង។ តែមួយឃ្លាដ៏ខ្លីប៉ុណ្ណឹង ឲ្យរៀបចំតែម្តង។

**ស៖** លោកបានឆ្លើយនៅក្នុងសាលសវនានេះជាច្រើនដង ថាការងាររបស់លោកនៅព្រលានយន្តហោះនៅក្នុងកង១៧នេះ លំបាកជាងការងារដែលគេប្រគល់ឲ្យកងផ្សេងៗទៀតនៅលើការដ្ឋានព្រលានយន្តហោះដូចគ្នានេះ។ ខ្ញុំចង់អានសម្រង់មួយនៃចម្លើយរបស់សាក្សីម្នាក់ដែលគាត់នោះស្ថិតនៅក្នុងកងដូចលោកដែរ ហើយធ្វើការនៅលើការដ្ឋានដូចគ្នានឹងលោកដែរ។ គឺឯកសារ E3/471, ERN ជាភាសាខ្មែរគឺ 00172080, ERN ជាភាសាបារាំង 00205018, ជាភាសាអង់គ្លេស 00223337 គឺជាចម្លើយរបស់លោកដែលមានឈ្មោះ -- រហស្សនាមគឺ 2-TCW-382។ នៅក្នុងឆ្នាំ១៩៧៧ គាត់មាន

អាយុ១៩ឆ្នាំ។ គាត់បាននិយាយអំពីលក្ខខណ្ឌការងារដូចតទៅនេះ។ សំណួរដែលគេសួរគាត់កាលនោះថា៖ “នៅព្រលានយន្តហោះកំពង់ឆ្នាំង តើមានការងារយ៉ាងម៉េចដែរ? របបអាហារយ៉ាងម៉េចដែរ? ហើយលក្ខខណ្ឌការងារពិបាក ឬក៏ស្រួល? គាត់ឆ្លើយថា៖ យើងធ្វើការស្រួលដែរទេ ក៏ប៉ុន្តែយើងមិនហូបគ្រប់គ្រាន់ទេ។ យើងទទួលអង្ករពីរកំប៉ុង ព្រឹកមួយកំប៉ុង ល្ងាចមួយកំប៉ុង។” អ្នកសួរគាត់នោះឆ្លើយថា៖ បាទ។ ហើយគាត់សួរថា៖ តើរបបហ្នឹងគេចែកយ៉ាងម៉េចដែរសម្រាប់ម្នាក់ៗ? គ្រប់គ្រាន់ទេ?”។ អ៊ីចឹងខ្ញុំសូមឲ្យលោកឆ្លើយតបទៅនឹងចម្លើយរបស់គាត់នោះ ដែលគាត់ឆ្លើយថាៗការងារមិនសូវលំបាកទេ បើធៀបទៅនឹងការងារដែលគេប្រគល់ឲ្យគាត់ធ្វើពីមុនមកនោះ ហើយគាត់ហ្នឹងគាត់ស្ថិតនៅក្នុងកងរបស់លោកដែរ។ អ៊ីចឹងតើលោកមានប្រតិកម្មយ៉ាងណាដែរចំពោះចម្លើយរបស់លោកសាក្សីដែលខ្ញុំបានរៀបរាប់ចម្លើយគាត់អម្បាញ់មិញនេះ?

[១០:៤១:៣២]

**ឆ៖** កម្លាំងសាក្សីដែលឆ្លើយបំភ្លឺដល់ចៅក្រមនេះក៏ម្យ៉ាងដែរ ខ្ញុំក៏ទទួលស្គាល់។ ប៉ុន្តែកងរបស់ខ្ញុំផ្ទាល់នេះគឺមិនបានហូបចុកអីឲ្យពេញលេញទេ តែការងារក្តៅជាងគេ។ ដូចខ្ញុំបានជម្រាបពីខាងដើមមកហើយ កងខ្ញុំនេះគឺកង១៧ គេចម្រាញ់ៗ។ គេយក បើគេចង់ឲ្យធ្វើអី គឺឲ្យធ្វើហ្នឹងភ្លាម មិនថាទេព្រឹកល្ងាចថ្ងៃទេ យប់ថ្មើរណាក៏ដោយ តែនេះគេៗមិនចាំបាច់មកហៅដាស់អីទេ។ គេវ៉ៃជួងម៉ឹងៗហ្នឹងទៅត្រូវតែទៅ កងខ្ញុំទាំងប៉ុន្មានហ្នឹងគឺត្រូវតែមានមុខទាំងអស់។ ឯសាក្សីបំភ្លឺនោះ គឺពិតមែនជាបានទៅធ្វើព្រលានយន្តហោះជាមួយខ្ញុំមែន ប៉ុន្តែគេនៅកងដោយខ្លួន ខ្ញុំមិនស្គាល់គេទេ។ សូមទោស នៅក្រុមដោយខ្លួន ខ្ញុំមិនស្គាល់គេទេ។

**ស៖** បាទខ្ញុំមិនទាន់ឲ្យឈ្មោះគាត់ទៅលោកផង។ អ៊ីចឹងខ្ញុំមិនដឹងថា លោកអាចអះអាងថាលោកមិនស្គាល់គាត់ដោយវិធីណានោះទេ។

**លោក អាកទួរ វែកកែន៖**

ហើយលោកប្រធាន បើសិនលោកប្រធានអនុញ្ញាត ខ្ញុំត្រៀមផ្តល់ឯកសារមួយសន្លឹកនេះទៅជូនគាត់ ព្រោះនៅក្នុងឯកសារនេះមានឈ្មោះសាក្សីហ្នឹងលោកប្រធាន។ អ៊ីចឹងសុំឲ្យមន្ត្រីតុលាការជួយយកឯកសារនេះទៅជូនគាត់ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការយកឯកសារនេះជូនទៅសាក្សី។

*(មន្ត្រីរដ្ឋបាលតុលាការយកឯកសារជូនសាក្សី)*

[១០:៤៩:២២]

**សួរដោយលោក អាកទូរ វែកគែន៖**

**ស៖** លោកសាក្សី លោកបានអានឈ្មោះគាត់ហើយឬនៅ? លោកស្គាល់គាត់ទេ?

**លោក ហ៊ឹម ហាន៖**

**ឆ៖** ខ្ញុំអត់ស្គាល់គាត់ទេ។

**ស៖** សូមអរគុណ។ ដើម្បីជាព័ត៌មានសម្រាប់លោក គឺថាលោកសាក្សីរូបនុ៎ង គាត់បានឆ្លើយថា គាត់ស្ថិតនៅក្នុងកងជាមួយនឹងលោក។ ហើយគាត់ក៏បានឆ្លើយផងដែរ នៅពេលដែលចៅក្រមស៊ើបអង្កេតសម្ភាសគាត់ គឺឯកសារ E3/471។ ERN ជាភាសាបារាំងគឺ 00205019, ហើយជាភាសាខ្មែរគឺ 00172080 ហើយពីរបីនាទីទៀត ខ្ញុំនឹងផ្តល់លេខយោងជាភាសាអង់គ្លេស។ គេសួរគាត់ថា សំណួរដូចតទៅនេះ "គេសួរគាត់ថា៖ នៅពេលដែលលោកធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំង តើមានចាត់វិធានការអ្វីខ្លះ ពីថ្នាក់លើ ពីមេទៅលើអ្នកដែលប្រព្រឹត្តកំហុស? គាត់ឆ្លើយថា៖ "នៅក្នុងកងខ្ញុំវិញ មិនសូវអីទេ តែនៅក្នុងកងដទៃទៀតនោះ ខ្ញុំមិនច្បាស់ទេ។" អ៊ីចឹងបុគ្គលរូបនេះ គាត់ឆ្លើយទាក់ទងទៅនឹងការប្រព្រឹត្តនៅក្នុងកង១៧យ៉ាងដូច្នេះ។ តើលោកមានប្រតិកម្មអីទៅនឹងចម្លើយរបស់គាត់ហ្នឹងទេ? បាទ ខ្ញុំសូមផ្តល់លេខ ERN ជាភាសាអង់គ្លេសគឺ 00223337។

**ប្រធានអង្គជំនុំ៖**

សាក្សី ឯកសារហ្នឹងទុកលើតុ។ សូមបន្តលោកមេធាវី!

[១០:៤៧:២៣]

**សួរដោយលោក អាកទូរ វែកគែន៖**

**ស៖** បាទ អម្បាញ់មិញនេះ ខ្ញុំត្រូវបានកាត់ផ្តាច់សម្តី។ គឺ ERN ជាភាសាអង់គ្លេស បាទសូមកែប្រែគឺ ERN 00223336។ នៅទំព័រនេះ សាក្សីរូបនេះ ដែលខ្ញុំបាននិយាយនេះ គាត់បានឆ្លើយថា មិនមានការប្រព្រឹត្ត មិនមាន -- មិនសូវអីទេនៅក្នុងកងខ្ញុំ តែក្នុងកងដទៃនោះ ខ្ញុំមិនច្បាស់ទេ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ សូមអរគុណលោកប្រធាន។ បាទ ជាការពិតណាស់ សាក្សីនេះគាត់បាននិយាយអំពីកង១៧ មែន ក៏ប៉ុន្តែមិនៗទំព័រមុន -- ប៉ុន្តែគាត់និយាយអម្បាញ់មិញនេះ គាត់ថា គាត់មិនបាននិយាយបញ្ជាក់ពីថា កង១៧ ឬកងណានោះទេ ពីព្រោះថា គាត់និយាយថា នៅកងខ្ញុំ។ អ៊ីចឹងគួរតែបញ្ជាក់ឲ្យបានច្បាស់ ថាតើពិតជាកង១៧មែន ឬក៏យ៉ាងណា ពីព្រោះអីបើតាមចម្លើយនេះ មិនមានបញ្ជាក់ឲ្យច្បាស់លាស់ទេ គាត់គ្រាន់តែនិយាយថា “នៅកងខ្ញុំតែប៉ុណ្ណោះ”។

**លោក អាកទួរ វ៉េកតែន៖**

លោកប្រធាន បើយើងអានចម្លើយរបស់សាក្សីនេះទៅ យើងនឹងដឹងថា សាក្សីរូបនេះត្រូវបាន បញ្ចូលទៅក្នុងកង១៧ មុននឹងពេលបញ្ជូនទៅកំពង់ឆ្នាំង គឺនៅក្នុងទំព័រមុននឹងមួយទំព័រ លោកប្រធាន។ អ៊ីចឹងគាត់មិនបាននិយាយអំពីការផ្លាស់ប្តូរកងគាត់នោះទេ។ អ៊ីចឹងខ្ញុំគិតថាកង ដែលគាត់និយាយថា “កងខ្ញុំហ្នឹង” គឺកង១៧ហ្នឹងហើយ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី!

[១០:៤៩:៥៤]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមបញ្ជាក់បន្តិចទេ គឺថានៅក្នុងឯកសារហ្នឹង គាត់ត្រូវបានដក ចេញពីកងពលហ្នឹង ដើម្បីបញ្ជូនទៅធ្វើការនៅជាមួយនឹងចិន។ ERN ជាភាសាបារាំងគឺ 00205018។ អ៊ីចឹងគិតថា ខ្ញុំគិតថានៅពេលដែលគាត់ធ្វើការនៅព្រលានយន្តហោះនោះ នៅពេលណាមួយគាត់ត្រូវបាន ដកចេញពីកងពលរបស់គាត់ដើម្បីឲ្យគាត់ទៅធ្វើការជាមួយចិន។ អ៊ីចឹងមានការផ្លាស់ប្តូរកងហើយមើល៍ ទៅលោកប្រធាន។

**លោក អាកទួរ វ៉េកតែន៖**

បាទ ខ្ញុំមើលទៅមិនឃើញថា គាត់មានដកចេញអីនោះទេ បើខ្ញុំមើលទៅ។ ក៏ប៉ុន្តែខ្ញុំឃើញថា គាត់ធ្វើការជាមួយចិនមែន។ ហើយយើងដឹងទាំងអស់គ្នាហើយថា នៅព្រលានយន្តហោះនោះ គឺមានចិន ធ្វើការដែរ។

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** អ៊ីចឹងខ្ញុំសួរលោក ថាតើលោកមានប្រតិកម្មអ្វីដែរឬទេ? ព្រោះថាមានសាក្សីរូបនេះដែលគាត់និយាយអំពីលក្ខខណ្ឌការងារនៅក្នុងការងារគាត់នៅកំពង់ឆ្នាំង ព្រលានយន្តហោះកំពង់ឆ្នាំងនេះ។ គាត់និយាយថា នៅកងកន្លែងគាត់នោះមិនជាអីទេ ប៉ុន្តែគាត់មិនដឹងថាកន្លែងផ្សេងយ៉ាងណាទេ។

**លោក ហ៊ឹម ហាន៖**

**ឆ៖** កង១៧ហ្នឹងគឺ មានគ្នាច្រើនដែរ ប្រហែលជា៥០នាក់លើស។ អ៊ីចឹងកងគេផ្សេងក៏គេបានធូរស្រាលទៅ។ ឯក្រុមខ្ញុំ ក្រុមទី១ហ្នឹងគឺលំបាកជាងគេ ធ្ងន់ធ្ងរជាងគេ។ ហើយការផ្ទេរផ្លាស់ប្តូរពីភ្នំពេញមកនោះ គឺគេចម្រាញ់ទុកតែប៉ុន្មានជា៥០នាក់ លើសអីប៉ុណ្ណឹង ឲ្យឈ្មោះថា "កង១៧" តែម្តង។ អ៊ីចឹងកង១៧ហ្នឹង គឺត្រូវបញ្ជូនឲ្យមកធ្វើវាលរវង់កំពង់ឆ្នាំងតាំងពីពេលនោះមក។

[១០:៥២:៤៧]

**ស៖** នៅពេលដែលលោកធ្វើការនៅការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំងនេះ លោកអាចស្តាប់វិទ្យុបានទេនៅពេលនោះ?

**ឆ៖** ស្តាប់បាន តែមិនចំហទេ។ ទាល់តែពេលយាមយប់ហ្នឹងអាចខ្សឹបដាក់នឹងជិតៗខ្លួនបាន។ តែឲ្យបើកចំហស្តាប់ក្នុងរង្វង់មួយរោងហ្នឹងបាន គឺអត់ដែលមានទេ។ ស្តាប់ខ្សឹបៗ នៅនឹងត្រចៀកហ្នឹង។

**ស៖** តើមានអ្នកធ្វើការផ្សេងទៀតដែលធ្វើការជាមួយលោកហ្នឹង ស្តាប់វ៉ាដ្យូដែរទេ?

**ឆ៖** មានតិចណាស់ ពីព្រោះការងារវាហេវហត់ខ្លាំងទៅ គេគិតតែពីសម្រាកទៅ។ លើកលែងតែពេលយាម អាហ្នឹងគេដាស់គ្នាយាម។ តែឲ្យបានមកប្រជុំគ្នាពីរបីនាក់ ហើយអង្គុយស្តាប់ អត់មានទេ។ មានតែម្នាក់ឯង ឬក៏ពីរនាក់ពេលដែលគេផ្លាស់ប្តូរយាមអីតិចតួចប៉ុណ្ណឹង។

**ស៖** តើលោកអាចរៀបរាប់អំពីប្រភេទទំនាក់ទំនង ដែលលោកផ្សាភ្ជាប់ជាមួយនឹងវិស្វករចិននៅនឹងការដ្ឋាននោះបានដែរទេ? តើទំនាក់ទំនងរវាងលោក ហើយនិងចិនន៎ុង តើជាប្រភេទទំនាក់ទំនងអ្វីដែរ?

**ឆ៖** ការទំនាក់ទំនងជាមួយចិននោះ តាមរយៈថីបក។ បើថីបកគេប្រាប់ថាម៉េច យើងធ្វើអ៊ីចឹងទៅ។ ហើយមានពួកនិរតីហ្នឹងចាំពិនិត្យនៅជាមួយយើងទៀត។ ចាំតែចាប់កំហុសយើងហ្នឹង ប៉ុន្តែខ្ញុំធ្វើមិនឲ្យខុសទេ ពីព្រោះថីបកចង្អុលការប្រាប់មក គេធ្វើឲ្យយើងមើលខ្លះទៅ យើងកត់ចំណាំ យើងធ្វើទៅរយៈមួយព្រឹករួច ឬក៏មួយថ្ងៃរួចហ្នឹង ក៏ស្អែកទទួលផែនការពីចិនថែមទៀត។ ហ្នឹងពួកនិរតីហ្នឹងគេត្រួត

ពីលើខ្ញុំហ្នឹងទៀត។

[១០:៥៥:៤៩]

**ស៖** អ៊ីចឹងបានន័យថា លោកជួបចិនហ្នឹងរាល់ថ្ងៃ អ៊ីចឹងឬក៏យ៉ាងណា?

**ឆ៖** បាទ ខ្ញុំជួបរាល់ថ្ងៃ។ លើកលែងតែថ្ងៃសៅរ៍ អាទិត្យ គឺគេចិនអត់មកទេ។ អាហ្នឹងត្រូវអ្នកត្រួតពិនិត្យខ្ញុំហ្នឹង មានពួកនិរតីហ្នឹងគេត្រួតពិនិត្យខ្ញុំធ្វើការងារនៅកន្លែងហ្នឹងប្រចាំថ្ងៃ។

**ស៖** បើតាមការយល់ដឹងអំពីរឿងរ៉ាវនៅសម័យនោះៗ តើលោកអាចយល់ស្របទេថា ជនជាតិចិនហ្នឹងជាអ្នកគ្រប់គ្រងត្រួតត្រាលើការដ្ឋាននៅព្រលានយន្តហោះកំពង់ឆ្នាំងហ្នឹង?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ លោកប្រធាន សំណួរនេះមិនច្បាស់លាស់ទេ ព្រោះថាមានច្រើនថ្នាក់ មានផ្នែកបច្ចេកទេសផង មានផ្នែកសន្តិសុខផង។ អ៊ីចឹងខ្ញុំគិតថា សំណួរនេះមិនអាចទទួលបានចម្លើយច្បាស់លាស់ទេ ព្រោះវាមានច្រើនថ្នាក់ មានច្រើនបែបផែននៅក្នុងសំណួរនេះ។

**សួរដោយលោក អាកឡូរ វ៉ែកគែន៖**

**ស៖** បាទ ខ្ញុំសូមបញ្ជាក់ តើនៅលើការដ្ឋាននោះលោកបែកចែកទំនួលខុសត្រូវ -- តើលោកមើលឃើញយ៉ាងម៉េចដែរវវាងកម្មាភិបាលមកពីភូមិភាគនិរតី និងចិនដែលមកធ្វើការនៅការដ្ឋានព្រលានយន្តហោះហ្នឹង ពួកគេបែងចែកទំនួលខុសត្រូវរវាងពួកគេនោះយ៉ាងណាដែរ?

[១០:៥៧:៥៣]

**លោក ហ៊ីម ហន៖**

**ឆ៖** ផែនការរបស់ចិនក៏គេហៅពួកនិរតីហ្នឹងទៅប្រាប់ ហើយនិរតីហ្នឹងបញ្ជាឲ្យខ្ញុំធ្វើ ជារៀងរាល់ថ្ងៃអ៊ីចឹង លើកលែងតែថ្ងៃសៅរ៍ អាទិត្យ ដែលចិនមិនមក។

**ស៖** ក៏ប៉ុន្តែលោកបានឆ្លើយផងដែរថា នៅក្នុងសប្តាហ៍នុ៎ង គឺចិនជាអ្នកណែនាំលោក តើលោកបាននិយាយអ៊ីចឹងមែនទេ?

**ឆ៖** ពាក្យហ្នឹងអ៊ីចឹងមែន តែម្តងម្កាលទេ មិនបានជាប្រចាំទេ។

**ស៖** ពីរបីនាទីមុននេះ លោកបាននិយាយថា មានការប្រជុំរាល់ថ្ងៃជាមួយជនជាតិចិន។ តើមក

ពីការបកប្រែខុស ឬក៏លោកពិតជាបាននិយាយអ៊ីចឹងមែន?

**ឆ៖** ការងារហ្នឹងបកប្រែខុសទេ ខ្ញុំមិនដែលបានប្រជុំអីជាមួយចិនទេ។ សូម្បីតែអ្នកដែលមកត្រួតត្រាខ្ញុំពួកនិរតីក៏គេមិនដែលទៅប្រជុំផង។ បើសិនណាជាគេហៅ គេវ៉ៃជួងម៉ឹងមក យើងរត់ចូលជួរ គេប្រាប់ថាទៅធ្វើនៅកន្លែងនេះ ក្រុមនេះទៅធ្វើនោះ ក្រុមនោះទៅធ្វើខាងណោះ តែប៉ុណ្ណឹងឯង។ តែឲ្យប្រជុំជុំធំដុំ មានចិនមានអីមកផ្សព្វផ្សាយ គឺខ្ញុំអត់ដែលបានទទួលការអប់រំហ្នឹងទេ។ អត់ដែលបានចូលប្រជុំទេ។

**សៈ** ហើយជួងដែលគេវ៉ៃហ្នឹង វ៉ៃសម្រាប់តែកងលោកទេ ឬក៏សម្រាប់កងផ្សេងៗទៀតដែលធ្វើការនៅការដ្ឋានហ្នឹង?

**ឆ៖** តាមកង តាមរោងនីមួយៗហ្នឹង គឺមួយរោងមានមួយ។ ជួនកាលក៏គេស្តាប់គ្នារោងមួយរោងពីរទៅ គេដាក់ជួងមួយហ្នឹងទៅ។ ឯក្រុមខ្ញុំហ្នឹង គឺមានជួងមួយដោយឡែកពីគេ។ តែមានការ គេវាយជួង គេមិនមកដាស់យើងផ្ទាល់ទេ គេវាយតែជួងហ្នឹង។ ដល់វាយជួងថ្មើរណា ក៏ត្រូវតែងើបប្រជុំជួរថ្មើរហ្នឹង មានសម្ភារៈធ្វើការងារប្រចាំថ្ងៃហ្នឹង គឺនៅជាប់ខ្លួន។

[១១:០១:១០]

**សៈ** លោកអាចជម្រាបជូនតុលាការបានដែរឬទេ ថានៅសម័យនោះ លោកមានពាក់ឯកសណ្ឋានយោធាដែរឬទេ ពេលដែលលោកធ្វើការនៅការដ្ឋានហ្នឹង? គឺខ្ញុំចង់និយាយថាទាំងលោក ហើយនិងទាំងអ្នកធ្វើការផ្សេងទៀតនៅការដ្ឋានហ្នឹង។

**ឆ៖** ចំពោះសម្លៀកបំពាក់យោធា គឺមានតែអ្នកត្រួតពិនិត្យខ្ញុំទេ ដែលថាខាងពួកនិរតីតែប៉ុណ្ណោះទេ ខាងយោធា។ ឯចំនួនខាងពួកខ្ញុំ គឺស្លៀកពាក់ខោខ្មៅ អាវខ្មៅ។

**សៈ** ហើយអ្នកត្រួតមើលហ្នឹងមកពីខាងណាដែរ មកពីភូមិភាគជាមួយនឹងលោកដែរ ពីភូមិភាគលោក ឬភូមិភាគណា?

**ឆ៖** បាទ សូមជម្រាបលោក មកពីភូមិភាគនិរតី។

**សៈ** ម្សិលមិញនៅពេលដែលគេសួរលោកនោះ លោកបានឆ្លើយថា លោកបានកត់សម្គាល់ឃើញថា នៅក្នុងចំនួនមនុស្សដែលធ្វើការនៅការដ្ឋាននោះ គឺថាស្រីៗបាត់ខ្លួនយ៉ាងឆាប់រហ័ស។ ហើយម្សិលមិញនេះនៅក្នុងសាលសវនាការដដែលហ្នឹង យើងបានឮសាក្សីម្នាក់ដែលនៅក្នុងកងពល៣១០ដែរ ហើយត្រូវបានបញ្ជូនទៅការដ្ឋានកំពង់ឆ្នាំងហ្នឹងដែរ គាត់បាននិយាយថា មានវត្តមានស្ត្រី។ ខ្ញុំសូម

ដកស្រង់ សាក្សីមួយទៀតដែលមិនបានផ្ដល់សក្ខីកម្មនៅទីនេះទេ។ ក៏ប៉ុន្តែគាត់បានពិពណ៌នាអំពីវត្តមានស្ត្រីនៅការដ្ឋានហ្នឹង គឺឯកសារ 19.149 ERN ជាភាសាខ្មែរគឺ 00054136, ជាភាសាបារាំងគឺ 00829678, ជាភាសាអង់គ្លេស 00821981។ បាទ សំណួរខ្ញុំដូចតទៅនេះ តើលោកនៅតែរក្សាចម្លើយរបស់លោកដែរឬទេ គឺថាអត់មានស្ត្រីនៅលើការដ្ឋាននោះទេ ស្ត្រីហ្នឹងបាត់ខ្លួនយ៉ាងឆាប់រហ័ស លោកនៅតែរក្សាចម្លើយរបស់លោកដែរឬទេ?

[១១:០៤:១៣]

**ឆ៖** សូមបញ្ជាក់ រឿងស្ត្រីនៅកន្លែងខ្ញុំគ្មានទេ តែកន្លែងគេមាន។ ខ្ញុំសូមបញ្ជាក់ជូនថា ដូចជាស្ត្រីនៅភូមិភាគបូព៌ាហ្នឹង គឺមានច្រើនដែរ។ ឯខាងភូមិភាគឧត្តរ ខ្ញុំមិនដែលឃើញ ប្រហែលជាគេនៅចុងឯលិចនោះក៏មិនដឹង អីក៏មិនដឹង ខ្ញុំអត់ដែលជួបទេ។ ឯម្ដុំខ្ញុំហ្នឹងខាងយុទ្ធជនប្រុសៗហ្នឹង គឺក្រុមខ្ញុំហ្នឹង គឺអត់មានស្រីលាយទេ។ បញ្ជាក់ជូនប៉ុណ្ណឹង។

**ស៖** បាទ ខ្ញុំសួរជិតចប់ហើយ។ នៅពេលដែលលោកធ្វើការនៅលើព្រលានយន្តហោះកំពង់ឆ្នាំងហ្នឹង តើលោកត្រូវជួបប្រជុំរៀនសូត្រអីដែរឬទេនៅទីនោះ?

**ឆ៖** មិន -- ខ្ញុំមិនបានចូលរួមប្រជុំ ឬក៏ស្ដាប់ការផ្សព្វផ្សាយប្រជុំអីទេ អត់មានទេប៉ុន្មានឆ្នាំហ្នឹងអត់មានទេ។

**ស៖** អ៊ីចឹងតើយើងអាចសន្និដ្ឋានបានដែរឬទេថា លោកនៅទីនោះៗគឺដើម្បីលត់ដំ រៀនសូត្រដោយមិនចាំបាច់មានជំនួយពីខាងក្រៅទេ។ តើការនិយាយយ៉ាងដូច្នេះលោកយល់ស្របនឹងខ្ញុំដែរឬទេ?

**ឆ៖** ការលត់ដំហ្នឹង ខ្ញុំទទួលស្គាល់ទាំងស្រុង ឯផ្សេងៗទៀតខ្ញុំអត់ទទួលស្គាល់ទេ។ ព្រោះការងារខ្ញុំហ្នឹងវាគ្មានអីត្រូវមានស្រួលទេ មានតែលំបាក ព្រោះពលកម្មហ្នឹងវាក្ដៅគគុក។ ជម្រាបលោកម្ដងហើយម្ដងទៀតថា មានតែរែកដី កាប់គាស់ដី គាស់គល់ឈើ ជញ្ជូនថ្ម ពង្រាបថ្ម មានតែប៉ុណ្ណោះឯង។ ហើយពេលវេលាអត់ថាយប់ អត់ថាថ្ងៃទេ ឲ្យតែជួងរ៉ៃធ្វើរណា គឺរៀបចំខ្លួនទៅធ្វើរហ្នឹង។ មិនថាភ្លៀងទេ ម៉េចក៏ដោយ ឲ្យគេតែហៅគឺទៅធ្វើរហ្នឹងហើយ។ មិនបាច់សួរនាំថា ទៅណាៗអីអត់បាត់ទេ ចាប់ផ្ដើមគឺគេនាំយើងទៅហើយ។ ទៅដល់កន្លែងគេដើរចេញ ហើយយើងមិនបានតាមដាន តាមអីមើលគេថា គេទៅជ្រកនៅកន្លែងណាត្រង់ណា អត់ទេ។ តែទៅធ្វើហើយ គេឲ្យណែនាំឲ្យធ្វើម៉េចគឺធ្វើអ៊ីចឹងទៅ។ តែបញ្ជាក់ជូនដែរ ពេលយប់ធ្វើតែ៤ម៉ោងទេ ឬក៏មិនដល់៤ម៉ោងទេ ឯថ្ងៃគឺ៨ម៉ោងពេញ។

[១១:០៧:៤០]

**ស៖** តើនៅសម័យនោះលោកមានដឹងអំពីការសម្ងាត់នៃការកសាង ឬព្រលានយន្តហោះហ្នឹង ឬក៏ដូចជាការជីករូងក្នុងភ្នំហ្នឹង ដើម្បីលាក់យន្តហោះដែរឬទេ? លោកមានដឹងពីថា កាលណោះគេធ្វើហ្នឹងគឺក្នុងការងារសម្ងាត់បំផុត?

**ឆ៖** ការងារម្ងាត់ ខ្ញុំអត់ដឹងទេ។ ខ្ញុំដឹងតែពលកម្មនៅឯខាងក្រៅឯណោះ។ ដឹងគេជីកលាក់ឯណាផង ខ្ញុំអត់ដឹង។

**លោក អាកទួរ វែកកែន៖**

លោកប្រធាន ខ្ញុំសួរចប់ហើយលោកប្រធាន ក៏ប៉ុន្តែសហភាតាខ្ញុំគឺលោកមេធាវី គង់ សំអុន មានសំណួរមួយចំនួនសួរទៅសាក្សីលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពអង្គជំនុជម្រះ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** សូមជម្រាបសួរលោក ហ៊ុម ហន។ ខ្ញុំមានសំណួរចង់បញ្ជាក់លោកទាក់ទងទៅនឹងការងាររបស់លោកនៅការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង។ តែដំបូងខ្ញុំចង់សួរពីរឿងក-១៧ ដែលលោកមានប្រសាសន៍ថា ជាកងរបស់លោក។ កង១៧នេះ ថាតើកង១៧នេះបង្កើតនៅកំពង់ឆ្នាំង ឬក៏បង្កើតនៅពីភ្នំពេញហើយបញ្ជូនទៅកំពង់ឆ្នាំង?

**លោក ហ៊ុម ហន៖**

**ឆ៖** គេបង្កើតនៅអន្លង់ក្ងាន។

**ស៖** បាទ សូមអរគុណ។ មានរចនាសម្ព័ន្ធយ៉ាងម៉េចដែរ? អ្នកណាជាអ្នកដឹកនាំកង១៧ហ្នឹង?

[១១:១០:០៩]

**ឆ៖** អ្នកដឹកនាំក្នុងកង១៧ហ្នឹង រាប់ពីមេក្រុមឡើងទៅគឺនៅនិរតីទាំងអស់។ ខ្ញុំអត់ស្គាល់ឈ្មោះគេទេ ហើយក៏មិនបានតថ្លៃ មើលមុខគេដែរកាលនោះ។

**ស៖** បាទ សូមអរគុណ។ គេបង្កើតបានប៉ុន្មានរយៈពេលប៉ុន្មានដែរនៅអន្លង់ក្ងានហ្នឹង មុនពេលដែលបញ្ជូនទៅការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង?

**ឆ៖** ប្រហែលជាមិនដល់៣ខែទេ ក៏គេចាប់ផ្ដើមបញ្ជូនខ្ញុំទៅកំពង់ឆ្នាំងតែម្ដង ហើយខ្ញុំគ្រាន់តែដឹងថា អញគេដកចេញពីកងវរសេនាធំ១២ហើយ ឲ្យមកនៅកង១៧វិញ។ អ៊ីចឹងលែងបាននៅក្នុងជួរទ័ពវរសេនាធំ១២ហើយ មកនៅកង១៧ដែលត្រៀមខ្លួនគោរពការងារតាមវិន័យ តាមគេចាត់តាំង។ ហើយបញ្ជាក់ផងដែរថា តាំងពីបង្កើតកង១៧ហ្នឹងមក សូម្បីតែមេក្រុមហ្នឹងក៏ខាងនិរតីដែរ។ មេក្រុម មេកងឡើងទៅខាងនិរតីទាំងអស់។ ឯរូបខ្ញុំកាលមុនវាមានតួនាទីខ្លះៗពិតមែន តែមកដល់ចូលដល់កង១៧ នេះគឺគ្មានតួនាទីអ្វីទេ ជាកម្លាំងពលកម្ម ជាកម្មករ ពលករប៉ុណ្ណឹងទេ។

**ស៖** បាទ សូមអរគុណ។ លោកបានបញ្ជាក់ពីព្រឹកមិញថា នៅក្នុងកង១៧នេះមានគ្នាប្រមាណ៥០នាក់។ តើ៥០នាក់លោកនិយាយហ្នឹងសំដៅ៥០នាក់ពីអន្លង់ក្ងានទៅរហូតទៅដល់កំពង់ឆ្នាំងនោះ ឬក៏មានការផ្លាស់ប្ដូរចំនួន?

[១១:១២:១២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

ខ្ញុំគិតថាមានការបកប្រែខុស ព្រោះថាអម្បាញ់មិញនេះយើងបានឮនិយាយ សាក្សីនិយាយថាមាន៥០នាក់នៅក្នុងកង១៧នុ៎ង។ ហើយនៅអម្បាញ់ -- ស្រាប់តែឥឡូវនេះឮថា១៥នាក់ចេញពីអ្នកបកប្រែមកនោះ។ អ៊ីចឹងខ្ញុំគិតថាប្រហែលមានបញ្ហាបកប្រែ ព្រោះថាពីមុនឮ៥០ ឥឡូវឮ១៥វិញ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណ។ ខ្ញុំនិយាយ៥០នាក់អម្បាញ់មិញណ៎ា។

**សួរដោយលោក គង់ សំអុន៖**

**ស៖** លោកសាក្សីអាចឆ្លើយបានទេ?

**លោក ហ៊ឹម ហាន៖**

**ឆ៖** ឆ្លើយលេខបាន ចំនួនមនុស្ស តែឈ្មោះឆ្លើយអត់បាន ភ្លេចអស់ហើយ។

**ស៖** បាទ សូមអញ្ជើញទាក់ទងនឹងចំនួន។ សំណួររបស់ខ្ញុំគឺថា តើ៥០នាក់ដែលលោកបញ្ជាក់ហ្នឹង គឺជាសមាជិកក្នុងកង១៥ពីអន្លង់ក្ងានទៅ រហូតទៅដល់ការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង ជាចំនួនដដែល ឬក៏មានចំនួនផ្លាស់ប្ដូរ តួលេខផ្លាស់ប្ដូរ?

[១១:១៣:៤៦]

**ឆ៖** ពេលប្រជុំជួរ គេប្រកាសប្រាប់ថា យើងមានគ្នា៥០នាក់ទៅធ្វើវាលវង់កំពង់ឆ្នាំងហ្នឹង។ ខ្ញុំក៏រៀបចំខ្លួន ទាំងគេ ទាំងខ្ញុំរៀបចំខ្លួនឡើងឡានមកមានចំនួនប្រាំឡាន។ លុះមកដល់វាលវង់យន្តហោះហ្នឹងក៏បំបែកគ្នាអស់ទៅ។ ហើយឯផ្សេងទៀត គឺមិនមានអីទៀតទេ មានតែប៉ុណ្ណឹង។

**ស៖** លោកអាចបញ្ជាក់បានទេ នៅពេលដែលបំបែកខ្លួនហ្នឹង មានន័យថាម៉េច? បំបែកនៅក្នុងកង១៧តែមួយ គ្រាន់តែស្នាក់នៅកន្លែងខុសគ្នា ឬមួយក៏ធ្វើការជាមួយគ្នាដដែលទេ នៅពេលដែលទៅដល់ព្រលានកំពង់ឆ្នាំងហ្នឹង?

**ឆ៖** ឈ្មោះកងតែមួយ តែកន្លែងស្នាក់ និងកន្លែងធ្វើការដោយខ្លួន។

**ស៖** បាទសូមអរគុណ។ ទាក់ទងទៅនឹងមេដឹកនាំ ថ្នាក់ដឹកនាំ ដែលលោកនិយាយថាជាពួកនិរតីពីថ្នាក់ក្រោមឡើងទៅ ក្នុងក្រុមរបស់លោកហ្នឹងមាន ក្នុងកង១៧ហ្នឹងមានប៉ុន្មានក្រុម? ហើយថ្នាក់ដឹកនាំដែលជាអ្នក ជានិរតីហ្នឹងមានប៉ុន្មាននាក់ដែរ?

**ឆ៖** សូមបញ្ជាក់ជូនថា រាប់ពីប្រធានក្រុមឡើងទៅតែម្តង។

**ស៖** បាទ សូមអញ្ជើញ!

**ឆ៖** ពួកនិរតីគ្រប់គ្រងខ្ញុំ រាប់ពីប្រធានក្រុមឡើងទៅតែម្តង។

**ស៖** ខ្ញុំចង់ដឹងថា តើមានចំនួនមនុស្សប៉ុន្មាននាក់ ចាប់ពីក្រុមឡើងទៅហ្នឹង ដែលជាអ្នកនិរតីហ្នឹង? មានឧទាហរណ៍ថា បើចែកជាបីក្រុម វាអាចមានបីនាក់។ បើមានអនុប្រធានទៀត អនុប្រធានម្នាក់ ឬក៏ពីរនាក់ អ៊ីចឹងសូមឲ្យលោកបញ្ជាក់ពីចំនួនឲ្យច្បាស់លាស់មើល៍។

**ឆ៖** ព្រោះមួយកងវាមានបីនាក់ ហើយក្នុងមួយកង១៧ហ្នឹង វាមានប្រាំបួនក្រុម។ អ៊ីចឹងក្នុងមួយក្រុមមានម្នាក់។ អ៊ីចឹងមានប្រាំបួននាក់ ហើយមេវាធំជាងគេមួយទៀត គ្រប់១០។ តែឈ្មោះ ខ្ញុំអត់ដឹងទេ អត់បានសួរគេទេ។

[១១:១៧:០៩]

**ស៖** បាទ សូមអរគុណ។ លោកបានសង្កេតឃើញអ្វីខុសប្លែកគ្នារវាងមេក្រុមរបស់លោក ហើយនិងក្រុមសមាជិកក្រុម ជាអ្នកនិរតី ហើយនិងក្រុមរបស់លោកក្នុងកង១៧ហ្នឹង? មានអ្វីដែលលោកអាចមើលឃើញពីភាពខុសគ្នាទេ?

**ឆ៖** មានត្រង់រើសអើង។ គេកំណត់យើងថា ជាជនក្បត់ ហើយគេត្រួតត្រា។ គេមិនដែល

និយាយភាសាស្លូតបូតទេ មានតែម៉ាត់ណាម៉ាត់ហ្នឹង។ ឲ្យធ្វើអី គឺត្រូវធ្វើឲ្យហើយ។ បើប៊ិានតថ្លៃ យើងមានទោស ឬបាត់ខ្លួន។ ប៉ុន្តែកងខ្ញុំទាំងអស់ដែលនៅជិតគ្នានុ៎ង មិនដែលពីណាប៊ិានតថ្លៃ ឬក៏បញ្ជាក់ដោយប្រការណាមួយទេ។ ប្រើអី គឺទៅធ្វើហ្នឹងហើយ។ ធ្វើមិនរួច ធ្វើល្ងាចទៀត ល្ងាចមិនរួច ធ្វើយប់ទៀត ធ្វើទាល់តែរួចការងារហ្នឹង។ អ៊ីចឹងខ្ញុំមិនមានអីវែងឆ្ងាយទៀតទេ ប៉ុណ្ណឹង។

**ស៖** បាទ សូមអរគុណ។ ពីព្រឹកមិញ ក៏លោកបានបញ្ជាក់ផងដែរ អំពីការដែលលោកខ្លាចចំពោះក្រុមមេដឹកនាំក្នុងក្រុម ហើយនិងមេកងរបស់លោក។ រហូតដល់លោកនិយាយថា លោកមិនប៊ិានសម្លឹងមើលមុខ ដោយសារការមើលមុខ អាចគេយកទៅសម្លាប់។ ហើយចំណុចមួយទៀត លោកបញ្ជាក់អំពីអ្នកទាំងអស់នុ៎ងមិនចេះអក្សរ ហើយដែលលោកបានបញ្ជាក់រហូតដល់លោកអាចប្តូរឈ្មោះរបស់លោកបានទៀត។ សំណួររបស់ខ្ញុំ ខ្ញុំចង់សួរបន្ថែមថា តើពាក្យសម្តីអ្វីខ្លះ ឬអំពើអ្វីខ្លះ ដែលធ្វើឲ្យលោកខ្លាចទៅលើមេក្រុមរបស់លោក ឬក៏អ្នកនិរតីដែលជាអ្នកដឹកនាំក្នុងក្រុម ក្នុងកងរបស់លោក? អ្វីខ្លះជាអំពើជាក់ស្តែងដែលបានធ្វើចំពោះលោក?

[១១:២០:០៤]

**ឆ៖** ពាក្យគេ គេប្រាប់យើងថា ចង់រស់ ឬចង់ងាប់។ បើចង់ងាប់ គិតតាមងាប់។ បើចង់រស់ខំធ្វើការ។ មានតែប៉ុណ្ណឹង។ ហើយការដែលមិនស្គាល់អក្សរហ្នឹង ខ្ញុំស្គាល់។ ខ្ញុំ -- ព្រោះសូម្បីតែសរសេរក៏សរសេរមិនកើតផង។ ចាប់ប៊ិកចាប់អី ចាប់តាពីសតាពាស។ ខ្ញុំកំណត់ថា អ្នកនេះអត់ចេះអក្សរទេ ហើយអ្នកនេះអត់សរសេរកើតទេ។ ហ្នឹងខ្ញុំសម្គាល់បាន។ ត្រង់ហ្នឹងបានជា ខ្ញុំកែប្រវត្តិរូបខ្ញុំបាន។ ហើយខ្ញុំមិនបាននៅយឺតៗទេ ភ្លាមៗមួយពព្រិចភ្នែកហ្នឹង ខ្ញុំកែបានភ្លាម ដើរចេញបាត់។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងខ្ញុំអាចសង្ខេបបានទេថា លោក សម្រាប់ខ្លួនលោកផ្ទាល់ទទួលនូវការគំរាមកំហែងពីមេក្រុម និងមេកងទាំងនោះ។ ត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ។ មិនត្រឹមតែរូបខ្ញុំទេ គ្នាខ្ញុំទាំងឡាយក៏ជួបប្រទះពាក្យមិនសប្បុរសហ្នឹងញឹកញាប់។

**ស៖** បាទ សូមអរគុណ។ មានអំពើអ្វីផ្សេងទៀតដែលទាក់ទងទៅនឹងការគំរាមកំហែងទេ ដែលលោកនិយាយពីដើមមកថា បើសិនជាប៊ិានឆ្លងកន្លងដែលគេឲ្យនៅធ្វើការនៅកន្លែងណាហ្នឹង អាហ្នឹងអាចគេសម្លាប់ចោល? ហើយតើមានករណីដែលជាការរំលោភបំពានណាមួយដែលត្រូវគេដាក់វិន័យ ជាការធ្វើទារុណកម្ម ឬការយកទៅសម្លាប់ដែរទេ ក្នុងពេលដែលលោកធ្វើការនៅការដ្ឋានព្រលានយន្តហោះ

កំពង់ឆ្នាំងហ្នឹង?

**ឆ៖** ពេលមួយ មិត្តខ្ញុំប្រាប់ខ្ញុំថា "កងនុំង គ្រាន់តែដើរឆ្លងទៅត្រង់ណោះ ឥឡូវគេចាប់យកទៅបាត់ហើយ"។ អ៊ីចឹងឃើញរូបភាពយ៉ាងនេះ ពួកខ្ញុំហ្នឹងមកប្រាប់ណែនាំគ្នា ខ្សឹបៗទៅ ពេលសម្រាកហ្នឹងថា "កុំណា ប្រយ័ត្នងាប់! តែឆ្លងទៅ ងាប់ហើយ។" អ៊ីចឹងមិនហ៊ានឆ្លងទេ គេឲ្យធ្វើត្រង់ណា គឺធ្វើត្រង់ហ្នឹង។ ឲ្យសម្រាកត្រង់ណា គឺសម្រាកត្រង់ហ្នឹង។ សូម្បីតែនៅជិតដើមឈើ ក៏មិនហ៊ានទៅជ្រកផង។

[១១:២៣:០០]

**ស៖** បាទ សូមអរគុណ។ ចុះទាក់ទងទៅនឹងការភ័យខ្លាចក្នុងការដែលលោកមិនហ៊ានសម្លឹងមើលភ្នែករបស់មេក្រុម ឬក៏មេកងដែលជាអ្នកនិរតីនោះ។ តើវាមានឥទ្ធិពលយ៉ាងម៉េចក្នុងការងារ ឬក៏ក្នុងការរស់នៅជាក់ស្តែងនៅពេលដែលលោកធ្វើការនៅព្រលានយន្តហោះនោះដែរទេ?

**ឆ៖** សកម្មភាពគេខុសពីយើងធម្មតា។ ទី១ គឺគេមិននិយាយលេងជាមួយនឹងយើង ឬក៏រាក់ទាក់ជាមួយនឹងយើងរឿងការងារ យ៉ាងម៉េចៗ គឺគេមិនៗៗ រវេរវល់នឹងយើងទេ។ បើគេប្រើថា មិត្តឯងនាំគ្នាប៉ុណ្ណោះនាក់ទៅធ្វើអានេះឲ្យហើយ។ អាហ្នឹងខំប្រឹងធ្វើឲ្យទាល់តែហើយទៅ។ បើមិនហើយមកឲ្យម្នាក់មកប្រាប់ថា មិនទាន់ហើយទេ។ គេគ្រាន់តែប្រាប់ បើមិនហើយទេ ល្ងាចត្រូវធ្វើឲ្យហើយ។ តែប៉ុណ្ណឹង។ ឲ្យមកសួរថា យ៉ាងម៉េចយ៉ាងម៉ា ត្រូវហេវហត់ អស់កម្លាំង ដោយប្រការណាមួយគឺគេមិនបែរមុខមករកមើលយើងផង។ ហើយសម្តីសំដៅគេទៀត គឺមិនមានល្អូកល្អិនទេ គឺម៉ាត់ណាម៉ាត់ហ្នឹង។

**ស៖** លោកចង់និយាយទៀតទេ? បើអត់ខ្ញុំអស់សំណួរ លោកសាក្សី។

**លោក គង់ សំអុន៖**

លោកប្រធាន ខ្ញុំអស់សំណួរ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកមេធាវី។ សវនាការស្តាប់សក្ខីកម្ម ហ៊ីម ហាន ដល់ទីបញ្ចប់ហើយ ហើយសវនាការបន្តនៅរសៀលនេះ បន្ទាប់ពីសម្រាក អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-247 សូមភាគីជ្រាប។

អង្គជំនុំជម្រះអរគុណលោក ហ៊ីម ហាន ដែលបានចំណាយពេលវេលាដ៏មានតម្លៃមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះក្នុងឋានៈជាសាក្សី ក្នុងរយៈពេលពីរថ្ងៃកន្លងមកនេះ។ ហើយសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។ ការផ្តល់សក្ខីកម្មរបស់លោកដល់ទី

បញ្ចប់ហើយ សូមលោកមានសំណាងល្អ ហើយមានសេចក្តីសុខចម្រើន និងធ្វើដំណើរវិលត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីរូបនេះវិលត្រឡប់ទៅវិញ។ ហើយឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយកន្លះរសៀល សូមអញ្ជើញចូលវិញ និងបន្តកិច្ចដំណើរការសវនាការ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់សម្រាកខាងក្រោមសាលសវនាការនេះ ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សូមអញ្ជើញសម្រាក!

*(សវនាការសម្រាកពីម៉ោង ១១:២៦ នាទី ដល់ម៉ោង ១៣:២៩ នាទី)*

[១៣:២៩:១៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ បង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-247 រួមទាំងបុគ្គលិកអង្គការ ធី.ភី.អូ លោកស្រី ឆាយ ម៉ារីដែន ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការ។

*(ដើមបណ្តឹងរដ្ឋប្បវេណីចូលមកកាន់បន្ទប់សវនាការ)*

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី! តើលោកស្រីឈ្មោះអី?

**លោកស្រី ជុំ សាមឿន៖**

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ស៖** លោកស្រីចាំភ្លើងមីក្រូហ្វូនប្រតិបត្តិការចេញពណ៌ក្រហមចាំលោកស្រីឆ្លើយបាទ។

**ឆ៖** ខ្ញុំឈ្មោះ ជុំ សាមឿន។

[១៣:៣១:៤៩]

**ស៖** លោកស្រីកើតនៅថ្ងៃណា ខែណា ឆ្នាំណាដែរ?

**ឆ៖** ខ្ញុំកើតខែ -- ថ្ងៃ០៤ ខែ៣ ឆ្នាំ១៩៦០។

**ស៖** លោកស្រីកើតនៅទីកន្លែងណា?

**ឆ៖** ខ្ញុំកើតនៅភូមិព្រេច ឃុំឈូក ស្រុកឈូក ខេត្តកំពត។

**ស៖** ទីលំនៅសព្វថ្ងៃរបស់លោកស្រីនៅឯណាដែរ?

**ឆ៖** ទីលំនៅសព្វថ្ងៃនៅភូមិទ្វីខាងត្បូង ឃុំអណ្តូងខ្មែរ ស្រុកកំពង់បាយ ខេត្តកំពត។

**ស៖** ឪពុកបង្កើតរបស់លោកស្រីឈ្មោះអី? ហើយនិងម្តាយបង្កើតរបស់លោកស្រីបាទ?

**ឆ៖** ឪពុកបង្កើតខ្ញុំឈ្មោះ ជុំ ជៀន ម្តាយខ្ញុំឈ្មោះ ពៅ អួន។

**ស៖** ចុះប្តីលោកស្រីឈ្មោះអីដែរ? ហើយលោកស្រីមានកូនប៉ុន្មាននាក់?

**ឆ៖** ប្តីខ្ញុំ រីត ច្រិក។ ខ្ញុំមានកូនប្រាំនាក់។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រី ជុំ សាមឿន។ ក្នុងឋានៈលោកស្រីជាដើមបណ្តឹងរដ្ឋប្បវេណី ជាចុងក្រោយបង្អស់នៃការផ្តល់សក្ខីកម្មរបស់លោកស្រី លោកស្រីមានសិទ្ធិថ្លែងរៀបរាប់ពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មដែលកើតមានឡើងចំពោះលោកស្រី នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រសិនបើលោកស្រីមានបំណងធ្វើដូច្នេះ។

ដោយអនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះផ្តល់វេទិកាជូនសហមេធាវីមុខនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន មុនភាគីដទៃទៀតនៃរឿងក្តី។ ហើយអង្គជំនុំជម្រះសូមបញ្ជាក់ថា មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី រួមទាំងសហព្រះរាជអាជ្ញាមានវេលាមួយវគ្គនៃថ្ងៃសវនាការក្នុងការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី!

[១៣:៣៤:៤២]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៏៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមអនុញ្ញាតប្រគល់វេទិកានេះជូនសហភាតារបស់ខ្ញុំគឺលោកស្រីមេធាវី ម៉ុច សុវណ្ណារី។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី!

**លោកស្រី ម៉ុច សុវណ្ណារី៖**

ចាស សូមអរគុណ។ ជាដំបូងនាងខ្ញុំសូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ភាគី និងអង្គសវនាការទាំងមូល ហើយសូមជម្រាបសួរអ្នកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ម៉ុច សុវណ្ណារី៖**

**ស៖** ខ្ញុំមានសំណួរមួយចំនួនដើម្បីសួរដល់អ្នកស្រី ហើយសូមអរគុណទុកជាមុនចំពោះការឆ្លើយនឹងសំណួររបស់ខ្ញុំ។ ជាដំបូងខ្ញុំចង់សួរអ្នកស្រីថា នៅមុនឆ្នាំ១៩៧៥ តើអ្នកស្រីរស់នៅទីកន្លែងណាដែរ? ហើយអ្នកស្រីបានធ្វើអ្វីខ្លះ?

**លោកស្រី ជុំ សាមឿន៖**

**ឆ៖** មុនឆ្នាំ៧៥ គឺខ្ញុំរស់នៅភូមិត្រពាំងរាំង ឃុំឈូក ស្រុកឈូក។ កាលនោះខ្ញុំនៅជាវ័យកុមារនៅឡើយទេចាស។

[១៣:៣៦:០១]

**ស៖** សូមអរគុណអ្នកស្រី។ នៅក្នុងឆ្នាំ១៩៧៣ តើអ្នកស្រីបានធ្វើអ្វី -- អ្នកស្រីធ្វើការងារអ្វីដែរ?

**ឆ៖** មុនឆ្នាំចិត-- ក្នុងឆ្នាំ៧៣ គឺខ្ញុំរស់នៅកងពលលេខ១១ ខ្ញុំទើបមានអាយុ១៣ឆ្នាំ។ ខ្ញុំនៅទីនោះគឺគេឲ្យខ្ញុំរែកបាយស្នូក។

**ស៖** ចាស សូមអរគុណអ្នកស្រី។ អ៊ីចឹងមានន័យថា នៅពេលដែលអ្នកស្រីអាយុ១៣ឆ្នាំនៅក្នុងឆ្នាំ១៩៧៣ អ្នកស្រីបានចូលរួមជាមួយនឹងកងទ័ពខ្មែរក្រហមនៅក្នុងកងពលលេខ១១។ អ្នកស្រីអាចបញ្ជាក់បានទេ ថានៅពេលនោះ តើកងពលនោះឈរនៅទីតាំងណាដែរ?

**ឆ៖** នៅក្នុងស្រុកកោះធំ ខេត្តកណ្ដាលចាស។

**ស៖** តើអ្នកស្រីអាចជម្រាបជូនបានទេថា ប្រធានកងពលលេខ១១ នោះគាត់មានឈ្មោះអ្វីដែរ?

**ឆ៖** គាត់មានឈ្មោះ កៅ សំអុន។

**ស៖** ចាស សូមអរគុណអ្នកស្រី។ តើអ្នកស្រីអាចដឹងបានទេ ហើយបញ្ជាក់បានទេថាកងពលលេខ១១ របស់ស្រីហ្នឹងស្ថិតនៅក្រោមការគ្រប់គ្រងរបស់ភូមិភាគណាដែរ?

**ផ៖** ចាស ខ្ញុំអត់បានដឹងនៅភូមិភាគណាទេ ចាស។

**ស៖** ចាស សូមអរគុណអ្នកស្រី។ អ្នកស្រីអាចជម្រាបជូនតុលាការបានទេថា នៅពេលនោះតើមូលហេតុអ្វីបានជាអ្នកស្រីចូលរួមបម្រើឲ្យកងទ័ពខ្មែរក្រហម?

**ផ៖** កាលហ្នឹងពេលដែលខ្ញុំទៅចូលកងទ័ពបម្រើខ្មែរក្រហម គឺខ្ញុំដឹងថាគេថាទៅរំដោះសម្តេចឪ ខ្ញុំក៏ទៅតាមគេទៅ។

[១៣:៣៩:០១]

**ស៖** ចាសសូមអរគុណអ្នកស្រី។ អម្បាញ់មិញអ្នកស្រីបានបញ្ជាក់ថា នៅពេលដែលអ្នកស្រីចូលរួមបម្រើឲ្យកងទ័ពខ្មែរក្រហម នៅពេលនោះគេឲ្យអ្នកស្រីជញ្ជូនបាយ។ តើអ្នកស្រីអាចរៀបរាប់ពីការងារដែលអ្នកស្រីដែលត្រូវធ្វើជាប្រចាំថ្ងៃបានទេ? ថាតើអ្នកស្រីត្រូវជញ្ជូនស្បៀង ជញ្ជូនបាយហ្នឹងទៅឲ្យអ្នកណា? ហើយពីកន្លែងណា? ហើយទៅកន្លែងណាដែរ?

**ផ៖** ចាស ពេលគេឲ្យខ្ញុំជញ្ជូនបាយស្ទុកហ្នឹងពី – ខ្ញុំអត់បានចាំភូមិទេ តែគេឲ្យជញ្ជូនយកទៅកន្លែងម្តុំភូមិ ម្តុំជិត គេហៅទួលក្រសាំងហ្នឹងចាស។

**ស៖** ចាស សូមអរគុណអ្នកស្រី។ អ្នកស្រីអាចបញ្ជាក់បានទេថាទីតាំងដែលអ្នកស្រីត្រូវបញ្ជូនបាយស្ទុកទៅនោះ តើទីនោះកំពុងជាសមរភូមិដែលគេកំពុងតែច្បាំងគ្នា ឬក៏យ៉ាងណាដែរ?

**ផ៖** ពេលដែលខ្ញុំជញ្ជូនបាយទៅ ខ្ញុំមានមួយថ្នាក់ទៀត ខ្ញុំយកទៅខាងក្រោយទេ ខ្ញុំអត់បានដល់ជួរមុខទេចាស គេមានគេមកទទួលនៅកន្លែងខ្ញុំមួយថ្នាក់ទៀត។

**ស៖** សូមអរគុណអ្នកស្រី។ តើអ្នកស្រីចាំបានទេ ថានៅក្នុងកងពលរបស់អ្នកស្រី ឬក៏ក្រុមដែលអ្នកស្រីទៅជញ្ជូនបាយស្ទុកនោះ ថាតើមានកុមារដែលអាយុដែលស្របាលៗអ្នកស្រី ឬក៏មានអាយុតិចជាងអ្នកស្រីហ្នឹងមានដែរឬទេ? ហើយបើសិនជាមាន តើប្រហែលជាចំនួនប៉ុន្មាននាក់ដែរ ដែលគាត់មានតួនាទីក្នុងការជញ្ជូនបាយស្ទុកទៅឲ្យកងទ័ពដូច្នេះ?

**ផ៖** ចាស អាយុប្រហែលខ្ញុំ។

[១៣:៤១:៣១]

**ស៖** ប្រហែលជាមានចំនួនប៉ុន្មាននាក់ដែរ?

**ផ៖** មួយក្រុមខ្ញុំហ្នឹងគឺ១០នាក់ ពេលដែលជញ្ជូនយកទៅហ្នឹងចាស។

**ស៖** សូមអរគុណអ្នកស្រី។ អ៊ីចឹងយើងមកដល់ពេលវេលានៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥

នៅពេលដែលកងទ័ពខ្មែរក្រហមបានវាយបែកភ្នំពេញ ថាតើកងអ្នកស្រីនៅឈរជើងនៅទីតាំងដដែល ឬក៏ត្រូវបានទីទៅកន្លែងណាផ្សេងទៀត?

**ឆ៖** ចាស ដល់គេវៃបែកនៅទីក្រុងភ្នំពេញឆ្នាំ១៩៧៥ គឺគេបានផ្លាស់កងពលខ្ញុំហ្នឹងឲ្យមកធ្វើស្រែនៅវត្តក្ដុល ខាងលិចស្ទឹងមានជ័យ ពីរោងចក្រកែវទៅឆ្ងាយដែរ ខ្ញុំមិនបានដឹងគីឡូទេ ដឹងថាឆ្ងាយដែរ។

**ស៖** ចាស សូមអរគុណអ្នកស្រី។ នៅពេលដែលគេឲ្យកងរបស់អ្នកស្រីមកធ្វើស្រែនៅវត្តក្ដុលមកធ្វើ មកភ្នំពេញហ្នឹង ថាតើកងអ្នកស្រីនៅតែមានឈ្មោះកងពលលេខ១១ដដែល ឬក៏តើមានអ្វីប្រែប្រួលចំពោះកងរបស់អ្នកស្រីដែរឬទេ?

**ឆ៖** ចាស កាលហ្នឹងនៅតែកងពលលេខ១១ដដែល ហើយអត់មានការប្រែប្រួលអីទេ។

**ស៖** សូមអរគុណអ្នកស្រី។ បន្ទាប់ពីគេឲ្យអ្នកស្រីធ្វើស្រែនៅវត្តក្ដុលម្ដុំរោងចក្រកែវហ្នឹងហើយ តើគេចាត់តាំងឲ្យអ្នកស្រីធ្វើអ្វីទៀត?

[១៣:៤៣:៥២]

**ឆ៖** ចាស មកដល់ពេលហ្នឹង គេឲ្យធ្វើស្រែនៅវត្តក្ដុលហើយបានចំនួន៥ខែ គេឲ្យមកធ្វើស្រែនៅរោងចក្រកែវវិញ។ ហើយគេចាត់តាំងបាន២ខែ គេចាត់តាំងឲ្យខ្ញុំទៅធ្វើជាជីលាមកអាចម៍របស់មនុស្ស។

**ស៖** ចាស សូមអរគុណអ្នកស្រី។ បន្ទាប់មកទៀត តើគេឲ្យអ្នកស្រីធ្វើអ្វីទៀត ហើយនៅកន្លែងណាដែរ?

**ឆ៖** បន្ទាប់មកទៀត គេឲ្យខ្ញុំមកធ្វើស្រែនៅម្ដុំអូរបែកក្អម នៅធ្វើស្រែដដែលចាស។

**ស៖** ចាស សូមអរគុណអ្នកស្រី។ រហូតមកដល់អូរបែកក្អមនេះ តើអ្នកស្រីនៅតែស្ថិតនៅក្នុងកងពល១១ទៀតដដែល ឬក៏តើមានអ្វីប្រែប្រួលនៅក្នុងកងពលដែលអ្នកស្រីស្ថិតនៅ?

**ស៖** ចាស សូមអរគុណអ្នកស្រី។ រហូតមកដល់អូរបែកក្អមនេះ តើអ្នកស្រីនៅតែស្ថិតនៅកងពលលេខ១១ទៀតដដែល ឬក៏តើមានអ្វីប្រែប្រួលនៅក្នុងកងពលដែលអ្នកស្រីស្ថិតនៅ?

**ឆ៖** ចាស ពេលនោះកងពលលេខ១១ និងកងពល៥០២ បានបញ្ចូលគ្នាជាមួយ ចាស។

**ស៖** សូមអរគុណ។ អ្នកស្រីអាចចាំបានទេថា ប្រធានកងពលលេខ៥០២ហ្នឹង គាត់មានឈ្មោះអ្វីដែរ?

**ឆ៖** ចាស គាត់ឈ្មោះ ម៉េត។

**ស៖** សូមអរគុណ។ បន្ទាប់ពីកងពលលេខ១១ និងកងពល៥០២បានបញ្ចូលគ្នាហើយ តើកងពលថ្មីដែលអ្នកស្រីមានចំណែកនៅក្នុងនោះដែរហ្នឹង ឈ្មោះកងពលអ្វីដែរ? ហើយថាតើអ្នកណាជាអ្នកគ្រប់គ្រងលើកងពលថ្មីនោះ?

**ឆ៖** ចាស ឈ្មោះ ម៉េត ហ្នឹងជាអ្នកគ្រប់គ្រង ចាស។

**ស៖** សូមអរគុណអ្នកស្រី។ ចាប់តាំងពីបែកភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ថាតើអ្នកស្រីមានធ្លាប់ត្រូវបានគេធ្វើប្រវត្តិរូប ឬក៏ត្រូវបានតម្រូវឱ្យធ្វើប្រវត្តិរូបនៅក្នុងជួរកងទ័ពដែលអ្នកស្រីនៅដែរឬទេ?

[១៣:៤៦:៤៧]

**ឆ៖** ចាស ពេលនោះខ្ញុំក៏អត់បានដឹងដែរ។ ដល់ពេលហើយ មេកងឈ្មោះ ម៉េត ស្រីហ្នឹង គេប្រាប់ខ្ញុំថា "ខ្ញុំបានទៅសហករណ៍" ខ្ញុំថា "ទៅធ្វើអីបង?"។ គាត់បានប្រាប់ថា "ទៅស្រាវជ្រាវប្រវត្តិរូបអ្អែងហ្នឹង អ្អែងពីដើមអ្អែងឪធ្វើប៉ូលិស ឪពុកចុងធ្វើជាទាហាន។ អ៊ីចឹងម៉ែគាត់ជាប់ពាក់ព័ន្ធ១៧មេសា"។

**ស៖** សូមអរគុណអ្នកស្រី។ បន្ទាប់ពីគេបានស្រាវជ្រាវប្រវត្តិរូបអ្នកស្រីឃើញថា មានការពាក់ព័ន្ធអ៊ីចឹងហើយ ថាតើគេបានចាត់វិធានការយ៉ាងម៉េចជាមួយនឹងអ្នកស្រី? ហើយគេចាត់តាំងឱ្យអ្នកស្រីធ្វើអ្វីទៀត?

**ឆ៖** ចាស ពេលនោះគេដឹងថា ខ្ញុំប្រវត្តិរូបម៉ែឪពាក់ព័ន្ធ១៧មេសា ពេលនោះ គេដាក់ខ្ញុំឱ្យនៅថាជាការកងពាក់ព័ន្ធនិន្នាការ ចាស។ ហើយគេឱ្យខ្ញុំធ្វើលើកដីតែម្នាក់ឯង បាន១០ថ្ងៃគេថាខ្ញុំហ្នឹង ម៉ែឪ១៧មេសា អ៊ីចឹងនាងឯងត្រូវតែឈរលើកដីម្នាក់ឯងនៅតាមសហករណ៍។ ខ្ញុំក៏បានលើកដីម្នាក់ឯង ដូចមនុស្សគ្មាន នៅក្នុងខ្លួន គឺខ្ញុំលើកតែដីម្នាក់ឯងគត់។ គេប្រើខ្ញុំឱ្យធ្វើ ខ្ញុំក៏បានធ្វើ។ កាលនោះខ្ញុំទើបតែមានមិនទាន់ថាដឹងខុសដឹងត្រូវ ខ្ញុំធ្វើម្នាក់ឯង នៅតែឯង នៅសហករណ៍នៅខាងលិចពោធិ៍ចិនតុងហ្នឹង គេឱ្យខ្ញុំធ្វើលើកដីតែម្នាក់ឯង នៅទីនោះ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលសូមយកក្រដាសជូនទៅសាក្សី -- ជូនទៅដើមបណ្តឹងរដ្ឋប្បវេណី។

**សួរដោយលោកស្រី ម៉ុច សុវណ្ណារី៖**

**ស៖** ចាស សូមអរគុណអ្នកស្រី។ សូមអនុញ្ញាតឱ្យខ្ញុំបន្តសំណួរសួរដល់អ្នកស្រីទៀត។ ខ្ញុំចង់នាំ

អ្នកស្រីចូលទៅក្នុងឯកសារមួយ ជាឯកសារព័ត៌មានបន្ថែមដែលអ្នកស្រីបានដាក់ជូនទៅតុលាការ គឺឯកសារដែលមានលេខ E3/4807។ នៅក្នុទំព័រដែលមានលេខ ERN ជាភាសាខ្មែរ 00578980, ERN ជាភាសាអង់គ្លេស 00846968 និង ERN ជាភាសាបារាំង 00578977។ នៅក្នុងឯកសារនោះអ្នកស្រីបានអះអាងថា ចាប់ពីពាក់កណ្ដាលឆ្នាំ១៩៧៦ អ្នកស្រីត្រូវបានគេផ្លាស់ឲ្យទៅធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំង។ អ៊ីចឹងមកដល់ចំណុចនេះ ខ្ញុំចង់សួរអ្នកស្រីថា តើមូលហេតុអ្វីបានជាគេផ្លាស់អ្នកស្រីឲ្យទៅធ្វើការនៅទីនោះ? តើអ្នកស្រីដឹងដែរទេ?

[១៣:៥១:០៩]

**ឆ៖** ចាស កាលនោះខ្ញុំអត់បានដឹងទេ។ ដឹងតែគេប្រាប់ថា អ្នកឯងត្រូវតែទៅធ្វើព្រលានយន្តហោះនៅកំពង់ឆ្នាំង។ ប្រាប់ថាអ៊ីចឹង។

**ស៖** តើគេបញ្ជូនអ្នកស្រីទៅតែម្នាក់ឯង ឬក៏កងទាំងមូលរបស់អ្នកស្រីត្រូវបានបញ្ជូនទៅជាមួយគ្នា?

**ឆ៖** ចាស កងទាំងមូល ចាស។

**ស៖** ចាស សូមអរគុណអ្នកស្រី។ តើអ្នកស្រីអាចជម្រាបបានទេថា កង -- អម្បាញ់មិញអ្នកស្រីបានបញ្ជាក់ថា បន្ទាប់ពីគេធ្វើប្រវត្តិរូបអ្នកស្រីហើយ ដឹងថាពាក់ព័ន្ធ គេបានបញ្ចូលអ្នកស្រីចូលទៅក្នុងកងមួយ ក្នុងក្រុមដែលពាក់ព័ន្ធ។ តើជាកងដដែលនេះមែនទេ ដែលគេបញ្ជូនទៅធ្វើការនៅព្រលានយន្តហោះជាមួយនឹងអ្នកស្រី?

**ឆ៖** ចាស គេឲ្យខ្ញុំទៅកងដដែលហ្នឹង។

**ស៖** តើអ្នកស្រីអាចបញ្ជាក់បានទេថា កងទ័ពទាំងអស់ដែលស្ថិតនៅក្នុងកងជាមួយអ្នកស្រីហ្នឹងគឺសុទ្ធតែជាអ្នកដែលមាននិន្នាការជាប់ពាក់ព័ន្ធជាមួយនឹងអ្នក១៧មេសា ដូចជាអ្នកស្រីដែរ ឬក៏មានតែអ្នកស្រីទេ?

**ឆ៖** ចាស មានតែខ្ញុំម្នាក់ឯង។

**ស៖** ចាស សូមអរគុណអ្នកស្រី។ អ៊ីចឹងអ្នកស្រីបានទៅធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំងនោះ នៅការដ្ឋាននោះអស់រយៈពេលប្រហែលជាប៉ុន្មានដែរ?

**ឆ៖** ចាស កាលហ្នឹងខ្ញុំក៏បានរៀបរាប់ដឹងដែរ ដឹងបាន៣ខែ ឬ៥ខែទេ ព្រោះខ្ញុំនៅក្មេង។ ខ្ញុំក៏អត់បានដឹងខែ ដឹងអីដែរ ចាស។

**ស៖** ចាស សូមអរគុណអ្នកស្រី។ ពេលដែលមកដល់ការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំងដំបូង តើអ្នកស្រីឃើញទិដ្ឋភាពនៅក្នុងការដ្ឋាននោះយ៉ាងម៉េចដែរ? អ្នកស្រីអាចរៀបរាប់ជូនតុលាការបានទេ?

[១៣:៥៤:០០]

**ឆ៖** ចាស ពេលដែលខ្ញុំទៅដល់ព្រលានយន្តហោះកំពង់ឆ្នាំងហ្នឹង គឺទៅដល់ពេលយប់។ អ៊ីចឹង ខ្ញុំអត់ទាន់បានដឹងថា យ៉ាងរបៀបម៉េចទេ។ ដល់ព្រលឹមឡើង ខ្ញុំបានឃើញគេឲ្យខ្ញុំទៅធ្វើការ ក៏ខ្ញុំឃើញថា ទៅដល់នោះ ឃើញគេជីកប្រឡាយជុំវិញហើយអស់ហើយ ចាស។

**ស៖** ការដ្ឋាននោះ មានទីតាំងនៅកន្លែងណាដែរ អ្នកស្រីអាចបញ្ជាក់ជូនបានទេ?

**ឆ៖** ចាស ខ្ញុំអត់បានដឹងភូមិ ឃុំអីទេ ព្រោះខ្ញុំអត់ស្គាល់។

**ស៖** អ៊ីចឹងហេតុអ្វីបានពេលនោះអ្នកស្រីដឹងថា កន្លែងដែលគេចាត់តាំងអ្នកស្រីឲ្យទៅធ្វើការនោះជាការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង ហេតុអ្វីបានជាអ្នកស្រីដឹង?

**ឆ៖** ចាស មេកងឈ្មោះ ស្រ៊ុន ហ្នឹងគេប្រាប់ថា ហ្នឹងហើយព្រលានយន្តហោះកំពង់ឆ្នាំង។

**ស៖** សូមអរគុណអ្នកស្រី។ អ៊ីចឹងតើប្រធានកងឈ្មោះ ស្រ៊ុន នោះគាត់មានបានបញ្ជាក់ប្រាប់អ្នកស្រី ឬក៏ក្រុមរបស់អ្នកស្រីហ្នឹងបន្ថែមទៀតថា ទាក់ទងជាមួយនឹងការដ្ឋានហ្នឹង ថាមូលហេតុអ្វីបានជាថ្នាក់ដឹកនាំ គេសាងសង់ការដ្ឋាននេះ ដើម្បីគោលបំណងអ្វី? តើគេមានប្រាប់ដែរឬទេ?

**ឆ៖** ចាស ខ្ញុំអត់បានដឹងទេ។

**ស៖** សូមអរគុណអ្នកស្រី។ អ៊ីចឹងនៅពេលដែលអ្នកស្រីទៅចាប់ផ្ដើមធ្វើការនៅទីនោះដំបូង តើអ្នកស្រីដឹងទេថា មើលឃើញថា នៅក្នុងការដ្ឋាននោះតើមានកម្មករប្រហែលជាប៉ុន្មាននាក់ដែលត្រូវបានគេចាត់តាំងឲ្យទៅធ្វើការនៅទីនោះ?

**ឆ៖** ចាស ដឹងឃើញតែមនុស្សច្រើន ខ្មៅងងឹតនៅទីនោះ។ ខ្ញុំមិនបានរៀបរាប់ថា ប៉ុន្មានពាន់នាក់ៗ ព្រោះខ្ញុំអត់បានដឹងទេ ខ្ញុំដឹងថាច្រើន គ្នាច្រើនហ្នឹងតែម្ដង។

[១៣:៥៦:៤៤]

**ស៖** សូមអរគុណអ្នកស្រី។ តើអ្នកស្រីអាចដឹងទេថា កម្មករទាំងអស់នោះ គឺសុទ្ធតែជាកងទ័ពដូចជាអ្នកស្រីដែរ ឬក៏មានប្រជាជនធម្មតា ឬក៏មនុស្សប្រភេទណាខ្លះដែលត្រូវបានតម្រូវឲ្យទៅធ្វើការនៅទីនោះ?

**ឆ៖** ចាស សុទ្ធតែកងទ័ព។

**ស៖** ចាស សូមអរគុណអ្នកស្រី។ អ្នកស្រីអាចជម្រាបជូនបានទេថា ហេតុអ្វីបានជាអ្នកស្រីដឹងថាពួកគេគឺជាកងទ័ព ដោយសារពួកគេមានឯកសណ្ឋានដែលខុសគ្នាជាមួយនឹងប្រជាជនធម្មតា ជាឯកសណ្ឋានទ័ព ឬក៏ដោយមូលហេតុផ្សេង?

**ឆ៖** ចាស ស្លៀកពាក់ខ្មៅ ហើយនិងមានមួកកន្ទឹប ចាស។

**ស៖** សូមអរគុណអ្នកស្រី។ អ៊ីចឹងអ្នកស្រីដឹងដែរទេ នៅពេលនោះថា តើកងទ័ពទាំងអស់នោះគាត់មកពីតំបន់ណាដែរ មកពីភូមិភាគណាដែរ អ្នកស្រីដឹងព័ត៌មានទាំងនេះទេ?

**ឆ៖** ចាស ខ្ញុំអត់បានដឹងទេ។

**ស៖** ចាស សូមអរគុណអ្នកស្រី។ អ៊ីចឹងត្រឡប់មកការងារដែលអ្នកស្រីត្រូវធ្វើវិញ នៅពេលដែលអ្នកស្រីទៅដល់ការដ្ឋាននោះថា តើគេតម្រូវឲ្យអ្នកស្រីធ្វើអ្វីខ្លះ? អាចរៀបរាប់ជូនបានទេ?

**ឆ៖** ចាស ពេលនោះតម្រូវឲ្យការងារដែលពួកខ្ញុំធ្វើ គឺគេឲ្យលើកអាចម៍ដី និងសែងថ្ម ហើយនិងបង្ហាប់ដី។

**ស៖** សូមអរគុណអ្នកស្រី។ អ៊ីចឹងទាក់ទងជាមួយនឹងពេលវេលានៃការធ្វើការវិញ ថាតើអ្នកស្រីគេតម្រូវឲ្យអ្នកស្រីធ្វើការប៉ុន្មានពេលដែរក្នុងមួយថ្ងៃ? ហើយចាប់ពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មានដែរ?

**ឆ៖** ចាស ខ្ញុំអត់បានដឹងម៉ោងវេលាទេ ព្រោះដល់ពេលចេញធ្វើការ មេកងគេប្រាប់ឲ្យរៀបចំអីវ៉ាន់ចេញទៅធ្វើការ។ ដល់ពេលឡើង គេប្រាប់ថា ទុកអីវ៉ាន់ ទុកដាក់ឲ្យស្រួល ហើយត្រឡប់ទៅផ្ទះវិញសម្រាកហូបបាយ។ ដល់ពេលហូបបាយហើយ បានបន្តិចក៏គេឲ្យថា យើងត្រូវទៅធ្វើការវិញយប់ចាស។

[១៤:០០:១៤]

**ស៖** អ៊ីចឹងខ្ញុំសូមបញ្ជាក់ជាមួយនឹងអ្នកស្រីថា ខ្ញុំទទួលបានព័ត៌មានពីអ្នកស្រីនេះ គឺត្រឹមត្រូវដែរឬទេ? មានន័យថា កម្មករ ក្រុមរបស់អ្នកស្រីគឺត្រូវបានគេតម្រូវឲ្យធ្វើការបីពេលក្នុងមួយថ្ងៃ គឺធ្វើការនៅពេលព្រឹកមួយពេល ពេលថ្ងៃក្រោយពេលបាយថ្ងៃត្រង់មួយពេល ល្ងាចឡើងបរិភោគបាយពេលល្ងាចហើយ គឺត្រូវទៅធ្វើការនៅពេលយប់ថែមមួយពេលទៀត។ តើអ៊ីចឹងមែនទេ?

**ឆ៖** ចាស ពិតមែនហើយ។

**ស៖** ចាស សូមអរគុណអ្នកស្រី។ បន្ទាប់ពីអ្នកស្រីបរិភោគអាហារពេលល្ងាចហើយ ថាតើអ្នកស្រីអាចចាំបានទេ ឬអាចជម្រាបជូនបានទេ ថាអ្នកស្រីត្រូវបានគេតម្រូវឲ្យធ្វើការរយៈពេលប៉ុន្មាន

ម៉ោងថែមទៀតនៅពេលយប់នោះ?

**ឆ៖** ចាស ពេលពីហូបបាយល្ងាចហើយ សម្រាកបានបន្តិច ដល់ពេលទៅធ្វើការទៀត ខ្ញុំអត់ដឹងម៉ោងប៉ុន្មានទេ។ ដល់ពេលហើយ គេប្រាប់ថាដល់ម៉ោងហើយទៅផ្ទះ។ ទៅកន្លែងសម្រាកចាស ព្រោះកាលហ្នឹងអត់មានម៉ោង អត់មានអីទេ។

**សៈ** ចាស សូមអរគុណអ្នកស្រី។ ទាក់ទងនឹងរបបអាហារ ថាតើពេលព្រឹកឡើងនៅពេលដែលក្រោកពីគេង ហើយអ្នកស្រីត្រូវបានគេតម្រូវឲ្យទៅធ្វើការនៅពេលព្រឹក ថាតើពេលព្រឹកឡើងគេមានផ្តល់អាហារពេលព្រឹកឲ្យអ្នកស្រីដែរឬទេ? ហើយអាហារពេលថ្ងៃ និងអាហារពេលល្ងាច តើជាប្រភេទអាហាររបៀបណាដែលគេផ្តល់ឲ្យអ្នកស្រី? ហើយតើគ្រប់គ្រាន់ដែរឬទេ?

**ឆ៖** ចាស អាហារពេលព្រឹកគឺអត់មានទេ អាហារថ្ងៃត្រង់គឺបាយលាយពោត ពោត១០កំប៉ុងអង្ករពីរកំប៉ុងចាស។ ហើយហូបអត់បានគ្រប់គ្រាន់ទេ គឺហូបមិនដែលបានឆ្អែតទេ គឺសម័យនោះគឺហូបមិនដែលឆ្អែតសោះចាស។ ហើយបែរសម្លវិញ គឺសម្លផ្ទី ហើយក៏ព្រលឹត ខ្ញុំអត់ដែលបានឃើញសាច់ត្រីទេចាស។

**សៈ** សូមអរគុណអ្នកស្រី។ អម្បាញ់មិញអ្នកស្រីបានបញ្ជាក់ថា ក្នុងមួយថ្ងៃគេឲ្យអង្ករពីរកំប៉ុងពោត១០កំប៉ុង។ តើរបបអាហារបែបនេះគឺជារបបអាហារសម្រាប់មួយថ្ងៃ? បានន័យថា សរុបទាំងអាហារពេលថ្ងៃ និងអាហារពេលល្ងាច ឬក៏យ៉ាងណា?

[១៤:០៣:២២]

**ឆ៖** ចាស អាហារពេលថ្ងៃត្រង់ និងអាហារពេលល្ងាច។

**សៈ** របបអាហារទាំងពីរ -- របបអាហារប៉ុណ្ណឹងក្នុងមួយថ្ងៃហ្នឹង តើសម្រាប់កងរបស់អ្នកស្រីមួយកង មែនដែរទេ? ហើយបើសិនជាអ៊ីចឹងមែន ថាតើអ្នកស្រីអាចបញ្ជាក់បានទេថា ក្នុងកងរបស់អ្នកស្រីហ្នឹង គឺមានចំនួនមនុស្សប៉ុន្មាននាក់ដែរ ដែលទទួលបានរបបអាហារប៉ុណ្ណឹង?

**ឆ៖** ចាស មួយកងខ្ញុំ កងតូចហ្នឹងគឺមានគ្នា៣៣នាក់។ អ៊ីចឹងវាមានបីក្រុម។ អ៊ីចឹងក្នុងអង្ករ -- ពោត១០កំប៉ុង អង្ករពីរកំប៉ុងហ្នឹងគឺគ្នាខ្ញុំតែ១១នាក់ទេចាស។

**សៈ** សូមអរគុណអ្នកស្រី។ មុននេះអ្នកស្រីបានបញ្ជាក់ថា អ្នកស្រីត្រូវធ្វើការនៅពេលយប់ទៀត។ អ៊ីចឹងខ្ញុំចង់សួរបញ្ជាក់ថា នៅពេលដែលយើងត្រូវធ្វើការថែមនៅពេលយប់អ៊ីចឹង ថាតើមានរបបអាហារបន្ថែមក្រៅពីអាហារពីរពេលដែលគេផ្តល់ជូនក្រុមរបស់អ្នកស្រីដែរទេ?

**ឆ៖** ចាស អត់មានទេ អាហារពេលយប់ចាស។

**ស៖** ចាស សូមអរគុណអ្នកស្រី។ ទាក់ទងជាមួយនឹងអនាម័យនៃអាហារបរិភោគ ក៏ដូចជាទឹកបរិភោគ តើយ៉ាងម៉េចដែរ? អ្នកស្រីអាចរៀបរាប់បានទេ ថាតើមានទឹកដែលដាំឆ្អិនសម្រាប់បរិភោគឬទេ ឬក៏អ្នកស្រីត្រូវរកមធ្យោបាយ ឬក៏មានប្រភេទទឹកណាផ្សេងដែលត្រូវបរិភោគ?

**ឆ៖** ចាស ហូបទឹកគឺអត់មានអនាម័យទេនៅពេលហូបទឹកអូរ។

**ស៖** អ៊ីចឹងពេលដែលកម្មករគាត់ងូតទឹក ថាតើគាត់ងូតទឹកអូរដដែល ដែលត្រូវយកមកៗៗហូបហ្នឹង ឬក៏គាត់មានកន្លែងផ្សេងដែលគាត់អាចនឹងងូតទឹកសម្អាតកាយគាត់បាន?

**ឆ៖** ចាស ហូបកន្លែងទឹកងូតហ្នឹងចាស ព្រោះទឹកអូរវាហូរ។

[១៤:០៦:២៥]

**ស៖** សូមអរគុណ។ ទាក់ទងជាមួយនឹងពេលវេលាសម្រាកវិញ នៅក្នុងរយៈពេលដែលអ្នកស្រីទៅធ្វើការនៅការដ្ឋាននោះប្រហែលជា៣ ឬក៏៥ខែហ្នឹង ថាតើគេមានអនុញ្ញាតឲ្យអ្នកស្រីមានឱកាសដើម្បីនឹងសម្រាក? ឧទាហរណ៍ថា ប៉ុន្មានថ្ងៃគេចេញច្បាប់ឲ្យយើងចេញទៅសម្រាកម្តង ថាតើមានៗការរៀបចំអ៊ីចឹងដែរឬទេ?

**ឆ៖** ចាស អត់មានពេលសម្រាកទេ គឺពេលតែសម្រុក គេឲ្យសម្រុក។ ការងារគេអត់ឲ្យឈប់ទេ។ លុះត្រាតែមានឈឺក្បាល វិលមុខ ឬចុកពោះពេលមករដូវអី ហ្នឹងបានសុំគេសម្រាកមួយថ្ងៃអី បានគេឲ្យសម្រាកចាស។ បើថាអត់ទេ គេអត់ឲ្យឈប់ទេ។

**ស៖** សូមអរគុណអ្នកស្រី។ អ៊ីចឹងឧទាហរណ៍ថា ក្នុងពេលព្រឹកមួយអ៊ីចឹង ដែលក្រុមអ្នកស្រីត្រូវធ្វើការ អ៊ីចឹងនៅក្នុងមួយព្រឹកហ្នឹង ថាតើគេឲ្យយើងសម្រាកដែរឬទេ នៅក្នុងចន្លោះពេលមួយព្រឹកហ្នឹង? ហើយបើសិនជាគេឲ្យសម្រាក តើគេឲ្យយើងសម្រាកប្រហែលជារយៈពេលប៉ុន្មានដែរ? ហើយពេលថ្ងៃតើមានពេលសម្រាកពាក់កណ្តាលថ្ងៃដែលយើងធ្វើការហ្នឹងដែរឬទេ?

**ឆ៖** ចាស ពេលដែលធ្វើការងារ គឺអត់មានពេលសម្រាកទេ ដល់ពេលឡើងមកហូបបាយ គឺបានសម្រាកបានតែបន្តិចទេ បានត្រឡប់ទៅវិញទៀតហើយចាស។

**ស៖** ចាស សូមអរគុណអ្នកស្រី។ អ៊ីចឹងនៅពេលដែលយប់ឡើង តើកន្លែងសម្រាកនៅពេលយប់ គេរៀបចំឲ្យអ្នកស្រីរបៀបម៉េចដែរ? អ្នកស្រីអាចរៀបរាប់ពីទីតាំងដែលអ្នកស្រី ក្រុមរបស់អ្នកស្រីសម្រាកនៅពេលយប់បានទេ?

**ឆ៖** ចាសពេលយប់គេបានធ្វើរោង ខ្ញុំទៅដល់ឃើញរោងស្រាប់ ដល់ពេលនេះគេធ្វើជារាន ដូចរានកន្លែងដេក មួយកងហ្នឹងគឺមួយកន្លែងផ្ទះហ្នឹង គឺដេកដង្ហែគ្នាដូចកូនជ្រូកអ៊ីចឹង។ ហើយគ្មានមុងគ្មានកន្ទេលទេ ដេកដោយលាតរនាបទទេ ចាស។

[១៤:០៩:០២]

**ស៖** នៅកន្លែងដែលអ្នកស្រីសម្រាកនៅពេលយប់ហ្នឹង តើមានការរំខានពីសត្វល្អិត ដូចជាសត្វមូស ឬក៏ស្រមោច ឬក៏សង្កើច ឬក៏ចៃអីដែរទេ?

**ឆ៖** ចាសមានដែរ ដល់ពេលនោះនាំគ្នាប្រមូលស្លឹកឈើអីដុតបង្ហុយផ្សែង ដើម្បីកុំឱ្យមានមូសអីមកខាំដែរចាស។

**ស៖** អរគុណអ្នកស្រី។ អ៊ីចឹងតើអ្នកដែលទទួលខុសត្រូវនៅក្នុងការដ្ឋានហ្នឹង គេមានបានចាត់វិធានការណាមួយដើម្បីជួយសម្រួល ជួយដោះស្រាយបញ្ហាសត្វល្អិត បញ្ហាទាំងអស់នោះដែរទេ?

**ឆ៖** ខ្ញុំមិនដែលបានឃើញគេចាត់វិធានការណាមួយទេ។ អត់សោះ។

**ស៖** ចាស សូមអរគុណអ្នកស្រី។ អ៊ីចឹងទាក់ទងជាមួយនឹងអនាម័យខ្លួនប្រាណ ថាតើអ្នកទទួលខុសត្រូវការដ្ឋាននោះ គេមានផ្គត់ផ្គង់ដល់អ្នកស្រី ហើយនិងក្រុមរបស់អ្នកស្រីហ្នឹងនូវសាប៊ូដុសខ្លួន សាប៊ូកក់សក់ ឬក៏សាប៊ូបោកខោអាវទេ? ហើយបើសិនជាគេមិនបានផ្គត់ផ្គង់ទេ ថាតើគេអនុញ្ញាតឱ្យយើងអាចមានរបស់ទាំងអស់នោះប្រើប្រាស់ដែរឬទេ?

**ឆ៖** ចាស អត់មាន។ ពេលនោះពេលធ្វើការឡើងមកវិញ គឺគ្មានជាសាប៊ូ ឬគ្មានជាអ្វីដើម្បីដុសសម្អាតកាយទេចាស មានតែអត់ទាំងអស់។ ពេលនោះ ពួកខ្ញុំយកអាដូចជានធនោងសាញ នធនោងព្រៃហ្នឹងយកមកដុសក្បាលចាស។ ហើយពេលនោះ គ្មានអ្នកណាមួយដែលមានសាប៊ូដុសទេ គឺចៃកើតពេញក្បាលទាំងអស់។ កើតរមាស់ក៏កើតរមាស់ ចៃក៏ចៃដែរចាស។

[១៤:១១:៣២]

**ស៖** សូមអរគុណអ្នកស្រី។ អ៊ីចឹងក្នុងនៅពេលដែលអ្នកស្រីធ្វើការ តើអ្នកណាជាអ្នកបែងចែកកំណត់ថា អ្នកស្រីក្រុមក្នុងមួយកងរបស់អ្នកស្រីហ្នឹងត្រូវធ្វើការក្នុងកម្រិតណា ទំហំប៉ុនណាឱ្យហើយក្នុងមួយថ្ងៃ? តើគេមានកំណត់អ៊ីចឹងទេ? រួចហើយថាតើអ្នកជាអ្នកកំណត់ឱ្យក្រុមអ្នកស្រីហ្នឹងជាអ្នកធ្វើ?

**ឆ៖** ខ្ញុំអត់បានទេគេកំណត់ទេ ដឹងតែគេឱ្យសែងចាក់ៗ ខ្ញុំចេះតែសែងចាក់ទៅ។ ចាក់ដីនៅ

តាមផ្លូវព្រលានហ្នឹង គឺគេឲ្យសែងចាក់ថ្មគេយកទៅ ដើម្បីគេបង្ហាប់។ បើកំណត់ផែនការដើម្បីឲ្យមានការបែងចែកកំណត់ប៉ុន្មានៗ គឺខ្ញុំអត់បានដឹងទាំងអស់។

**ស៖** ចាស សូមអរគុណអ្នកស្រី។ អ្នកស្រីអត់បានដឹងថាមានការកំណត់ផែនការអីទេ។ អ៊ីចឹងអ្នកស្រីធ្លាប់បានដឹង ឬក៏ជួបប្រទះនៅក្នុងក្រុមអ្នកស្រីផ្ទាល់ថា មានការស្ដីបន្ទោសពីខាងថ្នាក់លើអ្នកទទួលខុសត្រូវហ្នឹងថា អ្ហូ! ក្រុមនេះអត់បានធ្វើតាមផែនការទេនៅថ្ងៃនេះ ថាតើធ្លាប់មានករណីអ៊ីចឹងកើតឡើងនៅក្នុងកងអ្នកស្រីដែរទេ?

**ឆ៖** អត់មានទេចាស។

**ស៖** ចាស សូមអរគុណអ្នកស្រី។ នៅក្នុងពេលដែលអ្នកស្រីធ្វើការ ទាំងពេលថ្ងៃក៏ដោយ ទាំងពេលព្រឹកក៏ដោយ ទាំងពេលយប់ក៏ដោយ ទាំងបីពេលហ្នឹង ថាតើអ្នកស្រីអាចមានសេរីភាព សិទ្ធិសេរីភាពនៅក្នុងការជជែក ឬក៏មានទំនាក់ទំនងនិយាយជាមួយនឹងកម្មករដែលធ្វើការជាមួយគ្នាហ្នឹងដែរទេ? កម្មករនៅក្នុងកងជាមួយគ្នា ឬក៏អាចឆ្លងៗក្រុមគ្នា ថាតើអាចមានសិទ្ធិសេរីភាពនិយាយអ៊ីចឹងបានដែរទេ?

[១៤:១៣:៣៤]

**ឆ៖** ចាស អត់មានសិទ្ធិសេរីភាពនិយាយគ្នារកគ្នាទៅវិញទៅមកទេ គឺដឹងតែធ្វើការងារ។

**ស៖** អ៊ីចឹងទាក់ទងជាមួយនឹងសិទ្ធិសេរីភាពនៅក្នុងការដើរហើរវិញ ថាតើអ្នកស្រីមានសិទ្ធិសេរីភាពនៅក្នុងការដើរហើរចេញពីរង្វង់នៃកន្លែងការងារដែលអ្នកស្រីធ្វើ ទៅកន្លែងមួយទៀត ឬក៏នៅក្នុងការដ្ឋាននោះដែរទេ?

**ឆ៖** ចាស ពេលដើរហើរសេរីទៅណាមកណា គឺអត់បានដើរទេ។ បានដើរតែពេលទៅធ្វើការតែម្ដង។

**ស៖** ចាស សូមអរគុណអ្នកស្រី។ អ៊ីចឹងថាម៉ោងពេលធ្វើការចុះ យើងអត់អាចដើរហើរបានខ្លាចយើងធ្វើការងារមិនបានល្អ។ អ៊ីចឹងពេលដែលចប់ការងារនៅពេលយប់ហើយដែលអាចចូលទៅសម្រាកបានហ្នឹង បើសិនជាយើងចង់ដើរទៅណាមកណា តើយើងអាចដើរបានដែរឬទេ? ហើយយើងអាចនិយាយគ្នានៅក្នុងក្រុមយើងបានដែរឬទេ?

**ឆ៖** ចាស ពេលយប់ក៏អត់បានដើរដែរ។ ដឹងតែមកដល់ផ្ទះ ដឹងតែងូតទឹកហើយសម្រាកដេកតែម្ដងចាស។

[១៤:១៥:០៧]

**ស៖** សូមអរគុណអ្នកស្រី។ នៅពេលដែលក្នុងរយៈពេលដែលអ្នកស្រីធ្វើការនៅក្នុងការដ្ឋាននោះ ប្រហែលជាពីចន្លោះពី៣ខែទៅ៥ខែហ្នឹង ថាតើមានពេលណាមួយដែលអ្នកស្រីធ្វើហ្នឹង មានភ្លៀងធ្លាក់មក ហើយអ្នកស្រីត្រូវធ្វើការនៅហាលភ្លៀងនោះទេ?

**ឆ៖** ចាស មានពេលធ្វើការទាំងហាលភ្លៀង ចាស។

**ស៖** ប្រហែលជាប៉ុន្មានដងដែរ ដែលក្រុមអ្នកស្រីត្រូវធ្វើការទាំងហាលភ្លៀងនុ៎ង?

**ឆ៖** ចាស ខ្ញុំបានដឹងតែមួយដងទេ ចាស ហាលភ្លៀង។

**ស៖** ពេលដែលមានភ្លៀងធ្លាក់អ៊ីចឹង អាចសុំគេឈប់បានទេ?

**ឆ៖** ចាស គេអត់ឲ្យឈប់ទេ។

**ស៖** គេមានប្រាប់មូលហេតុទេ ថាហេតុអីបានជាអត់បានច្បាប់ឈប់នៅពេលដែលភ្លៀង?

**ឆ៖** គេអត់ប្រាប់មូលហេតុទេ គេដឹងថា ឲ្យយើងធ្វើការងារ ចាស។

**ស៖** បើមិនឲ្យច្បាប់ឈប់ទេ ហើយតម្រូវឲ្យធ្វើការនៅហាលភ្លៀងអ៊ីចឹង ថាតើគេមានផ្គត់ផ្គង់ឲ្យកម្មករនៅពេលដែលធ្វើការហ្នឹងដែរទេ ឧទាហរណ៍ដូចជា ឲ្យមួកការពារភ្លៀង ឲ្យអាវភ្លៀង ឬក៏ឆត្រ? តើមានផ្តល់ -- អ្នកទទួលខុសត្រូវការដ្ឋានមានផ្តល់សម្ភារៈទាំងអស់នោះ ដល់កម្មករដែលត្រូវធ្វើការនៅហាលភ្លៀងដែរទេ?

**ឆ៖** ចាស អត់មានអាវភ្លៀង ឬមួកទេ។ មានតែមួកកន្ទឹបមួយ ក៏ពាក់មុខមិនជិតដែរ ចាស។ អត់មានអាវភ្លៀង ឬឆត្រ ឬអ្វីដើម្បីការពារខ្លួនពេលធ្វើការហាលភ្លៀងទេ គឺអត់ទាំងអស់។

[១៤:១៧:៤៦]

**ស៖** ចាស សូមអរគុណអ្នកស្រី។ អ៊ីចឹងនៅក្នុងអំឡុងពេលដែលអ្នកស្រីធ្វើការនៅទីនោះ ថាតើគេមានតម្រូវឲ្យអ្នកស្រីត្រូវប្រជុំជីវភាពដែរឬទេ? ហើយបើសិនជាមាន ថាតើត្រូវប្រជុំជារៀងរាល់ថ្ងៃ ឬក៏ក្នុងរយៈពេលប៉ុន្មានថ្ងៃម្តង? ហើយនៅពេលប្រជុំនោះ ថាតើគេរៀបចំយ៉ាងម៉េច? ហើយគេពិភាក្សាគ្នាពីរឿងអីគេខ្លះ?

**ឆ៖** ចាស ពេលគេប្រជុំ គេប្រជុំប្រាប់តែពីរឿងការងារឲ្យយើងខំធ្វើដើម្បីសម្រុកឲ្យឆាប់ហើយតែប៉ុណ្ណឹង។ គេអត់មាននិយាយអំពីរឿងអ្វីក្រៅពីការងារទេ ចាស។

**ស៖** នៅពេលដែលប្រជុំនោះ ថាតើគេមានបានបញ្ជាក់ថា អ្នំផែនការពីលើមកគេកំណត់ថា

យ៉ាងម៉េចៗ? តើគេមានបាននិយាយពីរឿងហ្នឹងទេ? ហើយមួយទៀត ថាតើគេឲ្យយើងទិតៀនគ្នាទៅវិញទៅមក ឬក៏ទិតៀនខ្លួនឯងអីដែរទេ?

**ឆ៖** ចាស អត់បានទិតៀនគ្នាទេ ហើយក៏ទិតៀនខ្លួនឯងក៏អត់បានដឹងដែរ ព្រោះដឹងតែពីការងារសម្រុករាល់ថ្ងៃ។ អត់ដឹងខ្លួនឯងខុសអីផង។

**ស៖** សូមអរគុណអ្នកស្រី។ ដោយសារស្ថានភាពការងារនៅទីកន្លែងនោះលំបាក ធ្វើការច្រើន ហើយរបបអាហារមិនគ្រប់គ្រាន់ ហើយអនាម័យមិនល្អ។ អ៊ីចឹងខ្ញុំចង់សួរអ្នកស្រីថា តើអ្នកស្រីធ្លាប់ពិសោធន៍ផ្ទាល់ខ្លួន ធ្លាក់ខ្លួនឈឺ ឬក៏ធ្លាប់ឃើញកម្មករណានៅក្នុងក្រុមរបស់អ្នកស្រីធ្លាក់ខ្លួនឈឺដែរទេ?

**ឆ៖** ចាស ពេលនោះខ្ញុំអត់បានដឹងគេទេ។ ដឹងតែខ្លួនខ្ញុំផ្ទាល់ គឺខ្ញុំធ្លាក់ខ្លួនកើតពិសដៃ។ ដល់តែពេលនោះគេឲ្យខ្ញុំទៅសែងដី។ បើសែងមិនរួច ក៏គេឲ្យខ្ញុំទៅជួយកើបអាចម៍ដីដាក់ឲ្យគេ ដៃម្ខាងឈឺ ដៃម្ខាង។ ខ្ញុំដឹងថា ខ្លួនខ្ញុំគឺឈឺ ធ្លាក់ខ្លួនឈឺតែប៉ុណ្ណឹង ចាស។

[១៤:២០:១៩]

**ស៖** អ៊ីចឹងថាតើនៅពេលដែលអ្នកស្រីឈឺហ្នឹង គេមានផ្តល់សេវាពេទ្យឲ្យ មានគ្រូពេទ្យ គេមកពិនិត្យអ្នកស្រី ហើយគេមានផ្តល់ថ្នាំ ឬក៏គេព្យាបាលអ្នកស្រីយ៉ាងម៉េចដែរ? ហើយតើអ្នកស្រីបានទទួលច្បាប់ឈប់សម្រាកដែរឬទេ?

**ឆ៖** ចាស សេវាកម្មពេទ្យគេ គេឲ្យថ្នាំអាចម៍ទន្សាយខ្ញុំលេប ហើយខ្ញុំសុំគេឈប់ គេអត់ឲ្យខ្ញុំឈប់ទេ គេថា "ដៃម្ខាងឈឺ ក៏នៅដៃម្ខាងដែរ អ៊ីចឹងទៅធ្វើការ"។ អ៊ីចឹងខ្ញុំខ្លាចគេ ខ្ញុំទៅហើយ។

**ស៖** ចាស សូមអរគុណអ្នកស្រី។ អ៊ីចឹងរយៈពេលកន្លងដែលអ្នកស្រីបានធ្វើការនៅការដ្ឋាននោះប៉ុន្មានខែហ្នឹង នៅពេលដែលចប់ ថាតើអ្នកទទួលខុសត្រូវការដ្ឋាន ឬក៏អ្នកទទួលខុសត្រូវនៅក្នុងកងអ្នកស្រីហ្នឹង គេបានផ្តល់ផលប្រយោជន៍អ្វីខ្លះដល់អ្នកស្រី ឬក៏កម្មករផ្សេងៗទៀត ជាថ្នូរនឹងការដែលយើងខំប្រឹងធ្វើការនៅក្នុងការដ្ឋាននោះ?

**ឆ៖** ចាស អត់មានផ្តល់ផលប្រយោជន៍អីទេ គឺអត់ផង។

**ស៖** ត្រឡប់នៅពេលដែលគេចាត់តាំងអ្នកស្រីឲ្យមកធ្វើការនៅការដ្ឋាននោះដំបូងវិញ ថាតើអ្នកស្រី ឬក៏សមាជិកណាមួយនៅក្នុងកងរបស់អ្នកស្រីអាចប្រកែកថាមិនមក មិនទៅធ្វើការនៅទីនោះបានទេ?

**ឆ៖** ចាស អត់មានអ្នកណាមួយហ៊ានប្រកែកទេ។

[១៤:២២:២៦]

**សៈ** ចាស សូមអរគុណអ្នកស្រី។ បន្ទាប់ពីធ្វើការនៅការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំងនោះ តើគេបានចាត់តាំងអ្នកស្រី ឬក៏កងអ្នកស្រីហ្នឹងទៅធ្វើការនៅកន្លែងណាទៀត? រួចហើយគេឲ្យអ្នកស្រីធ្វើអ្វីខ្លះ?

**ឆៈ** ចាស ពេលដែលធ្វើការនៅព្រលានកំពង់ឆ្នាំងរួចហើយ ក៏គេចាត់តាំងឲ្យកងតូចរបស់ខ្ញុំមួយកងតូចហ្នឹងទៅភ្នំពេញវិញចាស ទៅជញ្ជូនឥដ្ឋ ដើម្បីដាក់បារ៉ុងរទេះភ្លើង។ គេថា ប្រាប់គេថាយកទៅព្រលានកំពង់ឆ្នាំងវិញ។

**សៈ** អ្នកស្រីអាចជម្រាបជូនបានទេ ពីផលលំបាកដែលអ្នកស្រីទទួលរងនៅពេលដែលអ្នកស្រីត្រូវជញ្ជូនឥដ្ឋ ដើម្បីដាក់រទេះភ្លើងយកមកបម្រើឲ្យការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង? ថាតើអ្នកស្រីជួបប្រទះនូវការលំបាកអ្វីខ្លះ នៅពេលដែលអ្នកស្រីជញ្ជូនឥដ្ឋនោះ?

**ឆៈ** ចាស ពេលនោះពួកខ្ញុំគ្នា៣០នាក់ហ្នឹងទៅជញ្ជូនឥដ្ឋ គឺមានការប៉ះពាល់ដូចជា ពងដៃបែកដៃ បែកជើង ចាស។ ពេលនោះចូលទៅយកឥដ្ឋនៅក្នុងឡនោះ គឺក្តៅ ដើម្បីខំសម្រុកជញ្ជូនឥដ្ឋយកដាក់ឲ្យគេ ទាន់ផែនការរបស់គេនៅកំពង់ឆ្នាំង ចាស។

**សៈ** សូមអរគុណអ្នកស្រី។ អ៊ីចឹងខ្ញុំចង់ចូលទៅប្រធានបទមួយទៀត ដែលអ្នកស្រីបានបញ្ជាក់នៅក្នុងពាក្យ ឯកសារព័ត៌មានបន្ថែមរបស់អ្នកស្រី។ នៅក្នុងឯកសារលេខ E3/4807 នៅក្នុងទំព័រដែលមានលេខ ERN ជាភាសាខ្មែរ 00578979, ERN ជាភាសាអង់គ្លេស 00846968 និង ERN ជាភាសាបារាំង 00578977។ ពេលនោះអ្នកស្រីបានបញ្ជាក់នៅក្នុងឯកសារនេះថា ប្រហែលជានៅឆ្នាំ១៩៧៨ អ្នកស្រីត្រូវបានគេបង្ខំឲ្យរៀបការ។ អ៊ីចឹងតើអ្នកស្រីអាចរៀបរាប់លម្អិតអំពីការដែលគេបង្ខំឲ្យអ្នកស្រីរៀបការនេះជូនតុលាការបានទេ?

[១៤:២៥:០៩]

**ឆៈ** ចាស នៅក្នុងឆ្នាំ១៩៧៨ កាលនោះចុង៧៨ហើយ គេបានបង្ខំឲ្យខ្ញុំរៀបការជាមួយនឹងប្រាំគូចាស តែខ្ញុំអត់បានស្គាល់បុរសនោះទេ។ ដល់ពេលគេឲ្យខ្ញុំទៅអង្គុយជាជួរ ថាឲ្យមើលគ្នាម្នាងៗម្នាក់ ខ្ញុំអត់បានស្គាល់ឈ្មោះគេ គេក៏មិនបានស្គាល់ឈ្មោះខ្ញុំ។ ដល់ពេលគេការហើយ – ចាប់ដៃហើយគេថាឲ្យឡើងប្តេជ្ញា។ មានម្នាក់ -- ពីរនាក់គេឡើងប្តេជ្ញា គេឲ្យប្តេជ្ញាហើយ គេឲ្យយើងចេញទៅរៀងៗខ្លួន ទៅតាមផ្ទះរៀងៗខ្លួនចាស។ ហើយពេលគេបង្ខំខ្ញុំឲ្យរៀបការ ខ្ញុំប្រកែកគេ។ គេប្រាប់ខ្ញុំថា

“បើអ្នកឯងមិនរៀបការទេ អ្នកឯងទៅញញឹមដាក់បុរសណាក៏អត់បានដែរ។ បើញញឹមដាក់បុរសណាគេឃើញ នោះអ្នកនឹងត្រូវ ប្រយ័ត្នតែងាប់” គេថាអ៊ីចឹង។ ហើយខ្ញុំភ័យក៏ខ្ញុំ –ទុកខ្ញុំមិនបានស្រឡាញ់បុរសនោះ– ក៏ខ្ញុំត្រូវតែរៀបការដែរចាស ដើម្បីខ្ញុំខ្លាចៗស្លាប់។ ដល់ពេលគេការហើយ គេបង្ខំឲ្យខ្ញុំទៅរៀងៗខ្លួន។ ខ្ញុំក៏ទៅបន្ទប់ហ្នឹងក៏ខ្ញុំញ័រដូចកូនកណ្ដុរអ៊ីចឹងចាស។ ពេលដែលគេនេះហើយ ក៏ខ្ញុំអត់បានប្រាប់អ្នកដែលស្រឡាញ់ខ្ញុំថា “ពូអើយអាណិតខ្ញុំទៅ ពូឯងកុំអាលធ្វើអីខ្ញុំ ខ្ញុំខ្លាចណាស់”។ ដល់ហើយអ្នកនោះក៏គេអត់បានធ្វើអ្វីខ្ញុំដែរ។ ដល់ពេលនោះក៏មាន មិនដឹងជាឈ្លបគេ ឬគេអ្វីឮសូរស្នូរជើងគេដើរនៅខាងក្រៅហ្នឹង ខ្ញុំក៏ភ័យញ័រ ខ្ញុំខ្លាចៗគេចាស។

**ស៖** ចាស សូមអរគុណអ្នកស្រី។ អ៊ីចឹងសំណួរចុងក្រោយទាក់ទងជាមួយនឹងប្រធានបទមួយនេះ ខ្ញុំចង់សួរថា តើអ្នកស្រីជាមួយនឹងប្ដីដែលអង្គការបានរើសឲ្យអ្នកស្រីនោះ ថាតើសព្វថ្ងៃនេះរស់នៅជាមួយនឹងគ្នា ឬក៏មានកើតឡើងរវាងអ្នកស្រី និងគាត់?

**ឆ៖** ចាស ខ្ញុំអត់បានរស់នៅជាមួយទេ។ ខ្ញុំការបាន៣ថ្ងៃ ក៏បែកគ្នារហូតចាស។

**លោកស្រី ម៉ុច សុវណ្ណារី៖**

ចាស សូមអរគុណអ្នកស្រីចំពោះការឆ្លើយនឹងសំណួររបស់ខ្ញុំ ហើយសូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរសួរដល់ដើមបណ្ដឹងរដ្ឋប្បវេណីនេះទៀតហើយ។ សូមអរគុណ។

[១៤:២៧:៥៤]

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកមេធាវី។

បន្ដទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាមានឱកាសសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

**ស៖** ជម្រាបសួរលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ យើងខ្ញុំសល់ពេលតិចនាទីទេ ដូច្នេះខ្ញុំសូមឲ្យលោកស្រីឆ្លើយសង្ខេបខ្លីៗបានហើយទៅនឹងសំណួររបស់ខ្ញុំ។ ខ្ញុំសូមសួរសំណួរមួយចំនួនតូចទាក់ទង

ទៅនឹងប្រធានបទដែលលោកស្រីទើបឆ្លើយអម្បាញ់មិញនេះ គឺការរៀបការរបស់លោកស្រីនៅក្នុងរបបខ្មែរក្រហម។ លោកស្រីបាននិយាយថា ក្រោយពីលោកស្រីរៀបការ លោកស្រីបានត្រឡប់ទៅរស់នៅជាមួយប្ដីរបស់លោកស្រី។ ហើយនៅក្នុងទម្រង់ព័ត៌មានបន្ថែមគឺឯកសារ E3/4807 លោកស្រីបាននិយាយថា៖ "ក្រោយពីបាយជាមួយគ្នា យើងជាប្ដីប្រពន្ធបានទៅផ្ទះជាមួយគ្នា ហើយខាងឈ្លបគេមកពិនិត្យមើលថាតើយើងចុះសម្រុងគ្នា ឬក៏អត់ទេ? ទោះបីយើងរៀបការជាមួយគ្នាក៏ដោយ ប៉ុន្តែយើងខ្ញុំមិនបានរួមភេទជាមួយគ្នាទេ ហើយខ្ញុំប្រាប់ប្ដីរបស់ខ្ញុំថាឲ្យលាក់ការណ៍សម្ងាត់។ ហើយដល់ពេលរបបនោះចប់ទៅ យើងក៏អត់បានរស់នៅជាមួយគ្នាទេ។" តើលោកស្រី -- សូមលោកស្រីពន្យល់បន្តិចមើលថា នៅពេលអ្នកស៊ើបការណ៍មានអាវុធមកលបស្ដាប់លោកស្រីហ្នឹង តើគេចង់ធ្វើយ៉ាងម៉េចដែរ? លោកស្រីជម្រាបលម្អិតបន្តិចមើល៍?

[១៤:២៩:៥៤]

**លោកស្រី ជុំ សាមឿន៖**

**ឆ៖** ចាសមានឈ្លបគេតាមដានហ្នឹង គេៗអត់បានចង់ធ្វើអីទេ ព្រោះខ្ញុំអត់បានដឹងគេកាន់អាវុធឬអីទេ ព្រោះខ្ញុំឮតែសម្រឹបជើងដើរចាស។

**ស៖** តើលោកស្រីដឹងថាគេមកលបស្ដាប់លោកស្រីនេះ គេចង់ដឹងពីរឿងអ្វី?

**ឆ៖** គេចង់ដឹងថាយើងចុះសម្រុងអត់។

**ស៖** តើលោកស្រីអាចជម្រាបជូនតុលាការបានទេថា ហេតុអ្វីបានជាលោកស្រីត្រូវលាក់ការណ៍សម្ងាត់ដែលថាលោកស្រី ហើយនិងប្ដីលោកស្រីហ្នឹងគឺមិនបានរួមសង្វាសជាមួយគ្នាទេ? ហេតុអ្វីបានជាលោកស្រីថាត្រូវតែលាក់ការណ៍សម្ងាត់នេះ?

**ឆ៖** ព្រោះខ្លាចគេដឹងចាស។ ត្រូវតែលាក់ការណ៍ ខ្លាចដឹង ព្រោះខ្ញុំ និង -- ខ្ញុំត្រូវ -- គេថាឪពុកខ្ញុំជាប៉ូលិស ឪពុកចុងជាទាហាន គឺគេថាខ្ញុំ១៧មេសា។ អ៊ីចឹងខ្ញុំត្រូវតែលាក់ការណ៍សម្ងាត់រឿងនេះ កុំឲ្យគេដឹង ខ្លាចគេយកខ្ញុំទៅធ្វើបាប ចាស។

**ស៖** តើលោកស្រីខ្លាចអ្វី បើសិនណាជាគេដឹងថា លោកស្រីនេះមិនបានរួមដំណេកជាមួយប្ដីលោកស្រីទេនោះ?

**ឆ៖** ចាស អត់បានរួមដំណេកទេ ព្រោះខ្ញុំខ្លាច ខ្ញុំធម្មតា ស្រីយើងមិនមែនការភ្លាម រឹបភ្លាមទេ។ ខ្ញុំញ័រដៃញ័រជើងណាស់ ខ្ញុំខ្លាច ខ្ញុំឲ្យប្ដីខ្ញុំលាក់ការណ៍ថា ឲ្យលាក់ការណ៍ឲ្យជិតទៅ ហើយក៏បានលាក់

ការណ៍ជិតរហូតដល់សព្វថ្ងៃចាស។

**ស៖** ខ្ញុំយល់។ ប្រហែលជាសំណួរខ្ញុំសួរទៅវាមិនបានច្បាស់មើល៍ទៅ។ ប៉ុន្តែខ្ញុំចង់ដឹងថាហេតុអ្វីបានជាលោកស្រីខ្លាច រហូតថាត្រូវតែលាក់ការណ៍សម្ងាត់ ដោយសារថាមិនបានៗរួមសង្វាសជាមួយគ្នា? បើសិនណាខ្មែរក្រហមរកឃើញថា លោកស្រី ហើយនិងប្ដីលោកស្រី មិនបានរួមសង្វាសជាមួយគ្នាទេ លោកស្រីភ័យ តើវាមានអ្វីកើតឡើងបើគេដឹង?

[១៤:៣២:៤៤]

**ឆ៖** ចាស ខ្ញុំអត់ដឹងមានអ្វីកើតឡើងទេ បើគេដឹងចាស។ កាលហ្នឹងខ្ញុំប្រាប់ប្ដីខ្ញុំថា ខ្ញុំភ័យណាស់ ទើបតែការអឺចឹង ខ្ញុំខ្លាចណាស់ កុំប៉ះពាល់ខ្ញុំ។ អឺចឹងនាំគ្នាលាក់ការណ៍សិនទៅកុំឲ្យគេដឹង។ ខ្ញុំគ្រាន់ប៉ុណ្ណឹង។

**ស៖** សំណួរចុងក្រោយទៅលើប្រធានបទនេះ។ លោកស្រីចាំទេអ្នកណាៗ ជាអ្នករៀបចំពិធីការឲ្យលោកស្រី?

**ឆ៖** ចាស មេកងឈ្មោះ ម៉េត ចាសគេរៀបចំការឲ្យខ្ញុំ។

**ស៖** តើៗសមមិត្តនារី ម៉េត នេះគ្រាន់តែដឹកនាំការរៀបការនេះ ឬក៏គាត់គឺជាអ្នករៀបចំចាត់ចែងផ្គូផ្គងទាំងអស់នេះ?

**ឆ៖** ចាស គាត់ជាអ្នកផ្គូផ្គងឲ្យខ្ញុំ។

**ស៖** ហើយក្រោយគាត់ផ្គូផ្គងជាមួយប្ដីរបស់លោកស្រី គឺថាៗក៏មានពិធីរៀបការប្រាំគូ។ តើគាត់ក៏ជាអ្នកដឹកនាំពិធីរៀបការគូស្រករទាំងប្រាំគូហ្នឹង ឬក៏អត់ទេ?

**ឆ៖** ចាសពេលហ្នឹងគាត់ផ្គូផ្គងរៀបចំការទាំងប្រាំគូហ្នឹង។

**ស៖** សូមអរគុណ ឥឡូវនេះ ខ្ញុំសូមចូលទៅសួរលោកស្រីអំពី តើនៅក្នុងកងពល២០៥នេះ នៅពេលដែលលោកស្រីទៅធ្វើការនៅតាមវាលស្រែ ហើយក្រោយមកគេបញ្ជូនលោកស្រីទៅធ្វើការនៅព្រលានយន្តហោះ។ នៅក្នុងទម្រង់ព័ត៌មានបន្ថែម E3/4807, ERN 00846968, បារាំង 00578977, ខ្មែរ 00578979។ លោកស្រីឆ្លើយដូចតទៅ៖ “ខ្ញុំត្រូវបានគេបញ្ជូនមកអូរបែកក្អមនៅភ្នំពេញ ធ្វើស្រែនៅអូរបែកក្អមភ្នំពេញ ដោយសារតែប្រវត្តិរូបខ្ញុំមិនល្អ ដោយសារឪពុករបស់ខ្ញុំគឺជាប៉ូលិសក្នុងរបបសីហនុ ហើយឪពុកចុងខ្ញុំនោះ នុត ជា នេះគឺជាទាហាន លន់ នល់។” បញ្ចប់ការដកស្រង់។ តើត្រឹមត្រូវដែរទេ ដូចដែលលោកស្រីបានឆ្លើយនៅក្នុងទម្រង់ព័ត៌មានបន្ថែមរបស់លោកស្រីនេះ? ហើយដូច

លោកស្រីបញ្ជាក់បន្ថែមនៅនឹងសំណួរមុននេះបន្តិចនេះថា ក្រោយពីលោកស្រីផ្ដល់ប្រវត្តិរូបទៅ គេរកឃើញថាឪពុករបស់លោកស្រីបង្កើត និងឪពុកចុងមានជាប់ទាក់ទងទៅនឹងរបប សីហនុ និងរបប លន់ នល់។ អ៊ីចឹងឯងបានជាលោកស្រីត្រូវបានគេបញ្ជូនឲ្យទៅធ្វើស្រែនៅអូររបៃកក្អម។

[១៤:៣៦:៤៦]

**ផ៖** ចាស អ៊ីចឹងមែន។ គេរកឃើញថាខ្ញុំពាក់ព័ន្ធឪពុកធ្វើប៉ូលិស ឪពុកចុងធ្វើជាទាហាន។ គេរកឃើញខ្ញុំអ៊ីចឹងមែន បានគេបញ្ជូនខ្ញុំទៅអូរបែកក្អមចាស។

**ស៖** តើគេដែលប្រាប់លោកស្រី ឬលោកស្រីគិតថាហេតុអ្វីបានជាលោកស្រី សូមដកស្រង់ "មានប្រវត្តិមិនល្អ" បញ្ចប់ការដកស្រង់។ ដោយសារតែឪពុក ឪពុកចុងមានជាប់ទាក់ទងទៅនឹងរបបមុន?

**ផ៖** ចាស សូមឆ្លើយម្ដងទៀត ខ្ញុំអត់ច្បាស់។

**ស៖** បាទ លោកស្រីបានឆ្លើយនៅក្នុងទម្រង់ព័ត៌មានបន្ថែមរបស់លោកស្រី ដែលថាបានជាគេបញ្ជូនលោកស្រីទៅអូរបែកក្អម សូមដកស្រង់ "ដោយសារតែប្រវត្តិរូបខ្ញុំមិនល្អ" បញ្ចប់ការដកស្រង់។ តើហេតុអ្វីដែលគ្រាន់តែឪពុករបស់លោកស្រី និងឪពុកចុងរបស់លោកស្រីគឺជាទាហាន និងជាប៉ូលិសក្នុងរបប លន់ នល់ និងសីហនុ គេចាត់ទុកលោកស្រីថាលោកស្រីថាមានប្រវត្តិរូបមិនល្អ?

**ផ៖** ចាស គេដកស្រង់ថាឪពុកខ្ញុំជាប់ពាក់ព័ន្ធនិន្នាការនៅរបប លន់ នល់ ហ្នឹងបានគេថាខ្ញុំប្រវត្តិរូបមិនល្អ។

**ស៖** លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងទម្រង់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី គឺ D22/1067 លោកស្រីនិយាយពាក់ព័ន្ធទៅនឹងការបញ្ជូនលោកស្រីទៅឲ្យធ្វើស្រែនៅអូរបែកក្អម សូមដកស្រង់៖ "ខ្មែរក្រហម ហេតុដូច្នេះខ្មែរក្រហមចាត់ទុកខ្ញុំនេះជា ទៅក្នុងក្រុមមនុស្សដែលមាននិន្នាការពាក់ព័ន្ធសាច់ញាតិពាក់ព័ន្ធនឹងខ្លាំង។ គេចាត់តាំងឲ្យខ្ញុំទៅធ្វើស្រែដោយគេចាត់ទុកថាខ្ញុំគឺជាអ្នកទោស។" តើត្រឹមត្រូវទេដែលថា ក្រោយពេលគេដឹងពីប្រវត្តិរូបរបស់លោកស្រី ខ្មែរក្រហមចាត់ទុកលោកស្រីគឺជាអ្នកទោស?

[១៤:៣៩:២៤]

**ផ៖** ចាស ពិតមែន គេថាខ្ញុំជាអ្នកទោស។

**ស៖** តាមដែលលោកស្រីដឹងបានច្រើនបំផុតនោះ ការដែលចាត់ទុកថា នៅពេលដែលលោកស្រី

ត្រូវគេបញ្ជូនទៅកំពង់ឆ្នាំងព្រលានយន្តហោះកំពង់ឆ្នាំង តើគេនៅចាត់ទុកលោកស្រីជាអ្នកទោសដដែលទេ?

**ឆ៖** ចាស គេនៅចាត់ទុកខ្ញុំថាជាអ្នកទោសដដែល។

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំឃើញមើលទៅ ខ្ញុំអស់ម៉ោងហើយ។ សូមអរគុណលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកព្រះរាជអាជ្ញា។ នាពេលនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី អញ្ជើញចូលវិញ។

សូមអញ្ជើញសម្រាក!

*(សវនាការសម្រាកពីម៉ោង ១៤:៤០ នាទី ដល់ម៉ោង ១៤:៥៨ នាទី)*

[១៤:៥៨:០៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

តទៅនេះ ផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដី ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។ ហើយភាគីសហមេធាវីទាំងពីរក្រុមមានពេលវេលាពីពេលនេះ រហូតដល់បញ្ចប់សវនាការនៅរសៀលនេះ ក្នុងការតាំងសំណួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញលោកមេធាវីការពារលោក នួន ជា លោក កូប៉េ! សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ លោកស្រីកើតនៅឆ្នាំ១៩៦០ មានន័យថាលោកស្រីមានអាយុ១៥ឆ្នាំ នៅក្នុងឆ្នាំ៧៥។ ត្រឹមត្រូវដែរទេ?

**លោកស្រី ជុំ សាមឿន៖**

**ឆ៖** ចាស ត្រឹមត្រូវហើយ។

**ស៖** តើលោកស្រីកើត និងរស់នៅធំដឹងក្ដីនៅខេត្តកំពត ឬក៏យ៉ាងណា?

**ឆ៖** ចាស រស់នៅដឹងក្ដីនៅស្រុកឈូក ខេត្តកំពត ចាស។

[១៤:៥៩:៥៨]

**ស៖** នៅចន្លោះពីឆ្នាំ៧៥ ទៅដល់៧៩ តើខេត្តកំពត គឺជាផ្នែកមួយនៃភូមិភាគនិរតីឬ?

**ឆ៖** ចាស ខ្ញុំ កាលហ្នឹងខ្ញុំអត់បានដឹងទេ ទើបដឹងឥឡូវ។

**ស៖** ប្រហែលជាខ្ញុំយល់មិនបានច្បាស់ទេ។ តើលោកស្រីចូលរួមក្នុងកងទ័ពបដិវត្តន៍នៅពេលណា? ចូលរួមនៅពេលរំដោះប្រទេសនោះតែម្ដង ឬក៏ចូលរួមតាំងពីមុនរំដោះ?

**ឆ៖** ចាស ចូលមុនរំដោះ។

**ស៖** លោកស្រីចាំទេ តើមានរយៈពេលប៉ុន្មានអាទិត្យ ប៉ុន្មានខែ ឬក៏ប៉ុន្មានឆ្នាំមុនពេលរំដោះ?

**ឆ៖** ខ្ញុំអត់បានចាំទេ។

**ស៖** លោកស្រីអាចឆ្លើយប្រហាក់ប្រហែលបានទេ ដូចជាចូលរួមនៅឆ្នាំ៧៣ ឬក៏៧៤? អាចផ្ដល់ចម្លើយប្រហាក់ប្រហែលបានទេ?

**ឆ៖** ខ្ញុំអត់បានចាំទេ ចាស។

**ស៖** តើលោកស្រីមានបងប្អូនប្រុសស្រីដែលបានចូលរួមជាមួយបដិវត្តន៍ ដូចជាលោកស្រីបានចូលរួមនៅមុនឆ្នាំ១៩៧៥នេះដែរឬទេ?

**ឆ៖** ចាស មានតែជីដូនមួយ។

[១៥:០២:១២]

**ស៖** ខ្ញុំសូមអានឲ្យលោកស្រីស្ដាប់នូវចម្លើយរបស់លោកស្រីគឺ D22/1067 ERN អង់គ្លេស 00842140។ លោកនិយាយថា -- លោកស្រីនិយាយថា៖ "បងប្រុសពីរ ជុំ ជន, ជុំ ស៊ីត -- បាទ គឺឈ្មោះ ជុំ សៀប, ជុំ ជឿន និង ជុំ ផុន។" តើទាំងបីនាក់នេះចូលរួមបដិវត្តន៍នៅមុនឆ្នាំ១៩៧៥ឬ?

**ឆ៖** ចាស ប្អូនខ្ញុំ ជុំ ផុន អត់បានចូលរួមបដិវត្តន៍ទេ គឺនៅសហករណ៍ខាងក្រោយ ចាស។ ហើយ ជុំ ជឿន និង ជុំ សៀប គាត់ក៏នៅសហករណ៍ខាងក្រោយដែរ។

**ស៖** តើបងនិងប្អូនប្រុសរបស់លោកស្រីបានចូលរួមក្នុង -- ធ្វើជាកងទ័ពដើម្បីប្រយុទ្ធប្រឆាំង

ជាមួយទាហាន លន់ នល់ ដែរទេ គឺបងប្រុសឈ្មោះ ជុំ សៀប និង ជុំ ជឿន?

**ឆ៖** ចាស កាលហ្នឹងដូចខ្ញុំភ្លេច មិនដឹងបងខ្ញុំទៅធ្វើទាហានកងទ័ពបដិវត្តន៍។ ចាស គាត់បានទៅ ខ្ញុំភ្លេចចាស។ គាត់ទៅទាំងពីរនាក់។

**ស៖** ខ្ញុំខ្លាចក្រែងខ្ញុំយល់មិនបានច្បាស់ ថាតើបងប្រុសៗរបស់លោកស្រីបានចូលរួមធ្វើកងទ័ពបដិវត្តន៍ដូចលោកស្រីដែរទេ?

**ឆ៖** ចាស បានទៅ។

**ស៖** ដូច្នេះតើត្រឹមត្រូវដែរទេ បើខ្ញុំនិយាយថា បងប្អូន -- បងនិងប្អូន ក៏ដូចជាលោកស្រីផ្ទាល់ទាំងបួននាក់ហ្នឹង គឺថាជាកម្មាភិបាលមកពីភូមិភាគនិរតី? ត្រឹមត្រូវដែរទេ?

**ឆ៖** ចាស អត់ត្រឹមត្រូវទេ។

**ស៖** បើមិនត្រឹមត្រូវទេ តើវាយ៉ាងដូចម្ដេចដែរអ៊ីចឹង?

**ឆ៖** ចាស ខ្ញុំអត់មានបានកម្មាភិបាលអីទេ។

[១៥:០៥:១៩]

**ស៖** នៅចម្លើយរបស់លោកស្រី ដែលខ្ញុំមាននៅខាងមុខនេះគឺ ERN ជាភាសាបារាំងគឺ 00505922 គឺឯកសារ D22/1067 ដែលលោកស្រីបានបញ្ជាក់ថា បងប្រុសរបស់លោកស្រីពីរនាក់និងប្អូនប្រុសម្នាក់ត្រូវបានសមមិត្តប៉ែត សម្លាប់ចោល ដោយចោទប្រកាន់ថាជាភ្នាក់ងារខ្មាំង។ តើលោកស្រីបានឆ្លើយថាយ៉ាងដូច្នេះមែនទេ?

**ឆ៖** បងប្រុសខ្ញុំពីរនាក់ គឺខ្ញុំអត់បានដឹងអ្នកណាសម្លាប់ទេ។ តែប្អូនខ្ញុំចាស ពិតមែន គេសម្លាប់ពិតមែន។

**ស៖** ខ្ញុំនឹងអានដែរ នៅក្នុងឆ្នាំ១៩៧៨ លោកស្រីឆ្លើយអ៊ីចឹងថា៖ "ជាការឲ្យសោកស្ដាយបងប្រុសខ្ញុំពីរនាក់ និងប្អូនប្រុសម្នាក់ ជុំ សៀប, ជុំ ជឿន និង ជុំ ផុន ជាកសិករទាំងបីនាក់ហ្នឹង គឺត្រូវបានសមមិត្តប៉ែត សម្លាប់ចោល គឺជាប្រធានកងវរសេនាធំនៅក្នុងស្រុកកំពត ដោយចោទប្រកាន់បងប្អូនខ្ញុំទាំងបីនាក់ថា ជាភ្នាក់ងារខ្មាំង។" តើលោកស្រីបានឆ្លើយថា អ៊ីចឹងមែនទេ?

**ឆ៖** ចាស ខ្ញុំអត់បានឆ្លើយអ៊ីចឹងផង។

**ស៖** ដូច្នេះបង និងប្អូនប្រុសរបស់លោកស្រីហ្នឹង គឺមិនត្រូវបានឈ្មោះ ប៉ែត ហ្នឹងសម្លាប់ចោលទេ។ អ៊ីចឹងមែនទេ?

**ផ៖** ចាស អត់បានសម្លាប់ទេ។ បានសម្លាប់តែប្អូនខ្ញុំ ជុំ ផុន ចាស។

[១៥:០៧:៥២]

**ស៖** តើសមមិត្តប៉ែត ពិតជាប្រធានវរសេនាធំ១៣៥ ត្រឹមត្រូវទេ?

**ផ៖** ខ្ញុំអត់បានស្គាល់ មិត្តប៉ែត ទេ។ ខ្ញុំ ដល់ខ្ញុំមកភូមិវិញ ឮមីងខ្ញុំនិយាយប្រាប់ខ្ញុំ បានខ្ញុំដឹង។

**ស៖** អ៊ីចឹងតើអ្នកណាជាប្រធានវរសេនាធំ១៣៥?

**ផ៖** ខ្ញុំអត់បានដឹងវរសេនាធំ១៣៥ ទេចាស។

**ស៖** តើលោកស្រី គឺជាសមាជិកម្នាក់នៅក្នុងកងវរសេនាធំ១៣៥ មិនអ៊ីចឹង?

**ផ៖** ចាស ខ្ញុំសមាជិកវរសេនាតូច១៣៥ មិនមែនវរសេនាធំទេ។

**ស៖** បាទ មិនអីទេ គឺអ៊ីចឹងមានការបកប្រែឯកសាររបស់លោកស្រីនេះ ឯកសារហ្នឹងប្រើពាក្យថា វរសេនាធំ ប៉ុន្តែមិនអីទេ។ តើអ៊ីចឹងតើអ្នកណាជាប្រធាន ជាមេបញ្ជាការវរសេនាតូចលេខ១៣៥?

**ផ៖** ចាស ជាប្រធានវរសេនាតូច១៣៥ គឺមិត្តម៉េត ចាស។

**ស៖** ខ្ញុំមិនយល់ថា ម៉េត ទេ។ ម៉េត គឺជាមេបញ្ជាការកងពល៥០២ ខ្ញុំសួរថា អ្នកណាជាមេបញ្ជាការកងវរសេនាធំ ឬក៏លោកស្រីនិយាយអម្បាញ់មិញថា វរសេនាតូច។ អ៊ីចឹងអ្នកមេបញ្ជាការវរសេនាតូច១៣៥?

**ផ៖** ចាស សមមិត្ត ម៉េត ហ្នឹងគាត់ជាស្រីចាស។

**ស៖** ឥឡូវនេះខ្ញុំកំពុងនិយាយ ស៊ូ ម៉េត មេបញ្ជាកងពល៥០២ ប្រុសទេ។ អ៊ីចឹងមែនទេ?

**ផ៖** ចាស ស៊ូ ម៉េត កងពល៥០២ គាត់ជាប្រុស។

**ស៖** អ៊ីចឹងអ្នកណាជាមេបញ្ជាការវរសេនាតូច១៣៥ ជាមេបញ្ជាការរបស់លោកស្រីផ្ទាល់នេះ?

**ផ៖** ចាស មិត្តម៉េត ជាស្រីហ្នឹង ចាស។

[១៥:១១:២៣]

**ស៖** បាទ ចុះម្នាក់ទៀតមេបញ្ជាការស្រីដែរ ឈ្មោះ សុខា ហ្នឹង សមមិត្តនារី សុខា ជាអ្នកណា?

**ផ៖** សុខា ក៏នៅក្នុងហ្នឹងដែរ ចាស។

**ស៖** តើសមមិត្តនារី សុខា នេះមានឋានន្តរសក្តិប៉ុន្មានដែរ? ជាអនុមេបញ្ជាការកងវរសេនាតូច១៣៥ឬ?

**ផ៖** ចាស កាលហ្នឹងខ្ញុំមិនដឹងគេអនុ ក៏ប្រធានទេ។ ខ្ញុំអត់បានដឹងគេធ្វើអីដែរ។

**សៈ** តើត្រឹមត្រូវទេ ដែលថានៅពេលមួយនោះ ក្រោយឆ្នាំ១៩៧៥ លោកស្រីក្លាយទៅជាពេទ្យនៅក្នុងកងពល៥០២ ដែលឈរជើងនៅព្រលានយន្តហោះពោធិ៍ចិនតុង ត្រឹមត្រូវទេ?

**ឆៈ** ចាស ខ្ញុំអត់បានធ្វើពេទ្យផង។

**សៈ** ខ្ញុំអានឯកសារ D22/1067 "មុនឆ្នាំ១៩៧៥ ខ្ញុំជាកងទ័ពរបស់ខ្មែរក្រហមមានតួនាទីជាពេទ្យនៅក្នុងកងពល៥០២ នៅពោធិ៍ចិនតុង ដែលមានសមមិត្ត សាម៉េត ជាប្រធានវរៈលេខ១៣៥ និងមិត្តនារី សុខា ជាអនុវរសេនាតូចលេខ១៣៥ ដែលនៅទីនោះរហូតដល់--" ថាតើលោកស្រីគឺជាពេទ្យម្នាក់ប្រចាំនៅកងពល៥០២ មែនទេ?

**ឆៈ** ចាស ខ្ញុំអត់បានធ្វើពេទ្យទេ។ អ៊ីចឹងច្រឡំហើយ។

[១៥:១៤:០៤]

**សៈ** លោកស្រី នៅពេលលោកស្រីឆ្លើយនូវអ្វីដែលបានកើតឡើងចំពោះលោកស្រីក្នុងរបបខ្មែរក្រហម លោកស្រីឆ្លើយប្រាប់ទៅអ្នកណាគេ?

**ឆៈ** ចាស ពេលគេទៅសួរ ខ្ញុំអត់បានស្គាល់ឈ្មោះគេ ខ្ញុំភ្លេចហើយ។

**សៈ** ឥឡូវខ្ញុំសូមអានពីឯកសារ D22/1067 ដដែល។ ERN គឺដូចខ្ញុំបានជម្រាបខាងដើមហើយៗ៖ "នៅដើមឆ្នាំ១៩៧៦ ខ្ញុំត្រូវបានអង្គការបដិវត្តន៍ឱ្យទៅស្រាវជ្រាវតាមដានប្រវត្តិរូបកងទ័ពទាំងអស់។" តើលោកស្រីបានឆ្លើយអ៊ីចឹងដែរឬទេ?

**ឆៈ** ចាស ខ្ញុំអត់បានឆ្លើយអ៊ីចឹងទេ គឺគេតាមដានតែខ្ញុំតែម្នាក់ឯងទេពេលនោះចាស។

**សៈ** សូមលោកស្រីជម្រាបជូនតុលាការ ថាហេតុអ្វីដែលថានៅលើកដំបូង -- ហេតុអ្វីបានជាលោកស្រីចូលរួមជាមួយកងពល៥០២ជាលើកដំបូង? ហើយក្រោយមកគេរកឃើញថា លោកស្រីមានជាប់ទាក់ -- ឪពុករបស់លោកស្រីជាក់ទាក់ទងជាមួយនឹងអតីតរបប លន់ នល់? លោកស្រីអាចពន្យល់ទេថា ហេតុអីបានជាគេមិនអាចរកឱ្យឃើញ ឱ្យដឹងពីប្រវត្តិរូបនេះតាំងពីខាងដើមមក?

**ឆៈ** ចាស កាលនោះខ្ញុំនៅជាមួយជីដូនចាស់ នៅឃុំឈូក ស្រុកឈូក ខេត្តកំពត។ ខ្ញុំមិនបានដាក់ប្រវត្តិរូបខ្ញុំថា មានឪពុកម្ដាយជាប់ពាក់ព័ន្ធទាហាន លន់ នល់ ទេ។ ខ្ញុំយកជីដូនរបស់ខ្ញុំធ្វើជាម្ដាយរបស់ខ្ញុំ។

**សៈ** ដូច្នេះនៅពេលដែលលោកស្រីចូលរួមជាមួយបដិវត្តន៍ កម្លាំងរបស់កងពលដែលជាកម្លាំងរបស់ តាម៉ុក ហ្នឹងនេះ អត់ដឹងថាឪពុកលោកស្រីហ្នឹងមានតួនាទីនៅក្នុងរបបសាធារណរដ្ឋខ្មែរទេ។ តើ

លោកស្រីកំពុងនិយាយថាអ៊ីចឹងមែនទេ?

[១៥:១៦:៥៥]

**ឆ៖** ចាស កាលអត់ដឹងទេ ហើយខ្ញុំអត់មានបាននៅទ័ព តាម៉ុក ទេ។

**ស៖** ប៉ុន្តែលោកស្រីគឺជាកងទ័ពនៅកងពល៥០២ ហើយខ្ញុំជឿជាក់ថា កងពល៥០២នេះជាកងពលរបស់ភូមិភាគនិរតី។ លោកស្រីដឹងថាអ៊ីចឹងដែរទេ?

**ឆ៖** ចាស ខ្ញុំអត់បានដឹងផង។

**ស៖** លោកស្រីស្គាល់ តាម៉ុក ទេ?

**ឆ៖** ខ្ញុំអត់បានស្គាល់ តាម៉ុក ទេ ទើបឮគេថាសម័យឥឡូវហ្នឹង។

**ស៖** តើលោកស្រីធ្លាប់បានឮឈ្មោះ តាម៉ុក ដែរទេ នៅពេលនោះនៅក្នុងរបបនោះ?

**ឆ៖** ចាស អត់បានឮទេ។

**ស៖** តើលោកស្រីដឹងថា តើ ស៊ូ ម៉េត ជាអ្នកណាដែរទេ?

**ឆ៖** ខ្ញុំអត់បានដឹង ស៊ូ ម៉េត ឈ្មោះអីទេ ដឹងតែគេថាឈ្មោះ ស៊ូ ម៉េត១ នៅកងពល៥០២។

**ស៖** លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី លោកស្រីឆ្លើយថា លោកស្រីជាកងទ័ពនៅក្នុងកងពល៥០២ គួរណាស់តែលោកស្រីដឹងមេបញ្ជាការរបស់កងពលនេះដែលជាមេបញ្ជាការរបស់ខ្លួន។

**ឆ៖** ចាស ខ្ញុំអត់បានដឹងទេ ព្រោះខ្ញុំអត់បានសួរគេឯងថា ដឹងពីប្រវត្តិរបស់ តាម៉េត ទេ។ ចាស ខ្ញុំអត់ដឹង។

**ស៖** លោកស្រីដឹងថា នៅក្នុងកងពល៥០២ហ្នឹងមានយុទ្ធនារីសរុបទាំងអស់ប៉ុន្មាននាក់ដែរ?

**ឆ៖** ចាស មានវរៈ៥០២ យុទ្ធនារីមួយកងវរសេនាតូច។

**ស៖** ហើយនៅក្នុងកងពលនេះគឺថា សរុបតែម្តងមានយុទ្ធនារីប្រយុទ្ធហ្នឹងសរុបទាំងអស់ប៉ុន្មាន?

**ឆ៖** ខ្ញុំអត់ដឹងមានប្រយុទ្ធប៉ុន្មានទេ។ ចាស ខ្ញុំអត់បានដឹងផង។ ដឹងតែមួយវរសេនាតូចហ្នឹងមានបីអនុសេនាធំ។ ខ្ញុំបានដឹងគេ កម្លាំងគេប៉ុន្មានផង។

[១៥:២០:៣៤]

**ស៖** តើលោកស្រីដឹងថាកងពល៥០២នេះមានភារកិច្ចចម្បងធ្វើអ្វីដែរ? តើកងពល៥០២នេះមានភារកិច្ចធ្វើអ្វី? ហើយគេចាត់ទុកថាកងពល៥០២ ជាផ្នែករបស់ៗកងទ័ពខាងណាដែរ?

**ឆ៖** ខ្ញុំអត់បានដឹងទាំងអស់។

**ស៖** ពេលណាខ្ញុំនិយាយថាកងពល៥០២ គឺ -- តើកងពល៥០២នេះជាកងទ័ពអាកាសរបស់កងទ័ពបដិវត្តន៍មែនឬ?

**ឆ៖** ចាស ពិតមែន។

**ស៖** ខ្ញុំសូមចូលទៅសួរពីព្រលានយន្តហោះកំពង់ឆ្នាំង។ តើហេតុអ្វីបានជាគេបញ្ជូនលោកស្រី និងកងរបស់លោកស្រីទៅព្រលានយន្តហោះកំពង់ឆ្នាំង គេមានប្រាប់ពីមូលហេតុក្នុងការបញ្ជូនលោកស្រីទៅទីនោះទេ?

**ឆ៖** គេអត់បានប្រាប់ពីមូលហេតុទេ គ្រាន់តែគេប្រាប់ថា ត្រូវទៅធ្វើការនៅព្រលានកំពង់ឆ្នាំងតែម្តង។

**ស៖** តើគេមានប្រាប់លោកស្រីថា ក្នុងការឱ្យទៅធ្វើតែ៣ខែ ឬក៏យូរជាង៣ខែបន្តិចហ្នឹង គេមានប្រាប់មូលហេតុហ្នឹងដែរទេ?

**ឆ៖** គេអត់បានប្រាប់មូលហេតុផង។

[១៥:២២:៤៥]

**ស៖** តើសមមិត្តនារី សុខា មេបញ្ជាការរបស់លោកស្រីនេះ នៅពេលលោកស្រីធ្វើការនៅៗតែជាមេបញ្ជាការរបស់លោកស្រីដដែលឬ នៅពេលលោកស្រីធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំង?

**ឆ៖** ចាស នៅដដែល។

**ស៖** តើគាត់មានចាត់តាំងការងារអ្វីឱ្យលោកស្រីធ្វើទេ នៅព្រលានយន្តហោះកំពង់ឆ្នាំង?

**ឆ៖** ខ្ញុំអត់បានដឹងគេចាត់ការងារទេ ចាស។ ពេលហ្នឹងខ្ញុំជាយុទ្ធនារី ខ្ញុំអត់បានដឹងអី។

**ស៖** ប៉ុន្តែខ្ញុំសួរថា តើសមមិត្តនារី សុខា នេះមានបញ្ជាឱ្យលោកស្រីបំពេញភារកិច្ចអ្វី ឬការងារអ្វីជាក់លាក់មួយទេ? ដោយសារ -- ហើយតើនៅពេលហ្នឹង គាត់នៅតែជាមេបញ្ជាការផ្ទាល់របស់លោកស្រីដែរឬ សមមិត្តនារី សុខា ហ្នឹង?

**ឆ៖** ចាស ពេលហ្នឹងនៅតែមេបញ្ជាការដដែល។ តែដល់ពេលខ្ញុំទៅព្រលានកំពង់ឆ្នាំង គឺខ្ញុំទៅតែជាមួយកងអនុសេនាធំតែប៉ុណ្ណោះ។

**ស៖** សំណួររបស់ខ្ញុំសួរថា គាត់គឺជាមេបញ្ជាការម្នាក់ដែលត្រូវដឹកនាំកងអនុសេនាធំហ្នឹង ឱ្យធ្វើការងារនៅព្រលានយន្តហោះកំពង់ឆ្នាំង។ ត្រឹមត្រូវដែរទេ?

**ឆ៖** ចាស ពេលនោះ ខ្ញុំដឹងតែពីកងអនុសេនាតូចរបស់ខ្ញុំ ខ្ញុំអត់បាន គេចាត់ចែងគ្នាគេខាងលើ

នោះ ក៏ខ្ញុំអត់បានដឹងដែរ។

[១៥:២៤:៥៨]

**ស៖** នៅពេលលោកស្រីចូលរួមកងពល៥០២ តើលោកស្រីបានទទួលការហ្វឹកហ្វឺនខាងផ្នែកកងទ័ពនេះដែរទេ?

**ឆ៖** ចាស អត់បានទទួលហ្វឹកហ្វឺនអីទេ។

**ស៖** តើលោកស្រីដឹងពីរបៀបប្រើប្រាស់អាវុធទេ ការប្រើប្រាស់អាវុធធុនធ្ងន់ អាវុធវែងៗអីអ៊ីចឹង?

**ឆ៖** ខ្ញុំអត់បានដឹងទេ ចាស។

**ស៖** អ៊ីចឹងនៅក្នុងចន្លោះពីឆ្នាំ៧៤-៧៥ ពេលលោកស្រីធ្វើជាទ័ពនៅនិរតីហ្នឹង តើលោកស្រីធ្វើអ្វី?

**ឆ៖** ចាស កាលហ្នឹងគេឲ្យខ្ញុំរែកបាយស្លុក។

**ស៖** នៅមុនឆ្នាំ១៩៧៥ លោកស្រីបានឆ្លើយថា លោកស្រីគឺជាយុទ្ធនារីម្នាក់ចូលរួមប្រយុទ្ធ។ នៅពេលនោះលោកស្រីមានអាយុ១៤ឆ្នាំ។ តើលោកស្រីធ្វើអ្វីនៅក្នុងជួរកងទ័ពបដិវត្តន៍កម្ពុជានៅភូមិភាគនិរតីហ្នឹង?

**ឆ៖** ខ្ញុំអត់បានប្រយុទ្ធទេ ខ្ញុំបានតែយកបាយស្លុកឲ្យគេនៅសមរភូមិ។

**ស៖** តើលោកស្រីជាយុទ្ធជនជាកងទ័ព ឬក៏ជាអ្វី? មិនចាំបាច់ថា យុទ្ធនារីមិនចាំបាច់ទៅប្រយុទ្ធនៅសមរភូមិទេ គ្រាន់តែថាមានតួនាទីជាកងទ័ព ជាយុទ្ធនារី ឬក៏មិនមែនទេ?

**ឆ៖** ចាស មានតួនាទីជាយុទ្ធនារីនៅកងទ័ព។

[១៥:២៧:៤៦]

**ស៖** ខ្ញុំសូមបន្តចូលទៅការរៀបការរបស់លោកស្រី។ លោកស្រីបាននិយាយថា លោកស្រីត្រូវបានគេបង្ខំឲ្យរៀបការជាមួយនឹងកម្មាភិបាលម្នាក់។ ប៉ុន្តែ៣ថ្ងៃក្រោយមក គេអនុញ្ញាតឲ្យលោកស្រីលែងលះគ្នា។ ហើយក្នុងពេលជាមួយគ្នានោះដែរ លោកស្រីនិយាយថា ឈ្លបគេដើរឆ្លងកាត់មក ហើយគេលបស្តាប់ចង់ដឹង ថាតើលោកស្រីនេះរួមដំណេកជាមួយប្តីលោកស្រីឬក៏អត់។ លោកស្រីសូមលោកស្រីពន្យល់បន្តិចមើល៍ ដែលថាម៉េចបានគេទៅលបស្តាប់លោកស្រី ព្រោះលោកស្រីឆ្លើយថា ៣ថ្ងៃក្រោយមកលោកស្រីត្រូវបានគេអនុញ្ញាតឲ្យលែងលះគ្នា។

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណីសូមកុំអាលឆ្លើយតប!

សូមអញ្ជើញលោកមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី!

**លោកស្រី ម៉ារី ហ្គ័រូវ៉ង់៖**

សូមអរគុណលោកប្រធាន ខ្ញុំធ្វើការកត់សម្គាល់ខ្លីមួយ។ ដើមបណ្ដឹងរដ្ឋប្បវេណីមិនបាននិយាយថាគាត់ទទួលការអនុញ្ញាតឲ្យលែងលះគ្នាទេ។ គាត់គ្រាន់តែនិយាយថា គាត់បានបែងគ្នាតែប៉ុណ្ណឹងទេ។ នៅបែកគ្នា គាត់មិនបាននិយាយថាបានលែងលះ គេឲ្យគាត់លែងលះគ្នាទេ លោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ប្រហែលជាខ្ញុំសរសេរទៅមិនបានត្រឹមត្រូវ។ បើខ្ញុំយល់មិនច្រឡំទេ ចម្លើយរបស់ -- ក្នុងចម្លើយរបស់លោក លោកស្រីឆ្លើយថា ៣ថ្ងៃក្រោយមកលោកស្រីក៏បានលែងលះគ្នា ឬក៏ខ្ញុំយល់ច្រឡំអ៊ីចឹង ឬក៏ត្រូវប្រើពាក្យថាម៉េច?

[១៥:២៩:៣២]

**លោកស្រី ជុំ សាមឿន៖**

**ឆ៖** ចាស អត់មានបានលែងលះទេ។ ពេល៣ថ្ងៃក្រោយ គឺបែកគ្នាធ្វើការរៀង១ខ្លួន ចាស។

**ស៖** ប្រហែលមានបញ្ហាបកប្រែ។ ខ្ញុំឮពាក្យ *"ឌីវ័ស៍"* លែងលះគ្នា តើលោកស្រី សូមប្រើពាក្យឲ្យចំមើល៍ យ៉ាងម៉េចដែរ?

**ឆ៖** ចាស ចំហើយ។ ខ្ញុំមិនថាលែងលះទេ គឺមានការបែកគ្នា ធ្វើការរៀង១ខ្លួន។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកមេធាវីមិនប្រើពាក្យ "លែងលះ" ទេ។ គ្រាន់តែថា១ គឺថាបានរស់នៅបែកគ្នា។ វាខុសគ្នា។

**លោក វ៉ិចទ័រ កូប៉េ៖**

ប្រហែលជាអាចអ៊ីចឹង។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំសូមប្រើពាក្យមួយទៀតទៅចុះ។ លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី ៣ថ្ងៃក្រោយមកលោកស្រីរស់នៅបែកគ្នាជាមួយប្ដីលោកស្រី មិនអ៊ីចឹងឬ?

**លោកស្រី ជុំ សាមឿន៖**

**ឆ៖** ចាស រស់នៅបែកគ្នា។

[១៥:៣១:០៣]

**ស៖** តើគេអនុញ្ញាតឲ្យលោកស្រីរស់នៅបែកគ្នាអ៊ីចឹង ឬក៏បាន ឬក៏អត់ទេ៣ថ្ងៃក្រោយមក?

**ឆ៖** ចាស គេអនុញ្ញាតឲ្យបែកគ្នា ធ្វើការរៀងៗខ្លួនអ៊ីចឹង។

**ស៖** បាទ ខ្ញុំសូមបន្តទៅមុខទៀត។ តើលោកស្រីត្រូវបានគេ -- មានចូលរួមនៅក្នុងវគ្គរៀនសូត្រអីមួយ ឬក៏វគ្គលត់ដំអីមួយទេ នៅកំពង់ឆ្នាំង?

**ឆ៖** ចាស អត់ដែលបានលត់ដំវគ្គអីទេ។

**ស៖** តើលោកស្រីអាចពន្យល់ជូនតុលាការបានទេ មានការប្រព្រឹត្តខុសគ្នាទេនៅពេលលោកស្រីនៅកំពង់ឆ្នាំងរយៈពេល៣ខែនុ៎ង? ឧទាហរណ៍ថា ខែដំបូងអ៊ីចឹង គឺគេប្រព្រឹត្តមកលើលោកស្រីផ្សេង ហើយខែក្រោយៗមកទៀត គឺថាគេបានប្រព្រឹត្តមកលើលោកស្រីខុសពីខែមុន។ តើមានអ៊ីចឹងទេ?

**ឆ៖** ចាស អត់មានទេ។

**ស៖** សូមលោកស្រីពន្យល់ជម្រាបជូនតុលាការបន្តិចថា ហេតុអ្វីបានជាការងាររបស់លោកស្រីនៅព្រលានយន្តហោះកំពង់ឆ្នាំងហ្នឹង គឺវាដោយសារតែលោកស្រីមាននិន្នាការ ឬក៏ត្រូវបានគេយកទៅកសាង ឬក៏បញ្ជូនទៅនោះដោយសារតែលត់ដំ តើលោកស្រីអាចពន្យល់ចំណុចទាំងអស់នេះ បន្តិចបានទេ?

**ឆ៖** ខ្ញុំអត់បានដឹងគេបញ្ជូនខ្ញុំទៅ ដោយសារជាប់ពាក់ព័ន្ធអីទេ គឺខ្ញុំអត់បានដឹង។ ដឹងតែគេបញ្ជូនខ្ញុំទៅធ្វើការនៅទីនោះ។

[១៥:៣៣:២៤]

**ស៖** ដូច្នេះ គេបញ្ជូនលោកស្រីទៅទីនោះដើម្បីបំពេញភារកិច្ចជាធម្មតាក្នុងនាមលោកស្រីជាកងទ័ពកងពល៥០២។ បើខ្ញុំមិននិយាយថាអ៊ីចឹង តើត្រឹមត្រូវ ឬក៏មិនត្រឹមត្រូវទេ?

**ឆ៖** ចាស ត្រឹមត្រូវហើយ។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំ។ លោកស្រីបាននិយាយថា លោកស្រីមិនអាចបដិសេធបញ្ជាឲ្យលោកស្រីទៅធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំងបានទេ។ តើគេអនុញ្ញាតឲ្យយុទ្ធជន យុទ្ធនារីបដិសេធបញ្ជារបស់មេបញ្ជាការបានទេ?

**ឆ៖** ចាស គេមិនអនុញ្ញាតឲ្យបដិសេធទេ។

**ស៖** ចាតើគេមានបានបណ្តុះបណ្តាលលោកស្រីថា ក្នុងនាមជាកងទ័ព គឺថាត្រូវតែធ្វើតាមបញ្ជារបស់មេបញ្ជាការគ្រប់ពេលវេលា? គេមានបង្រៀនអ៊ីចឹងទេ?

**ឆ៖** ចាស គ្រាន់តែគេប្រាប់ថា ឲ្យធ្វើការងារឲ្យបានល្អ ដើម្បីឲ្យឆាប់ហើយ។

**ស៖** ប៉ុន្តែនៅពេលលោកស្រីធ្វើជាយុទ្ធនារីមុនឆ្នាំ៧៥ និងក្រោយឆ្នាំ៧៥ លោកស្រីថាត្រូវតែធ្វើតាមបញ្ជា -- ត្រូវធ្វើតាម -- តើលោកស្រីត្រូវតែធ្វើតាមបញ្ជារបស់មេបញ្ជាការឬ?

**ឆ៖** ចាស យើងរស់នៅរបបនោះត្រូវតែធ្វើតាមគេបញ្ជាចាស។

**ស៖** ខ្ញុំដឹងហើយ គឺថាកងទ័ពនៅលើពិភពលោកនេះ ទាហាននៅលើពិភពលោកគឺថាត្រូវតែគោរពបញ្ជារបស់មេហើយ។ ប៉ុន្តែតើលោកស្រីត្រូវបានគេប្រាប់ទេ គេមានបានប្រាប់លោកស្រីថា នែ៎! អ្នកឯងត្រូវតែធ្វើតាមបញ្ជារបស់មេបញ្ជាការ នៅពេលលោកស្រីធ្វើជាយុទ្ធនារីហ្នឹង?

**ឆ៖** ចាស គេប្រាប់ត្រូវតែគោរពវិន័យបញ្ជាការចាស។ គេប្រាប់ធ្វើអី យើងត្រូវធ្វើហ្នឹង។

[១៥:៣៦:១៦]

**លោក វិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ។ សូមអរគុណលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកមេធាវី។ សូមអញ្ជើញលោកមេធាវីការពារលោក ខៀវ សំផន មានសំណួរដើមបណ្តឹងរដ្ឋប្បវេណី!

**លោក អាកទួរ វែកគែន៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** ជម្រាបសួរលោកស្រី។ បាទ ខ្ញុំសួរខ្លីទេ ខ្ញុំចង់ចោទសំណួរមួយ សំណួរទូលាយទេ។ អម្បាញ់មិញនេះ គេចោទសំណួរហ្នឹងទៅលោកស្រីដែរ ទាក់ទងទៅនឹងការអប់រំនៅក្រោមរបបខ្មែរក្រហមនោះ។ ខ្ញុំចង់សួរលោកស្រីថា មានពេលណាមួយនោះ លោកស្រីមានត្រូវបានគេអប់រំលោកស្រីទេ?

**លោកស្រី ជុំ សាមឿន៖**

**ឆ៖** ចាស អត់ដែលមានអប់រំផង។

[១៥:៣៧:១៣]

**ស៖** បាទ ខ្ញុំសូមអាននូវអ្វីដែលលោកបានឆ្លើយនៅក្នុងឯកសារដែលមេធាវីរបស់លោកស្រីហ្នឹងបានផ្ដល់ជូនលោកស្រី គឺឯកសារ D22/1067, ERN ជាភាសាបារាំងគឺ 00578977, ជាភាសាខ្មែរគឺ 00578979, ជាភាសាអង់គ្លេសគឺ 00846968។ បាទ លោកនិយាយអំពី -- លោកស្រីនិយាយអំពីការរៀបការរបស់លោកស្រី លោកស្រីនិយាយថា៖ "គេប្រាប់ខ្ញុំថា បើសិនជាខ្ញុំមិនរៀបការនោះទេ គឺលោកស្រីនឹងមិនជួបបុរសណាទៀតទេ បើសិនជា -- ដោយសារខ្ញុំជំទាស់ហ្នឹងគេឱ្យខ្ញុំ អប់រំខ្ញុំចំនួន៤ថ្ងៃ ហើយគេឱ្យធ្វើការតាំងពីម៉ោង -- យប់ទៀត ពីម៉ោងដប់ប្រាំបួនដល់ម៉ោងម្ភៃមួយ។" ហើយដោយសារប្រវត្តិរូបរបស់ឪពុកម្ដាយរបស់លោកស្រីហ្នឹងពីមុនមកមានជាប់ពាក់ព័ន្ធនឹង លន់ នល់។ នេះជាអ្វីដែលលោកស្រីបានឆ្លើយនៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០១០ ដោយមេធាវីគ្មានព្រំដែន។

លោកស្រីក៏បានឆ្លើយផ្ដល់ចម្លើយផ្សេងៗទៀតផងដែរ នៅឆ្នាំ២០១០ដដែលនេះ គឺនៅលេខ ERN 00575936 នេះគឺជា ERN ជាភាសាបារាំង, ជាភាសាខ្មែរគឺ 00518255 (សូមទោស) 45, អង់គ្លេសគឺ 00842140។ លោកស្រីបាននិយាយអំពីការរៀបការនេះដដែល ហើយលោកស្រីរៀបរាប់ដូចតទៅនេះ៖ "ផ្ទុយទៅវិញដោយសំណាងល្អ គេមិនបានកោះហៅខ្ញុំទៅអប់រំនោះទេ ដោយសារតែអ៊ីចឹងហើយ បានខ្ញុំរួចរស់រានមានជីវិតដល់សព្វថ្ងៃ។" ក្នុងឯកសារនេះគឺលោកស្រីបានចុះហត្ថលេខាដោយខ្លួនឯង មិនត្រឹមតែប៉ុណ្ណឹងទេមានស្នាមផ្ដិតមេដៃទៀត។ លោកស្រីបាននិយាយថា ថាអង្គការឱ្យលោកស្រីស្រាវជ្រាវប្រវត្តិរូបកងទ័ពទាំងអស់។ អ៊ីចឹងខ្ញុំចង់សួរលោកស្រីថា មួយដែល -- ម្ដងលោកស្រីនិយាយថា គេអប់រំលោកស្រី ឱ្យលោកស្រីធ្វើការតាំងពីម៉ោងប្រាំពីរដល់ម៉ោងប្រាំបួនយប់។ ហើយមួយទៀតលោកស្រីឆ្លើយថា លោកស្រីមិនត្រូវបានគេអប់រំអ្វីនោះទេ។ តើលោកស្រីយកចម្លើយមួយណាក្នុងចំណោមចម្លើយទាំងពីរនេះ?

[១៥:៤០:២៥]

**ឆ៖** ចាស ខ្ញុំអត់ដឹងគេអប់រំម៉េច អាហ្នឹងគេហៅយើងទៅប្រជុំប្រាប់ឱ្យយើងធ្វើតាមគេ ចាស។

**ស៖** អម្បាញ់មិញនេះ តើខ្ញុំយល់ត្រឹមត្រូវដែរឬទេ គឺថាលោកស្រីបានជំទាស់ លោកស្រីជំទាស់មិនព្រមស្រាវជ្រាវលើប្រវត្តិរូបកងទ័ពទាំងអស់ដែលអង្គការប្រាប់ឱ្យធ្វើនោះទេ។ តើខ្ញុំយល់អ៊ីចឹងត្រឹម

ត្រូវដែរឬទេ លោកស្រីជំទាស់មិនព្រមធ្វើតាមបញ្ជាអង្គការ?

**ឆ៖** គេអត់បានប្រាប់ឲ្យខ្ញុំដើរស្រាវជ្រាវប្រវត្តិរូបរបស់អ្នកនៅក្នុងកងហ្នឹងទេ។ គ្រាន់តែគេប្រាប់ខ្ញុំថា "អ្នកឯងត្រូវគេស្រាវជ្រាវប្រវត្តិរូប អ្នកឯងត្រូវជាប់ពាក់ព័ន្ធនិន្នាការ ឪធ្វើប៉ូលិស ឪពុកចុងធ្វើទាហាន" គេគ្រាន់តែប្រាប់ប៉ុណ្ណឹង។ បើឲ្យខ្ញុំទៅស្រាវជ្រាវប្រវត្តិរូប ក៏ខ្ញុំគ្មានសិទ្ធិអ្វីទៅស្រាវជ្រាវទេចាស។

**ស៖** ទាក់ទងនឹងការងាររបស់លោកជាគិលានុបដ្ឋាយិកានោះ លោកស្រីបានជំទាស់ដែរ។ អ៊ីចឹងខ្ញុំសួរលោកស្រីថា លោកស្រីនៅតែជំទាស់ដដែល ឬក៏យ៉ាងម៉េច ព្រោះថានៅក្នុងចម្លើយរបស់លោកស្រីដែលលោកស្រីបានផ្តិតមេដៃ ហើយចុះហត្ថលេខាទៀតនេះ គឺថាមានសរសេរថា លោកស្រីធ្លាប់ជាគិលានុបដ្ឋាយិកា? អ៊ីចឹងឥឡូវនេះលោកស្រីនៅតែបដិសេធដដែល ឬក៏យ៉ាងម៉េច ថាលោកស្រីមិនដែលធ្លាប់ធ្វើការងារអ៊ីចឹងទេ?

**ឆ៖** ចាស ខ្ញុំអត់បានធ្វើពេទ្យផង។

**ស៖** តើលោកស្រីមានបានអានឯកសារហ្នឹងទេ ចម្លើយរបស់លោកស្រីហ្នឹងដែលមុននឹងចុះហត្ថលេខា ហើយនិងផ្តិតមេដៃ? តើលោកស្រីមានបានអានទេ ឯកសារដែលជាទម្រង់សុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោកស្រីនេះ?

**ឆ៖** ចាស ខ្ញុំអត់បានអានទេ ព្រោះខ្ញុំមិនសូវចេះអក្សរផង។

[១៥:៤៣:៤១]

**ស៖** ឯកសារហ្នឹងលោកស្រីអ្នកសរសេរដោយខ្លួនឯង ឬក៏អ្នកធ្វើជាមួយអ្នកណាផ្សេងទៀត ព្រោះថានៅចុងឯងសារហ្នឹង គេបញ្ជាក់ថា គេបានអានជូនលោកស្រីស្តាប់ លោកស្រីបានអានឯកសារហ្នឹងហើយ មុននឹងចុះហត្ថលេខា ឬក៏ផ្តិតមេដៃ?

**ឆ៖** ចាស ខ្ញុំអត់បានអានផង។

**ស៖** អម្បាញ់មិញនេះ ពេលដែលគេសួរលោកស្រី លោកស្រីឆ្លើយជាច្រើនដងថា លោកស្រីជាមនុស្សតែមួយគត់ដែលគេសង្ស័យ ដែលជាប់ពាក់ព័ន្ធ។ នៅពេលដែលលោកស្រីនិយាយថា លោកស្រីតែម្នាក់ឯងហ្នឹង គឺថាចង់និយាយថា លោកស្រីជាមនុស្សតែម្នាក់ឯងគត់នៃកងរបស់លោកស្រីដែលត្រូវបានគេបញ្ជូនទៅកសាងនោះ ឬក៏យ៉ាងណា? ខ្ញុំនិយាយអម្បាញ់មិញនេះ សំដៅលើថាជាប់ពាក់ព័ន្ធជាមួយរបបចាស់។ តើលោកស្រីជាអ្នកជាប់ពាក់ព័ន្ធរបបចាស់ ហើយដែលត្រូវគេសង្ស័យតែម្នាក់ឯងគត់ ឬ

យ៉ាងម៉េច?

**ឆ៖** ចាស គេថាតែខ្ញុំម្នាក់ឯងហ្នឹង។ ថាខ្ញុំពាក់ព័ន្ធខ្សែធ្វើប៉ូលិស ធ្វើទាហាន លន់ នល់ ហ្នឹង ចាស។ តែម្នាក់ខ្ញុំហ្នឹង។

**ស៖** ក៏ប៉ុន្តែជាច្រើនដង លោកស្រីនិយាយថា លោកស្រីជាមនុស្សតែម្នាក់គត់ដែលគេចោទលោកស្រីថាជាប់ពាក់ព័ន្ធនេះ។ អ៊ីចឹងខ្ញុំចង់សួរលោកស្រីថា មានន័យយ៉ាងម៉េចដែរ ម្នាក់ឯងហ្នឹងធៀបនឹងកងរបស់លោកស្រី ឬយ៉ាងណា?

**ឆ៖** ចាស កង -- អ្នកគេរកដឹង ខ្ញុំអត់បានដឹងគេចុះស្រាវជ្រាវប្រវត្តិរូបឬអត់ទេ តែគេប្រាប់តែខ្ញុំម្នាក់ឯង។

[១៥:៤៦:០០]

**លោក អាកទ្វូរ វែកគែន៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយលោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកមេធាវី។ លោកមេធាវីជាតិមានសំណួរទេ?

**លោក គង់ សំអុន៖**

អត់មានសំណួរទេលោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រី ជុំ សាមឿន។ ដូចអង្គជំនុំជម្រះបានជម្រាបលោកស្រីរួចហើយកាលពីមុននឹងស្តាប់សក្ខីកម្មរបស់លោកស្រី ថាពេលចុងក្រោយ លោកស្រីអាចថ្លែងរៀបរាប់ប្រាប់ដល់អង្គសវនាការអំពីរឿងហេតុទំនាក់ទំនងទៅនឹងបទឧក្រិដ្ឋ ដែលត្រូវបានចោទប្រកាន់ចំពោះជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន ដែលបានប៉ះពាល់ចំពោះលោកស្រីក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលនាំឱ្យលោកស្រីសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប្តឹងទាមទារសំណងជំងឺចិត្ត ឬជាសមូហភាពពីជនជាប់ចោទ និងអំពីស្ថានភាពព្យសនកម្មដែលមានចំពោះលោកស្រីជាអាទិ៍ ការខូចខាតរាងកាយ ផ្លូវចិត្ត ឬខូចខាតសម្ភារៈ ផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋ ជាព្យសនកម្មផ្ទាល់ខ្លួន និងបានកើតឡើងពិតប្រាកដរហូតដល់បច្ចុប្បន្ន។ ប្រសិនបើលោកស្រីមានបំណងធ្វើដូច្នេះ។ សូមអញ្ជើញ!

[១៥:៤៧:៤៩]

**លោកស្រី ជុំ សាមឿន៖**

ចាស ខ្ញុំសូមធ្វើការ ពីខ្លួនខ្ញុំផ្ទាល់តាំងពីខ្ញុំចូលបម្រើទ័ពនៅកម្ពុជាប្រជាធិបតេយ្យ គឺខ្ញុំមានប៉ះពាល់អារម្មណ៍របស់ខ្ញុំ ដូចជាខ្ញុំត្រូវគេធ្វើការជាទម្ងន់។ ពេលខ្ញុំឈឺ កើតពិសដែក៏គេប្រើខ្ញុំ។ ដល់ពេលខ្ញុំសុំឈប់សម្រាក ក៏គេមិនឲ្យសម្រាក។ ហេតុដូច្នេះ អារម្មណ៍របស់ខ្ញុំរាល់ថ្ងៃ គឺខ្លួនខ្ញុំគឺខ្សោយបេះដូងហើយនិងខូចតម្រងនោម ដោយការធ្វើការជាទម្ងន់។ ដល់ពេលឪពុកម្ដាយ បងប្អូនខ្ញុំក៏ត្រូវគេសម្លាប់ចោល។ ផ្ទះសម្បែងខ្ញុំត្រូវខូចខាតទាំងអស់ ខ្ញុំគ្មានដីធ្លីទាំងអស់។ ទាល់ខ្ញុំរត់មកវិញ គឺមានតែខ្លួនខ្ញុំម្នាក់គត់ គឺនៅកំព្រាឯកា គ្មានអ្នកណាទីពឹងទាំងអស់។ ហេតុដូច្នេះ គឺក្នុងអារម្មណ៍របស់ខ្ញុំ គឺក្ដុកក្ដួលក្នុងចិត្តតាំងពីនោះ រហូតដល់សព្វថ្ងៃ គឺគ្មានឪពុកម្ដាយហៅ ឬបងប្អូនទាំងអស់ សាច់ញាតិក៏គ្មាន។ ហេតុដូច្នេះគឺខ្ញុំ អារម្មណ៍របស់ខ្ញុំគឺក្ដុកក្ដួលក្នុងអារម្មណ៍របស់ខ្ញុំ គឺមានជំងឺរហូតដល់សព្វថ្ងៃ។ គឺខ្ញុំរស់នៅជាមួយឪពុកម្ដាយខ្ញុំ គេមិនដែលប្រើប្រាស់ខ្ញុំយ៉ាងដូច្នេះ។ ខ្ញុំសុទ្ធចិត្តលះបង់ខ្លួនតាំងពីអាយុកុមារភាព ១០ឆ្នាំ ខ្ញុំទៅបម្រើទ័ព ថាខ្ញុំសុខស្រួល បែរមិនសុខស្រួល ប្រើខ្ញុំដូចគោ ដូចក្របី។ អ៊ីចឹងខ្ញុំមានអារម្មណ៍ឈឺចាប់ខ្លោចផ្សានៅក្នុងចិត្តរបស់ខ្ញុំ។ ពេលខ្ញុំរាំងរដូវ គេចោទខ្ញុំថាខ្ញុំពោះធំ ប្រើធ្វើការធ្ងន់ គឺខ្ញុំមានអារម្មណ៍ខូចខាតក្នុងខ្លួនរបស់ខ្ញុំ។ ខ្ញុំកំព្រាម៉ែកំព្រាឪ បងប្អូនក៏គ្មាន។ តែឥឡូវខ្ញុំចង់សួរទៅលោក ក្រោយពីតុលាការបានរកការខុសត្រូវរបស់លោកអស់ហើយ តើលោកហ៊ានសូមលើកដៃសំពះ សូមទោសឧក្រិដ្ឋដែលបានពលីជីវិតទៅ ទាំងអ្នកនៅរស់ដែរឬអត់? ដូចជាលោក ឌុច ដែរឬអត់? ខ្ញុំសូមតែប៉ុណ្ណឹង គឺខ្ញុំអស់ចិត្ត ទាំងបងប្អូនប្រជាជនទូទាំងប្រទេសក៏អស់ចិត្តដែរ។ ជាសំណាងខ្ញុំចង់ថា ឲ្យខ្ញុំបានធ្វើជាសំណាងឯកជន ដូចជាអ្នកកោះពេជ្របានដែរឬទេ? គឺខ្ញុំសូមសួរតែប៉ុណ្ណឹង។ ខ្ញុំសូមចប់ហើយ។

[១៥:៥១:០៤]

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកស្រី ជុំ សាមឿន។ អង្គជំនុំជម្រះសូមជម្រាបជូនលោកស្រីថា នៅក្នុងសវនាការកាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ បន្ទាប់ពីអង្គជំនុំជម្រះបានស្ដាប់ជនជាប់ចោទទាំងពីររូបឆ្លើយបញ្ជាក់អំពីជំហររបស់ពួកគាត់ក្នុងការរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបនឹងសំណួរ ហើយពេលនោះអង្គជំនុំជម្រះកត់សម្គាល់ថា ជនជាប់ចោទទាំងពីររូបនៅតែរក្សាជំហររបស់ខ្លួនក្នុងការអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតប។ លើកលែងតែ និងរហូតដល់ពេលណា ដែលអង្គជំនុំជម្រះទទួលបានព័ត៌មានជាក់ច្បាស់ផ្សេងទៀតពីជនជាប់ចោទ និងពីសហមេធាវីការពារក្ដីរបស់ជនជាប់ចោទ។ ហើយពេលនោះ

អង្គជំនុំជម្រះក៏បានដាក់កាតព្វកិច្ចឲ្យជនជាប់ចោទ និងមេធាវីការពារក្តីជនជាប់ចោទ ត្រូវជូនដំណឹងដល់អង្គជំនុំជម្រះឲ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព ប្រសិនបើជនជាប់ចោទមានការសម្រេចលះបង់សិទ្ធិនៅស្ងៀមមិនឆ្លើយតប ហើយយល់ព្រមឆ្លើយតបនឹងសំណួរនៅដំណាក់កាលណាមួយនៃកិច្ចដំណើរការនីតិវិធី។ ហើយរហូតមកដល់ពេលនេះ អង្គជំនុំជម្រះមិនទាន់បានទទួលដំណឹងពីការផ្លាស់ប្តូរជំហររបស់ជនជាប់ចោទទាំងពីរនាក់ ពីការសម្រេចលះបង់សិទ្ធិនៅស្ងៀមមិនឆ្លើយតប មកជាការឆ្លើយតបនឹងសំណួរនោះឡើយ។ សូមលោកស្រីជ្រាប។

សវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីបានចប់ហើយ។ អង្គជំនុំជម្រះអរគុណលោកស្រី ជុំ សាមឿន សវនាការស្តាប់សក្ខីកម្ម និងការស្តាប់ការថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មដែលលោកស្រីអះអាងថា លោកស្រីបានទទួលរងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានដល់ទីបញ្ចប់ហើយ។

លោកស្រីអាចវិលត្រឡប់ទៅវិញ ហើយសូមលោកស្រីមានសំណាងល្អ មានសុខភាពល្អ និងវិលត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។ អង្គជំនុំជម្រះសូមអរគុណ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន វិលត្រឡប់ទៅវិញ។

សវនាការនៅថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ។ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ទី២៥ ខែមិថុនា ឆ្នាំ២០១៥ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ សវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-855 ពាក់ព័ន្ធនឹងការដ្ឋានទំនប់១មករា។ ដូច្នេះសូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាកំណត់នេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែក ទី២៥ មិថុនា ឆ្នាំ២០១៥ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សូមអញ្ជើញសម្រាក៕

*(សវនាការផ្អាកនៅម៉ោង ១៥:៥៤ នាទី)*